# មជ្ឈមណ្ឌលឯកសារកម្ពុជា

## សឿ ទូច ហៅ សឿ លី ភេទប្រុស (នៅរស់)
## មុខងារ កងពល១៦៤
## សម្ភាសជាមួយ សឿ ទូច ហៅ សឿ លី អាយុ៥០ឆ្នាំ ក្រោយប្រវត្តិរូប
## រស់នៅភូមិជនពិការវាលធំ ឃុំត្រែងត្រយឹង ស្រុកភ្នំស្រួច ខេត្តកំពង់ស្ពឺ
## ថ្ងៃទី១ ខែមិថុនា ឆ្នាំ២០០៧
## សម្ភាសដោយ ៖ ឡុង ដានី

ដានី ៖ អញ្ចឹងដំបូងខ្ញុំចង់ស្គាល់ឈ្មោះពូ ឈ្មោះពេញម៉ង?

ទូច ៖ អឺ!ខ្ញុំឈ្មោះពេញ អឺ!ពីដើម ខ្ញុំឈ្មោះសឿ ទូច ។

ដានី ៖ សឿ ទូចហ៎?

ទូច ៖ បាទ!កាលដែលខ្ញុំប្រើជាធម្មតា កាលដែលខ្ញុំនៅចូលធ្វើកងទ័ពពីដំបូងៗខ្ញុំឈ្មោះសឿ ទូចអញ្ចឹង ហើយក្រោយមកនឹងខ្ញុំយកត្រកូលដាក់កណ្តាល ហើយខាងដើមក៏ឈ្មោះ ខាងចុងក៏ឈ្មោះ ។ អញ្ចឹងបានន័យថា វាទៅជាទូច សឿ លី ។

ដានី ៖ ទូច សឿ លី ។

ទូច ៖ បាទ!ខាងដើមក៏ឈ្មោះគេហៅទូច អ្នកខ្លះគេហៅលី បាទ!អញ្ចឹងត្រកូលនៅកណ្តាល ។

ដានី ៖ បាទៗ ត្រកូលនៅកណ្តាលវិញ ។

ទូច ៖ មានខាងដើម មានខាងចុង ។

ដានី ៖ ពូចាប់ផ្តើមដូរឈ្មោះពីសឿ ទូ មកទូច សឿ លីនឹងតាំងពី?

ទូច ៖ បាទ!ខ្ញុំចាប់ផ្តើមដូរនឹងនៅពេលដែលខ្ញុំមកដល់ស្រុកខ្មែរយើងនៅឆ្នាំ៩១ ។

ដានី ៖ សព្វថ្ងៃខ្ញុំពូអាយុប៉ុន្មានហើយ?

ទូច ៖ សព្វថ្ងៃ៥០ហើយ ។

ដានី ៖ ពូមានស្រុកកំណើតកើតជានៅភូមិឃុំស្រុកអីដែរ?

ទូច ៖ បាទ!ខ្ញុំនៅភូមិថ្មី ។

ដានី ៖ ភូមិថ្មី ។

ទូច ៖ អឺ!ឃុំស្តុក ។

ដានី ៖ ឃុំស្តុក ។ ស្រុក?

ទូច ៖ ស្រុកកងពិសី ។

ដានី ៖ ស្រុកកងពិសី ខេត្តកំពង់ស្ពឺ ។

ទូច ៖ បាទ!កំពង់ស្ពឺ ។

ដានី ៖ បាទ!សព្វថ្ងៃពូរស់នៅភូមិឃុំស្រុកអីដែរ?

ទូច ៖ បាទ!សព្វថ្ងៃខ្ញុំនៅអឺ! ភូមិជនពិការ ។

ដានី ៖ ភូមិជនពិការ?

ទូច ៖ ហ្នឹងភូមិជនពិការវាលធំ ។

ដានី ៖ អានឹងឈ្មោះឃុំអីដែរ?

ទូច ៖ ឃុំត្រែងត្រយឹង ។

ដានី ៖ ឃុំត្រែងត្រយឹង ស្រុកភ្នំស្រួច?

ទូច ៖ ភ្នំស្រួច ។

ដានី ៖ សព្វថ្ងៃពូ ដូចថាមានតួនាទីជាអីដែរ?

ទូច ៖ បាទ!ខ្ញុំសព្វថ្ងៃមានតួនាទីជាប្រធានសមាគមន៍ ។

ដានី ៖ សមាគមន៍ ជនពិការវាលធំ?

ទូច ៖ បាទ!

ដានី ៖ គ្រួសារពូ គាត់ឈ្មោះអីដែរ?

ទូច ៖ ឈ្មោះគឹម មឿន ។

ដានី ៖ ឈ្មោះ គឹម មឿន ។ គាត់អ្នកស្រុកកំណើតនៅណាដែរ?

ទូច ៖ ស្រុកកំណើតនៅតាកែវ ។

ដានី ៖ នៅតាកែវ ។ គាត់អាយុប៉ុន្មានដែរ?

ទូច ៖ អាយុប្រហាក់ប្រហែលគ្នានឹង ។

ដានី ៖ ៥០ដូចគ្នា?

ទូច ៖ បាទ!

ដានី ៖ ពូមានកូនចៅប៉ុន្មាននាក់ដែរ?

ទូច ៖ អឺ!កូនខ្ញុំ៣នាក់ ។

ដានី ៖ ស្រីប៉ុន្មានប្រុសប៉ុន្មាន?

ទូច ៖ ប្រុសទាំងអស់ ។

ដានី ៖ ប្រុសទាំងអស់ ។ អឺ!ឪពុកពូ ឪពុកម្ដាយពូឈ្មោះអីទៅ?

ទូច ៖ ឪពុកឈ្មោះ អម សំ ។

ដានី ៖ អម សំ ។ ម្ដាយ?

ទូច ៖ ម្ដាយឈ្មោះ ឆាយ ហម ។

ដានី ៖ ពួកគាត់ទាំងពីរសព្វថ្ងៃនៅ?

ទូច ៖ នៅៗរស់ ។

ដានី ៖ នៅទាំង២នាក់?

ទូច ៖ បាទ! នៅទាំង២នាក់ ។

ដានី ៖ នៅភូមិកំនើតពូ នៅខាង?

ទូច ៖ បាទ!ភូមិថ្មី ។

ដានី ៖ ពូមានបងប្អូនបង្កើតទាំងអស់ប៉ុន្មាននាក់?

ទូច ៖ បងប្អូនបង្កើតទាំងអស់៤នាក់ ។

ដានី ៖ ៤នាក់ ស្រីប៉ុន្មានប្រុសប៉ុន្មាន?

ទូច ៖ ស្រី២ ប្រុស២ ។

ដានី ៖ ពូកូនទីប៉ុន្មាន?

ទូច ៖ ខ្ញុំកូនទី២ ។

ដានី ៖ កាលពីក្មេងៗពូរៀនសូត្រអីនៅសាលាណាដែរ?

ទូច ៖ ខ្ញុំរៀននៅ កាលពិតទៅឪពុកខ្ញុំគាត់ជាអ្នកបង្រៀនខ្ញុំកាលនឹង ព្រោះយើងនៅក្មេងអឺ!គាត់ដូចជាមិនឲ្យទៅឆ្ងាយពីផ្ទះ ។

ដានី ៖ អត់មានទៅរៀនសាលាទេអញ្ចឹង?

ទូច ៖ បាទ!ហើយក្រោយមកបានយើងទៅរៀននៅសាលាៗសម័យខ្មែរក្រហម៧១ ៧០នឹង ។

ដានី ៖ កាលនឹងពូដូចថាចេះរៀន សម័យនឹងចេះអានចេះសរសេរច្បាស់ទេ?

ទូច ៖ ចេះអាន ចេះសរសេរចេះអី ដូចគេធម្មតា គ្រាន់ថាឪពុកខ្ញុំជាអ្នកបង្រៀនផ្ទាល់ដំបូង ជាធម្មតាគេទៅរៀនសាលាដែរ កាលនឹងសាលាប្រហែលម៉ាគីឡូពីផ្ទះ ។ ប៉ុន្តែ គាត់ដូច មិនដឹងជាគាត់យល់ឃើញយ៉ាងម៉េច គាត់សុខចិត្តចំណាយពេលបង្រៀនខ្ញុំ ហើយគាត់កាលនឹងនៅស្ទើរៗហើយគាត់មិនឲ្យទៅសាលា ។

ដានី ៖ ពូរៀនដល់ឆ្នាំណាបានឈប់?

ទូច ៖ ខ្ញុំរៀនដល់ឆ្នាំ៧១ ។

ដានី ៖ ឆ្នាំ៧១នឹងឈប់?

ទូច ៖ អឺ!

ដានី ៖ ពីឆ្នាំ៧១ឈប់ ពូធ្វើអីទៀតទៅ?

ទូច ៖ កាលនឹងមាន អឺ!យន្តហោះទម្លាក់ មានអឺ!ចាប់ផ្ដើមឈប់រៀនជាងម៉ាឆ្នាំហើយ ។ ហើយដល់ពេលឆ្នាំ៧១នឹងខ្ញុំក៏ចាប់ផ្ដើមចូល ។ កាលនឹងមានចលនា គេហៅចលនាកងទ័ពរំដោះនឹង យើងក៏ចាប់ផ្ដើមចូលធ្វើទាហាន ចូលទៅធ្វើការមុនដំបូងយើងទៅធ្វើការនៅសាលាឃុំ ជាកុមារអីអញ្ចឹងណា ។

ដានី ៖ កាលនឹងពូស្ម័គ្រចិត្ត?

ទូច ៖ បាទ!កាលនឹងស្ម័គ្រចិត្ត ព្រោះតែក! កាលពិតទៅគេក៏គេធ្វើអញ្ចឹង ឃើញថាវារត់របត់ទៅទាំងអស់គ្នាហើយ មិនមានអ្នកណានៅផ្ទះនៅអីផង ។

ដានី ៖ ពូចូលទៅសាលា ធ្វើនៅសាលាឃុំនឹង ធ្វើរយៈពេលប៉ុន្មានទៅ?

ទូច ៖ អានឹងយើងធ្វើជាកុមារនឹងរយៈពេល២ ៣ខែនឹង ហើយដល់២ ៣ខែអញ្ចឹងទៅបានយើងទៅស្រុក ។

ដានី ៖ ក្នុងឆ្នាំ៧១ដដែល?

ទូច ៖ បាទ! ទៅស្រុកហើយ បានយើងចេញពីស្រុកទៅៗខេត្ត ទៅធ្វើទាហាន ។

ដានី ៖ ទៅស្រុកហើយ ទើបបន្តទៅខេត្តទៀត?

ទូច ៖ បាទ!បន្តទៅខេត្តទៅ ។

ដានី ៖ ហើយយ៉ាងម៉េចទៀតទៅ?

ទូច ៖ ដល់ពេលដល់ខេត្តបានហ៊ានចាប់ផ្ដើមធ្វើទាហានហើយ ទាហានប្រយុទ្ធហើយ ។

ដានី ៖ កាលនឹងពេលដែលជួបពូទៅដល់ខេត្ត ចូលដល់ធ្វើកងទ័ពនឹង ពូនៅក្នុងកង ដូចថាអង្គភាព ដូចថាកងអនុសេនាតូច អនុសេនាធំ វរ កងពលអី?

ទូច ៖ បាទ!ខ្ញុំកាលនឹងនៅក្នុងអនុសេនាធំទី១ វរសេនាតូចលេខ១០២ ។

ដានី ៖ វរសេនាធំ?

ទូច ៖ ហើយបន្ទាប់មកកងតំបន់នឹង បានដល់ឆ្នាំ៧៤ៗយើងឡើងមកកងពល ។

ដានី ៖ បាទ!អញ្ចឹងកាលនៅវរសេនាតូចនឹង នៅក្នុងកងតំបន់ទេ?

ទូច ៖ បាទ!កងតំបន់ ។

ដានី ៖ តំបន់ប៉ុន្មាននឹង?

ទូច ៖ តំបន់៣៣ ។

ដានី ៖ ដល់ឆ្នាំ៧៤ បានឡើងមកកងពល?

ទូច ៖ កងពល កាលនឹងយើងនៅអនុសេនាធំនឹងដដែល ប៉ុន្តែកងវរយើងត្រូវដូរមកអឺ!៤២០ ។

ដានី ៖ ៤២០?

ទូច ៖ បាទ!

ដានី ៖ វរៈធំ វរសេនាធំ?

ទូច ៖ វរសេនាធំ២១ ។

ដានី ៖ ២១ ។ កងពល?

ទូច ៖ កងពលអឺ!ទី៣កាលនឹង ។

ដានី ៖ ទី៣?

ទូច ៖ បាទ!

ដានី ៖ កាលនឹងពូនៅចាំដូចថាគេទម្នាក់នៅអនុសេនាធំទី១របស់ពូ ពីណាគេអ្នកទទួលខុសត្រូវ?

ទូច ៖ អានឹងបងសំនៀង ។

ដានី ៖ សំនៀង ខាងវរសេនាតូច?

ទូច ៖ វរសេនាតូចឈ្មោះអឺ! ឈ្មោះមឿន ។

ដានី ៖ មឿន?

ទូច ៖ បាទ! ស មឿន ។

ដានី ៖ ស មឿន ។ ខាងវរសេនាធំ២១?

ទូច ៖ អានឹងតាមាឃ ។

ដានី ៖ កងពល? តាមុត តែម្នាក់ទេ?

ទូច ៖ កាលនឹងខ្ញុំមិនច្បាស់ វាយូរពេកហើយ មានអ្នកណាខ្លះ មានតារិន មានតាណាមិនច្បាស់ដែរ ។

ដានី ៖ អញ្ចឹងពេលដែលពូមកនៅកន្លែងឆ្នាំ៧៤ ឡើងទៅកងពលនឹង កាលនឹងយើងចាប់ផ្តើមប្រយុទ្ធអីណា?

ទូច ៖ បើយុទ្ធនាការប្រយុទ្ធសមរភូមិខាងលិចភ្នំពេញ តាមប្រជាជនបែកខាងជើង ។

ដានី ៖ យើងប្រយុទ្ធនឹងរហូតដល់ឆ្នាំ?

ទូច ៖ បាទ! បែកប្រយុទ្ធនឹងខាងលិចភ្នំពេញ បែកខាងជើងនឹងដល់ឆ្នាំ៧៥ម៉ងដល់ថ្ងៃ១៧មេសា៧៥ ។

ដានី ៖ យ៉ាងម៉េចទៀតទៅ ដល់ពេលថ្ងៃនឹង?

ទូច ៖ ដល់ថ្ងៃ១៧មេសា៧៥នឹង ខ្ញុំក៏នាំគ្នាចូលមកដល់ភ្នំពេញ បាទ! ពេលថ្ងៃណា ពេលថ្ងៃយើងចូលមកដល់ភ្នំពេញ រហូតដល់ម៉ោង៥កន្លះ ម៉ោង៦ ម៉ោង៧ បានយើងវិលត្រឡប់ទៅកន្លែងវិញជួបជុំគ្នានៅអគ្គស្ថួល ។

ដានី ៖ បាទ! ម៉េចទៀតទៅ?

ទូច ៖ យើងទៅជួបជុំគ្នានៅអគ្គស្ថួល យប់ជ្រៅយើងបានទទួលពត៌មានថា ស្អែកឡើងយើងធ្វើដំណើរទៅក្រុងកំពង់សោម បានទទួលបញ្ជាថាស្អែកឡើង កងអគ្គភាពទាំងអស់ទៅនៅកំពង់សោម ។ ពេលនឹងព្រលឹមឡើងយើងក៏រៀបចំអីវ៉ាន់ឡើងឡានមកកំពង់សោមដែរ ។ បានឡើងឡានទៅកំពង់សោម ខ្ញុំទៅនៅរាម ។

ដានី ៖ ពូទៅនៅរាម?

ទូច ៖ បាទ! ទៅនៅរាមបានប្រហែលជា២ ៣ថ្ងៃនឹង ទៅនៅកោះថ្មីៗពេលនោះយើងទៅធ្វើការយាមល្បាតនៅកោះត្រល់ៗ យើងឡើងលើកោះអីអញ្ចឹងណា ។ ពេលនោះយើងចាប់ផ្តើមបានជិះអាម៉ារីនៗនៅរបស់អាមេរិចកាំង របស់ទាហានលន់នល់ដែលនៅសេសសល់នឹង ។ វាបានដឹងពីជីវិតរបស់យើង ជាធម្មតាយើងនៅទាហានដែរ តែទាហានលើគោក យើងអត់ដែលចុះទៅក្នុងទឹកហើយជិះអាម៉ារីនអីនៅបណ្តែតលើទឹកអីអញ្ចឹងទេ យើងអត់ដែរទេ ។ ដំបូងៗយើងទៅមើលកោះត្រល់ ពេលនឹងយើងទៅមើលកោះត្រល់ កាលនឹងវាជាប់ជំពាក់វាក់វិនថាជាដីរបស់យើង បាទ! ខ្ញុំបានឡើងទៅលើកោះនឹងផ្ទាល់ បានដើរមើលកោះនឹងអី នៅម្តុំឆ្នេរសមុទ្រនឹង ប្រហែលជា២ ៣ថ្ងៃ ហើយបានយើងទទួលបញ្ជាថាដកថយវិញ ។ ហើយពេលនោះមេបញ្ជាការក៏ ខ្ញុំនៅជាប់ជាមួយគាត់ៗឲ្យមកកំពង់សោម យើងចេញពីកោះថ្មីមកនៅកំពង់សោម ។ មកនៅកំពង់សោមដល់៧៦ យើងចូលក្នុងកងអាម៉ារីន ។ ចូលក្នុងកងអាម៉ារីន យើងហ្វឹកហ្វឺនហែលទឹកសិន មុនដំបូង ហ្វឹកហ្វឺនហែលទឹករយៈពេលជិតម៉ាឆ្នាំ ។ ជិតម៉ាឆ្នាំបានយើងបានទៅរៀនសូត្រហ្វឹកហ្វឺនលើអាម៉ារីននឹង ។ កាលនឹងយើងអឺ! ស្រុកខ្មែរយើង៧៦នឹង មានអាម៉ារីនតែ៥គ្រឿងទេ ដែលនាំចូលមកពីជំនួយរបស់ចិននឹង ។ មានអានាវាធន់ការពារនឹងធន់ការពារ៣ ហើយអានាវាបណ្តែតនឹង២ ។ ហើយអឺ! យើងបាននៅរៀនសូត្រពីចិនផ្ទាល់ ហាត់ហ្វឹកហ្វឺនហើយរស់នៅលើនឹង រយៈពេលម៉ាឆ្នាំ ។

ដានី ៖ រៀនម៉ាឆ្នាំ?

ទូច ៖ បាទ! យើងរៀនអឺ! ម៉ាឆ្នាំនឹងទាំងហាត់ហ្វឹកហ្វឺនដាក់ស្តែង ទាំងរៀនទ្រឹស្តីអីនឹង បាទ!យើងចាប់ផ្តើមកាន់កាប់តាំងពី៦ខែឡើងទៅនឹង យើងរៀន៦ខែអញ្ចឹងទៅឲ្យយើងដាក់ ហ្វឹកហ្វឺនដាក់នឹង៦ខែទៀត ក្នុងម៉ាឆ្នាំ ។ ហើយក្រោយមក គេក៏ដកខ្ញុំពីនាវាការពារនឹងចេញពីនាវាការពារនឹង ខ្ញុំមករៀនអឺ!មករៀនអានាវាបណ្តែត ។ អាពេលខ្ញុំនៅនាវាការពារ ខ្ញុំជាអ្នកប្រយុទ្ធ គឺអឺ! បុគ្គលិកកាំភ្លើង៣៧ ។ ក្រោយមកទៀត នៅពេលដែលខ្ញុំចេញពីនាវាការពារមកនៅអាបណ្តែត ហើយខ្ញុំ មុនដំបូងខ្ញុំមករៀនខាងត្រីវិស័យ ។ ដល់ពេលក្រោយមក ខ្ញុំរៀនបើកបរ យើងរៀនត្រីវស័យ រៀនដែនទី រៀនបើកបរជាមួយគ្នានឹង ។ ហើយពេលដែលឆ្នាំនឹងយើងមានហេតុការណ៍មួយដែលគួរឲ្យយើងចាប់អារម្មណ៍នៅឆ្នាំ ដែលយើងចូលឆ្នាំ៧៧ណា យើញមានបញ្ហាមួយដែលគួរឲ្យចាប់អារម្មណ៍នៅក្នុងអង្គភាពដូចគ្នានឹង ។ ឆ្នាំ៧៥យើងមានអឺ!អង្គភាពចំរុះទៅពីបូព៌ានឹង ខ្ញុំនិយាយទៅកន្លែងនឹងវាំរំលងបន្តិច ។ អង្គភាពចំរុះទៅពីភ្នំពេញទៅ ត្រូវរៀបអាចំរុះគ្នា ហើយនៅជាមួយគ្នា ដល់ពេលឆ្នាំ៧៧នឹង ព្រឹត្តិការណ៍នឹងរៀងដូចជាចំឡែកៗម៉េច ចំឡែកថាកម្លាំងដែលទៅពីនេះម៉ាវរសេនាធំនឹង ទៅរៀបចំរុះជាមួយគ្នានៅនោះ ។ បាទ!ឆ្នាំ៧៧នឹងដូចជាមានសកម្មភាពមួយគឺថា បើយើងនិយាយជំនាន់នោះគេហៅថាសកម្មភាពក្បត់ ។ ដល់អញ្ចឹងទៅ បុគ្គលិកអានៅអាម៉ារីនជាមួយគ្នានឹង ម៉ាចំនួនក៏ត្រូវដកចេញៗ ដោយសារអ្នកនោះមាននិន្នាការដែលជាប់ពាក់ព័ន្ធកម្លាំងទៅពីភ្នំពេញទៅណា ។ ហើយកម្លាំងទាំងអស់នឹងខ្ញុំឃើញថាដកទាំងស្រុង ដកចេញពីអង្គ យើងរៀបអង្គភាពចំរុះ ដល់ក្រោយមកដកចេញទាំងអស់ ។ កម្លាំងដកទាំងអស់នឹង មិនដឹងជាដកយកទៅណា ខ្ញុំក៏មិនច្បាស់ដែលកាលនឹង ប៉ុន្តែដូចជាដកយកមកអង្គភាព មួយដែលគេហៅថាអង្គភាពចល័តធ្វើស្រែធ្វើអីអញ្ចឹង ។ ហើយពេលនឹងៗយើងឃើញហេតុការណ៍នឹង ត្រង់យើងចាប់អារម្មណ៍ថា យើងគួរចាប់អារម្មណ៍ថានែក! ពីដើមយើងធ្លាប់នៅជាមួយគ្នា ញ៉ាំបាយជាមួយគ្នា ធ្វើកិច្ចការអីជាមួយគ្នា ស្រាប់ដល់មានបញ្ហាគឺថាកម្លាំងដែលទៅពីភ្នំពេញ គឺត្រូវដកចេញទី១ ដែលជាយុទ្ធជនធម្មតា ហើយមេដឹកនាំខ្លះត្រូវចាប់ឃាត់ខ្លួន ។ ដូច្នេះ អង្គភាពចំរុះគ្នាដែលត្រូវទៅនៅលើអាម៉ារីន ធម្មតាយើងរៀនបច្ចេកទេស ដល់ពេលដកកម្លាំងនឹងចេញ វាមិនត្រូវបាត់ៗកម្លាំងអត់បាន ក្នុងនាវាមួយៗអត់បាន អត់មានបុគ្គលិកជំនាយនឹងគ្រប់ៗជំនាយទេ វាត្រូវខ្វះកម្លាំង ។ បាទ! ព្រឹត្តិការណ៍នឹងមួយទៀត មានអាថ្ងៃខ្លះ ខ្ញុំផ្ទាល់នឹងត្រូវទៅយាមចាំអាម៉ារីននឹងក្នុងម្នាក់ឯង ជាអ្នកកាន់កាប់ ជាអ្នកបើកបរនឹងគឺថាមាននាវា៣គ្រឿងហើយយើង នាវា២គ្រឿងគេមិនឲ្យមានប្រេងហើយក៏មិនឲ្យមានបុគ្គលិកគ្រប់គ្រាន់ ហើយម៉ាគ្រឿងគឺយើងមានរបស់យើងនៅគឺយើងមានប្រេង គឺយើងមានការប្រើ

ប្រាសបច្ចេកទេសគ្រប់គ្រាន់ទាំងអស់ ។ ដល់ពេលនោះ ប្រហែលជាមានព្រឹត្តិការណ៍នឹងមិនមាន ការជឿទុកចិត្តគ្នា ខ្ញុំមើលឃើញដូចជា មានបញ្ហាមួយត្រង់ថាត្រូវដកកម្លាំងនឹងចេញពីនាវានឹង ទៅ លែងទុកចិត្តថាបើកាលណាកម្លាំងនៅលើនាវា អាចមានធ្វើសកម្មភាពផ្សេងៗអញ្ចឹងទៅ អានឹងតាមការសន្និដ្ឋានរបស់ខ្ញុំ ។ អញ្ចឹងពេលនោះឆ្នាំ៧៧នឹង យើងឃើញថាដូចជាមានបញ្ហា រំដើបរំជួលខ្លាំងដែរ នៅក្នុងផ្ទៃក្នុងរបស់កងទ័ព ដែលមានសមាសភាពចំរុះគ្នានឹង ។ ដល់ក្រោយ ពីនឹងស្ងប់ទៅវិញៗទៅវា កម្លាំងត្រូវរៀនត្រៀមសម្រាប់ជំនាញមួយៗនឹងបានចូលបន្ថែម លើ អាជំនួសលើអាកម្លាំងដែលដកចេញនឹង ។ ដល់បានបញ្ចូលជំនួសអាកម្លាំងដែលដកចេញហើយ ដំណើរការក៏មានធម្មតាឡើងវិញ ។ ហើយព្រឹត្តិការណ៍នឹងមកដល់ឆ្នាំ៧៨ ម៉ាឆ្នាំទៀត យើងមក ដល់ឆ្នាំ៧៨ហើយ ការហ្វឹកហ្វឺនក៏នៅតែបន្តហាត់ហ្វឹកហ្វឺនបន្តទៅទៀត ។ ហើយអឺ!ខ្ញុំ ដល់ពេល នឹងយើងហាត់ទាំងយប់ហាត់ទាំងថ្ងៃហើយ ហាក់ដូចជាមានសកម្មភាពមួយមមាញឹក ។ បាទ! ហាត់ទាំងយប់ ហាត់ទាំងថ្ងៃ រហូតដល់យើងមានសមត្ថភាពគ្រប់គ្រាន់ក្នុងការគ្រប់គ្រងនឹងកាន់ កាប់ នឹងប្រើប្រាស់បច្ចេកទេស តាមជំនាញមួយៗហើយ ។ ពេលនឹងយើងលែងបានរៀនពី ចិន ពីអីទៀតហើយ យើងរៀនគ្នាយើងធម្មតា ។ ហើយពេលនឹងសកម្មភាពដូចជាមមាញឹក ណាស់ ហើយប្រកបទៅដោយការតាមដានគ្នា ការស្រាវជ្រាវល្អិតល្អន់ម្នាក់ៗមានការប្រុង ប្រយ័ត្នណាស់ពេលនឹង ដោយសារតែមានបញ្ហាផ្ទៃក្នុងហើយតាមមើល ។ ដល់ស្ថានការណ៍នឹង ស្ងប់ទៅ ក៏យើងចូលដល់ឆ្នាំចុង៧៨នឹងមានថ្ងៃមួយ មាននាវារបស់ខ្ញុំទៅឡើងអួន ទៅឡើង បន្ទុងណា ឡើងបន្ទុង យើងឆាប យើងកោសច្រេះអី លាបថ្នាំ ។ ដល់ថ្ងៃមួយទៀត ពេល ដែលយើងលាបថ្នាំមិនទាន់បានហើយម៉ាជាន់ផង ក៏ទទួលបញ្ជាឲ្យយើងចុះពីលើអួន ចុះពីលើអា ដុក ធម្មតាគេមានដុកសម្រាប់ឡើងទៅនឹងហើយគេបូមទឹកពន្លិចទៅ ហើយឲ្យកាប៉ាល់នឹងបរចូល ទៅនឹង ចូលដល់លើនឹងហើយគេបូមទឹកចេញទៅ វាអណ្តែតឡើងហើយ ។ អញ្ចឹងដល់ថ្ងៃនឹងវា ដូចជាមិនចាំ ប៉ុនដល់ឆ្នាំអឺ!៧៨ ប្រហែលដូចជាខែ១១ ១២ អញ្ចឹងមានទទួលបញ្ជាថាឲ្យយើង ចុះៗពីលើរោងនឹង ដើម្បីទៅត្រៀមប្រយុទ្ធៗ ។ អញ្ចឹងតាមបច្ចេកទេសវាត្រូវគិតម៉ោងទៀត ក្នុងការលាបថ្នាំ ដូចថាយើងលាបម៉ាជាន់អញ្ចឹងហើយ ប៉ុន្មានម៉ោងបានយើងអាចលាបម៉ាជាន់ ទៀតបាន ។ អញ្ចឹងពេលនឹងវាត្រូវបង្ខំឲ្យយើងលាបឆាប់ៗ ហើយបញ្ជាឲ្យចុះ ។ ដល់ពេលនឹង យើងលាបម៉ាថ្ងៃល្ងាចនឹង យើងលាប២ ៣ជាន់ ហើយចុះភ្លាម ។ ហើយចុះអញ្ចឹងយើងរត់ទៅ ចតនោះទេ អូរឈើទាលយើងចេញពីរាមទៅៗអូរឈើទាល ។ ចេញពីរាមទៅដល់អូរឈើទាល

នឹង ពួកយើងសម្រាក ថ្ងៃល្ងាចនឹងស្រាប់តែយប់ប្រហែលម៉ោង១០យប់ ស្រាប់មាននាវាម៉ាគ្រឿងនឹងរបស់យើងដែរ រត់ពីកោះរ៉ុងទៅៗសំដៅកោះប៉ុស្សី ។

ដានី ៖ ទៅកោះសី?

ទូច ៖ បាទ! ទៅកោះប៉ុស្សី ព្រោះមាននាវាមួយគ្រឿងទៅចតនៅកោះប៉ុស្សី រកនាវាដែលរត់នឹង គឺនាវាអាបណ្ដែតដូចគ្នា ដែលរត់ចេញមកពីកោះរ៉ូងទៅកោះប៉ុស្សីសំដៅទៅយកឈ្មោះតាហ៊ានៗនឹងគាត់ជាអ្នកទទួលខុសត្រូវកងនាវានឹងគឺហ៊ាន មេបញ្ជាការ ។ ទៅបាត់ម៉ាសន្ទុះស្រាប់តែពួកអានាវានៅខាងមុខ មុំកោះនឹង បញ្ចេះៗអញ្ចឹងទៅរត់ទៅខាងត្បូង រត់ទៅមុំប្រឡោគាគៀវទៅខាងត្បូងទៅ ហើយក៏បានទាក់ទងថាមានយួន កងអាម៉ារីនយួនចូលមកក្នុងដីយើងអញ្ចឹងណា ។ កងអាម៉ារីនយួនចូលមកក្នុងដីយើង ម៉ាសន្ទុះក្រោយមកក៏មានគ្រាប់កាំភ្លើងប្រយុទ្ធគ្នាឃើញកាំភ្លើងពួសូរស្នូលកាំភ្លើងស្នូលអី ។ ប្រហែលជាម៉ាម៉ោងក្រោយ ក៏មានបទបញ្ជាថាឲ្យនាវាខ្ញុំនឹងត្រូវរត់ទៅប្រកគ្រាប់ ចេញពីដែអូរឈើទាលទៅប្រកគ្រាប់នៅអា នៅដែរាម ។ ជាធម្មតាអាគ្រាប់ធំនឹងយើងមិនមែនប្រកទុកទេ កាលណាប្រកត្រូវតែត្រៀមប្រយុទ្ធហើយ អញ្ចឹងយើងគឺទៅប្រកគ្រាប់ទាំងយប់ថ្ងៃនឹង ចេញទៅប្រកគ្រាប់នៅរាមទាំងយប់ ។ ហើយយើងមើលទៅត្បូង ថានៅរាមអញ្ចឹងយើងមើលទៅត្បូងទៅយើងឃើញថាបាញ់តគ្នា កាំភ្លើងបាញ់ទៅបាញ់មកៗនឹង ។ ទាល់តែយប់ជ្រៅមែនទែនបានមាននាវាយើងរបួសធ្ងន់ណាស់ ។ នាវាមួយគ្រឿងរបួសធ្ងន់ ហើយមនុស្សនឹង មិនដឹងជាស្លាប់ប៉ុន្មានទេ ប៉ុន្តែស្លាប់ច្រើន ។ ហើយម៉ាគ្រឿងទៀតទៅជាមួយគ្នា គឺលិចនៅកន្លែងនឹងម៉ង ។

**កាសែ្សតទី១ ផ្នែក«ខ»**

ទូច ៖ ពេលនឹងបានយើងដឹងថាដូចជា គិតថាហេតុការណ៍ដែលកើតនេះដូចជាទាន់ហាន់ពេកណាវៀងៗដូចជាមានាករគិត មានការព្រួយបារម្ភច្រើនថា ដល់ពេលនឹងបានយើងដឹងថាកងទ័ពនាវាចំបាំងរបស់យួននឹងវាយចូលមកស្រុកខ្មែរយើង ។ ដល់លុះព្រឹកឡើងៗថ្ងៃម៉ោង៧ ៨នឹងឃើញថាយើងប្រុងរៀបចំកម្លាំងទៅប្រយុទ្ធ ទប់ទល់ជាមួយនាវារបស់ខ្លួននឹងទៀត ។ ហើយក្នុងនឹងក៏មានព្រឹត្តិការណ៍មួយទៀត គឺកងទ័ពរថក្រោះរបស់យួន ឡើងរហូតមកដល់ឃ្លាំងលើ ឡើងពីតាមពត៌មានថាឡើងពីផ្ដាក់កំពតនេះៗ រត់រហូតទៅដល់ឃ្លាំងលើ ទៅបាញ់គ្នាជាមួយពួកយើងនឹងនៅឃ្លាំងលើ ហើយព្រមពេលជាមួយគ្នានឹង រួមមានយន្តហោះ មានទម្លាក់គ្រាប់បែកដែរទម្លាក់គ្រាប់បែកនៅមន្ទីរកងពលយើងនឹង ។ ហើយដល់ស្អែកឡើងក៏រំលងមួយយប់នឹង ស្អែកឡើងទទួលបញ្ជាឲ្យយើងទាំងអស់គ្នាឈប់ប្រយុទ្ធ ឈប់អីទៅ ថាឲ្យទៅកោះកុង ។

ដានី ៖ ទៅកោះកុង មិនមែនទៅដល់ទីរួមខេត្តកោះកុង?

ទូច ៖ មិនមែនទៅដល់ អានឹងយើងហៅថាកោះកុង យើងមិនមែនទៅឯកោះកុងទីរួមខេត្តទេ យើងទៅព្រែកត្រពាំងរូង១ ។ ពេលទៅដល់នឹងយើងនៅចតខាងក្នុងកោះកុង យើងអត់ទាន់ទៅណាទេ នាវាយើងគ្រប់ធន់ទាំងអស់នៅមូលគ្នានៅខាងក្នុងកោះកុងនឹង ស្រាប់ក៏មានបញ្ជាមួយទៀត ថាឲ្យនាវារបស់ខ្ញុំនឹងវិលត្រឡប់មកកំពង់សោមវិញ១ មកនៅម៉ុស្ទីងហាវ ។ នៅស្ទឹងហាវក៏មានព័ត៌មានពីកោះ១ថាមាននាវាយួននៅពីខាងកើតកោះរ៉ុងនឹងច្រើន ហើយក៏ទទួលបញ្ជាថាឲ្យទៅមើល១កម្លាំងរបស់យួនវាទៅណាមកណា នាវាគេនឹងទៅណាមកណា យើងក៏ខាងខ្ញុំនេះក៏ចាប់ផ្តើមគូរទិសដំណើរ គូរផ្លូវអី១ចេញពីស្ទឹងហាវនឹងដើម្បីពិនិត្យមើល ។ ប៉ុន្តែពេលដែលយើងទៅនឹងនាវាយើងប្រដាប់ដោយគ្រាប់បំពាក់កាំជ្រួចនឹង១ហើយ១ ។ បាទ! ចែដន្យយើងមានតែ២គ្រឿងនឹងទេ អត់មានច្រើនគ្រឿងទេ ព្រោះនាវាយើងទាំងអស់នឹងទៅកោះកុងទាំងអស់ហើយ អញ្ចឹងត្រឡប់មកវិញមានតែ២គ្រឿងទេ ។២គ្រឿងនឹងមានតែអាបណ្តែតដូចគ្នាតូច១នឹងហើយ យើងដល់ពេលចូលទៅប្រយុទ្ធនាវាមួយទៀត គេអត់មានគ្រាប់ទេ មានតែរបស់ខ្ញុំទេ ។ បានមានរបស់ខ្ញុំអញ្ចឹង ពេលដែលយើងចូលទៅ១ពេលប្រយុទ្ធនឹង វាមិននឹកស្មានថាយើងមានអានាវាតូច១នឹងហ៊ានចូលទៅប្រយុទ្ធជាមួយវាដែរ ព្រោះវា១ធម្មតាវាធំ១ហើយវាមានអាវុធច្រើន ។ អញ្ចឹង ពួកខ្ញុំក៏ពេលដែលទៅ២គ្រឿងនឹង វាមិននឹកស្មានថាយើងចិត្តដាច់អញ្ចឹងទេ ។ បាទ!ដល់អញ្ចឹងយើងចូលទៅដូចជាចៃដន្យវានៅមូលគ្នាទាំងអស់ បាទ!អាធំ១របស់វានឹងនៅចតទន្ទឹមគ្នា ហើយមានអាតូច១ចតជាមួយអាធំ ។ ដល់ពេលយើងទៅដល់ យើងមើលតាមរ៉ាដាយើងឃើញ ដល់យើងមើលទៅរ៉ាដាឃើញវាអញ្ចឹង យើងក៏ដាក់ទិសដំណើរយើងឲ្យចំ យើងរត់ប្រហែលជា៥នាទី ១០នាទី ក៏មើលឃើញនឹងភ្នែក ។ មើលឃើញនឹងភ្នែកយើងទៅដល់បើកសំរុកចូលទៅបាញ់ម៉ង ។ បាទ!ដល់បើកសំរុកចូលទៅបាញ់អញ្ចឹង ករណីដែលទាន់ហន់នឹងឃើញថាវា១ដូចជារៀងស្ងន់វាដែលណា យើងបើកសំរុកទៅឃើញអញ្ចឹងវាស្ងន់វាដែរ ។ អាតូច១វានាំគ្នាបែកគ្នាអស់ទៅ ហើយអាធំ១២នឹងវាមានទាន់ទៅណា អញ្ចឹងដល់ពេលយើងចូលទៅដល់យើងបាញ់១២គ្រាប់ តែខុសម៉ាគ្រាប់ត្រូវម៉ាគ្រាប់ ។ ពេលដែលយើងបាញ់ចេញផុតហើយយើងបត់ក្បាលមកវិញនឹង យើងមានស្លាប់ម្នាក់ត្រូវក្បាល ហើយម្នាក់នឹងក៏ត្រូវនឹងគ្រាប់បេសេអាអញ្ចឹង ហើយគាត់មានកាំភ្លើងកាន់នឹងដៃ ហើយគាត់ដួរទៅក្រោយទៅវាវាលដៃនេះ ក្រោយមកវាផ្ទាតអាគ្រាប់គាត់នឹងមកត្រូវជើងអ្នកបើកបរម្នាក់ហើយអាម៉ាស៊ីននឹងម្នាក់ ។ ដល់ពេលនឹងមានរាយការណ៍ពីកោះរ៉ុង អ្នកនៅលើកោះនឹង ព្រោះយើងនៅលើកោះអត់ទាន់

ដកទេកាលនឹង ប្រាប់ថារបស់វាអាកាប៉ាល់វាអាធំបាត់មួយហើយ នៅមួយ ៗ របស់វាបាត់មួយមើលអត់ឃើញអាមួយនឹងដឹងទៅណា ឃើញតែមួយទេ ៗ ប៉ុនកាលពិតនៅពេលដែលយើងបាញ់អានឹងត្រូវទៅវាលិចមួយ ហើយវានៅមួយ វាលិចមួយ ៗ ព្រោះគ្រាប់នឹងកាលណាត្រូវដឹងថាលិចហើយ អត់មានជួយសង្គ្រោះអីទាន់ទេ ៗ ហើយពេលដែលយើងបាញ់ហើយយើងត្រឡប់មកដល់ខែ ស៊ីងហាវយើងយកសពយកអីទៅបញ្ចុះហើយអីហើយ ៗ ហើយកម្លាំងម៉ាចំនួនទៀតយកទៅដាក់នៅជិតស្រែអំបិលអញ្ចឹងទៅ ខ្ញុំនៅសល់គ្នា៥នាក់បើកអាម៉ារីនទៅកោះកុង ៗ ពេលនឹងអឺ!យើងទៅដល់កោះកុង យើងរស់នៅរបៀបជាចាប់ផ្ដើមមានអាវុធចែកគ្នាហើយ ចាប់ផ្ដើមមានគេយកអាវុធយកមកចែកហើយៗ កាប៉ាល់យើងដូចជាគ្រាន់ថាមើលថែនាអាយនឹង លែងដូចថាវាលែងសំខាន់ហើយ រួចយើងចូលទៅដល់ព្រៃកត្រពាំងរូង យើងយកទៅចតចោលនឹង ដូចអត់មានន័យអីទៀតទេ ៗ អញ្ចឹងចាប់ពីខែ ការប្រយុទ្ធគ្នានឹង ជាមួយកងទ័ពយួននឹង នៅពេលដែលយើងចប់ពីប្រយុទ្ធក្នុងទឹកនឹងទៅ គឺចប់តាំងពីថ្ងៃដែលខ្ញុំចេញកាប៉ាល់មក ៗ ចេញទៅចូលទៅក្នុងដៃ អឺ!ចូលទៅក្នុងព្រៃកដល់ចូលក្នុងព្រៃក យើងគ្រាន់មើលថែទាំអីនាយអាយប៉ុននឹង លែងប្រើប្រាស់ហើយ ៗ ដល់នឹងចាប់ផ្ដើមទុកអាម៉ារីនអញ្ចឹង យើងទៅប្រយុទ្ធម្ដង គ្រាន់ឲ្យអ្នកមើល នៅថែម្នាក់អីអញ្ចឹងៗទេ!យើងទៅប្រយុទ្ធ ៗ រហូតដល់ថ្ងៃខែមេសាឆ្នាំ៧៩នឹង គឺថាយើងយកអាម៉ារីនទាំងអស់នឹងយកទៅកម្ទេចចោល យកទៅដុតបំផ្លាញយកទៅបំផ្ទុះអីឲ្យវាលិចទឹក លិចអីវា យើងលែងប្រើ យើងចាប់ផ្ដើមចូលព្រៃតាំងពីពេលនឹង ៗ

ដានី ៖ បាទៗ អញ្ចឹងពូខ្ញុំចង់មកកន្លែង ដូចឆ្នាំ៧៩នឹង ដូចថាកាលយើងកាលជ្រើសរើសឲ្យចូលទៅរៀនក្នុងកងម៉ារីននឹង គេជ្រើសរើសយ៉ាងម៉េខ្លះទៅ ដូចថាមានពូៗថាមានកងចំរុះ?

ទូច ៖ បាទ!ចះ សមាសភាពចំរុះគ្នានឹង ទី១កងពលទី៣នឹង ជាកងពលធំដែលឈរជើងនៅនឹង ហើយខ្ញុំយកកម្លាំងពី ទៅពីភ្នំពេញទៅនឹង ដែលជាអង្គភាពមកពីៗភូមិភាគបូព៌ានឹងម៉ាវរសេនាធំ ៗ បាទ!យកទៅចំរុះចូលគ្នានៅអាកងជើងទឹក ចំរុះចូលគ្នាទៅរៀនចបញ្ចូលគ្នាទៅមានអា៣វរសេនាតូច ៗ

ដានី ៖ មាន៣វរសេនាតូច?

ទូច ៖ អឺ!១៨១ អឺ!៣អី ៤នោះ ៗ

ដានី ៖ ៤ហោ៎?

ទូច ៖ បាទ!១៨១ ១៨២ ១៨៣ ១៨៤ ៗ

ដានី ៖ អឺ!ដល់ពេលកងវរសេនាធំឈ្មោះអីទៅ?

ទូច ៖ ឈ្មោះសារឿន ។

ដានី ៖ បាទ!ប៉ុន្តែអានឹង១៨០?

ទូច ៖ បាទ!១៨០ អានឹងលេខ១៨០ ។

ដានី ៖ ១៨០ ប្រធានឈ្មោះសារឿន អញ្ចឹង?

ទូច ៖ ទេ!ដូចអត់មាន១៨៤ទេ នឹងរកនឹកមិនឃើញទេ ភ្លេចអានឹងបន្តិចដែរ ដូចជា៨អញ្ចឹងបើតាមមើល បាទ!បងសារឿន ។

ដានី ៖ សារឿនតែម្នាក់ទេ អ្នកទទួលខុសត្រូវ?

ទូច ៖ បងសារឿន បងសេង ។

ដានី ៖ ឈ្មោះសេង ។ ចុះ១៨១ ពីណាគេ?

ទូច ៖ ១៨១ បងមឿន ។

ដានី ៖ ៨២?

ទូច ៖ ៨២ដូចជាតាវ៉ែន ។

ដានី ៖ វ៉ែន ។ ៨៣?

ទូច ៖ ខ្ញុំអត់ច្បាស់ ៨៣ ៨៤នឹងដូចមិនច្បាស់ មិនដឹងជាសាង ដូចមានឈ្មោះសាងមួយ ។

ដានី ៖ ៨៤?

ទូច ៖ អឺ!មិនដឹងច្បាស់ទេ ។

ដានី ៖ ចុះពូមានប្រសាសន៍ថា មេបញ្ជាការឈ្មោះហ៊ន?

ទូច ៖ អឺ!បងហ៊ននឹង អានឹងគាត់ប្រហែលជានៅ៨២ ឬ៨១ ៨៣មិនដឹងទេ ខ្ញុំភ្លេចទៅ ហើយបន្ទាប់មកគាត់បានឡើងទៅជាវរសេនាធំ១៨០នឹង ។

ដានី ៖ បាទ! ៨៤នឹងពីណា?

ទូច ៖ ៨៤រកនឹកអត់ឃើញ កាលដែលៗគេដែលនិយាយអញ្ចឹងទេ?

ដានី ៖ បាទ!អញ្ចឹងដែរ ។

ទូច ៖ ប៉ុនមានដល់៨៤អញ្ចឹងដែរ?

ដានី ៖ បាទៗគេថា៨៤ឈ្មោះហ៊ន ។

ទូច ៖ អូ!អញ្ចឹងហ៊នហើយអញ្ចឹងហើយ នឹងហើយ ។

ដានី ៖ កាលនឹងពូនៅក្នុងកងណា?

ទូច ៖ ខ្ញុំនៅ៨១ ។

ដានី ៖ នៅខាង៤១ៗ កាលនឹងពូខាង?

ទូច ៖ ខ្ញុំនៅអឺ!ជាមួយអឺ!មេនឹង នៅជាមួយអាបង់រីមនឹង ជានារសា ។

ដានី ៖ បាទ!ជានារសាគាត់?

ទូច ៖ ខ្ញុំការពិតមិនមែននារសាទេ ខ្ញុំជាកងពិសេស ដល់ពេលគាត់ស្រឡាញ់ទៅវាដូចទៅនៅជាមួយនារសារបស់គាត់អញ្ចឹងទៅ ហើយជាប់រហូត ។ ទៅបែកពីគាត់ដោយសារខ្ញុំទៅនៅរៀនអាពេលចុងក្រោយ ខ្ញុំទៅនៅអាបណ្ដែតនឹង អានឹងចាប់ផ្ដើមបែកគ្នាហើយ ។

ដានី ៖ ប៉ុនដំបូងនៅជាមួយគាត់?

ទូច ៖ បាទ!នៅជាមួយគាត់ ។

ដានី ៖ ដូចថានៅយើងនៅជាមួយគាត់ ដូចថាអត់ អញ្ចឹងយើងធ្វើការងារខាងអីទៅ?

ទូច ៖ យើងថាជាអង្គរក្សគាត់ផង សម័យនឹងគេហៅនារសាៗផង ប៉ុន្តែគាត់ត្រូវប្រើឲ្យយើងទៅនៅអង្គភាពណា ទៅធ្វើអីនៅណា ជាភ្នែក ជាច្រមុះឲ្យគាត់អញ្ចឹងទៅណា ។

ដានី ៖ អញ្ចឹងក្នុង១៨១ ១៨២ ១៨៣ ១៨៤អីនឹង ដូចថាយើងមានកាប៉ាល់ដូចថាកាប៉ាល់នឹងក្នុងម៉ានឹងកាប៉ាល់ប៉ុន្មានទៅ?

ទូច ៖ យើងអត់កំណត់អញ្ចឹងទេ ហើយវាមានអង្គភាពនឹងវាមានចំរុះគ្នា ប៉ុន្តែ១៨១នេះ មុនដំបូងវាមានអឺ! មុនដំបូងគេរៀបដូចថា ១៨១អញ្ចឹងមានម៉ាគ្រឿងអញ្ចឹងទៅ ។ ប៉ុនដល់ក្រោយមកវាទៅជាចំរុះគ្នា គេអត់គិតអង្គភាពអញ្ចឹងទេ គេគិតតែជ្រើសរើសសមាសភាពចំរុះ ហើយបានគេរៀបចំអឺ!ដូចជាអង្គភាពអាម៉ារីនមួយទៅវិញ បាទ!លែងទទួលខុសត្រូវតាម ។

ដានី ៖ ប៉ុន ចុះកាប៉ាល់ការពារមាននៅក្នុងវរៈ៤១ ៤២ ៤៣ ៤៤នឹងដែរអត់?

ទូច ៖ មានទាំងអស់ ប៉ុនដល់ក្រោយមកវាមាន៨គ្រឿង អញ្ចឹងវាមានសមាសភាពចំរុះលែងជារបស់៤១ ៤២ ៤៣អីហើយអានឹង ហើយកងវរៈនឹងក៏មិនមែនៗនៅក្នុងអឺ!ទទួលខុសត្រូវនៅនឹងទៀតដែរ វាដូចជាដាច់ដោយឡែកមកកងអាម៉ារីនតែម្ដង ។

ដានី ៖ អញ្ចឹងពូនៅនារសារបស់គាត់រយៈពេលប៉ុន្មានដែរ?

ទូច ៖ ខ្ញុំនៅតាំងពី៧៥ ។

ដានី ៖ ៧៥ដល់៧០ប៉ុន្មានទៅ?

ទូច ៖ ពី៧៥រហូតដល់៧៨ ។

ដានី ៖ ដល់៧៨ហ៎?

ទូច ៖ អឺ!

ដានី ៖ អញ្ចឹងកាលនឹងពូនៅនារសាគាត់អញ្ចឹង ពូអត់មានតួនាទីនៅក្នុងកាប៉ាល់កាន់ខាងកាំភ្លើងខាងអី?

ទូច ៖ បាទ!អានឹងពេលដែលខ្ញុំទៅ មានតួនាទីទើបទៅនៅលើអាម៉ារីន អានឹងខ្ញុំចំណុះនៅក្នុងអាម៉ារីននឹងទៅ រួចយើងជាអង្គភាពចាស់ យើងនៅក្នុងអង្គភាពចាស់គឺជានារសា ។ ប៉ុនដល់កាលណាយើងទៅនៅអាម៉ារីនក្រោមការដឹកនាំរបស់ក្រុមគេមួយទៀត ។ ដល់ធ្វើរបៀបនឹងយូរប្រហែលជិតម៉ាឆ្នាំមក ដូចជាមានការលំបាក គេកាប់ដាច់ ឲ្យថាទៅនៅអាម៉ារីន ក្រោមការគ្រប់គ្រង Direct ផ្ទាល់ជាមួយមេដឹកនាំវរសេនាធំ១៨០នេះ គ្រប់គ្រងដោយកងម៉ារីននឹង ។ បាទៗ គេលែងឲ្យយើងនៅក្នុងអង្គភាពណាៗ អានឹងគ្រប់គ្រងផ្ទាល់ Directពីអា ។

ដានី ៖ បាទៗ ប៉ុនដល់ពេលពូចែកមកអញ្ចឹងហើយ ដល់ពេលយើងរៀនៗទៅអីនឹង យើងមានវរមានអីត្រឹមត្រូវហើយ ពេលដែលយើងចូលរៀន ហាត់ជាមួយគ្រូចិនអីនោះ?

ទូច ៖ បាទ!អានឹងដូចជាអង្គភាពចំរុះមកពីនេះ មកប៉ុន្មានអង្គភាពនេះប៉ុន្មាន អង្គភាពនោះប៉ុន្មានអញ្ចឹងគេយកមក សមាសភាពគ្រប់អង្គភាពចំរុះគ្នា ហើយមកនៅនាវានឹងតាមការស្រង់ឈ្មោះផង ។ វាមិនចំពោះអ្នកណាៗទេ បើមេដឹកនាំគេឲ្យអ្នកនេះនៅត្រង់នេះៗ ប៉ុនបើកូនចៅគឺថាគេសមាសភាពចំរុះស្រេចតែគេ រៀប មានListឈ្មោះថាឈ្មោះណាត្រូវទៅនៅជាមួយអ្នកណាៗ នៅអាម៉ារីនណាអីអញ្ចឹង លេខប៉ុន្មានអីអញ្ចឹង ហើយគេអាចផ្លាស់ប្តូរគ្នាបានតាមអី!នាវាៗមានជំនាញដូចគ្នា ឧបមាថាជំនាញវ៉ាដាគេអាចត្រូវផ្លាស់ប្តូរគ្នាអញ្ចឹងបាន ជំនាញកាំភ្លើងអាចផ្លាស់ប្តូរគ្នាបានជំនាញម៉ាស៊ីនអីផ្លាស់ប្តូរគ្នាបាន អញ្ចឹងគេមិនកំណត់ទេ ។

ដានី ៖ បាទ! ចុះដល់ពេលយើង គេបែងចែកយើងហ្វឹកហាត់ហើយ ពេលដែលយើងចេញល្បាត ដូចថានាវាមួយៗអញ្ចឹងល្បាតនៅតាមទិសដៅយ៉ាងម៉េចៗ?

ទូច ៖ អានឹងជាបញ្ហាមួយទៀត ជាធម្មតាល្បាតនឹងគឺថាទី១គេពឹងផ្អែកលើវ៉ាដាដែលមានស្រាប់នៅលើបូកគោនៅលើកោះតាង នៅលើកោះកុង ។ ហើយទី២ទៀត គេពឹងផ្អែកទៅលើអានាវាសេសសល់ពីអាមេរិចនៅអាពួកPGF ។ តែដល់ឆ្នាំ៧៨ ដូចថាដើម្បីឲ្យវាទាន់សភាពការណ៍នឹង ហើយម្យ៉ាងទៀត យើងអាចម្ចាស់ការបាន យើងចង់និយាយថាយើងអាចគ្រប់គ្រងបច្ចេកទេសបានមានទាំងវ៉ាដា បញ្ចូលគ្នាទាំងអាម៉ារីនយើង បញ្ចូលគ្នាអីទាំងអស់អញ្ចឹងទៅ ហើយពួកអាម៉ារីនក៏មានចប់ពីការរៀនសូត្រ ហើយត្រូវប្រចាំការណ៍ ខ្លះនៅកោះតាង ខ្លះនៅកោះរ៉ុង ខ្លះអូរឈើទាល ខ្លះនៅស្ទឹងហាវអញ្ចឹងណា ។ បាទ!គេបំបែកគ្នា ប្រចាំការណ៍អញ្ចឹងទៅ ដល់ហើយការធ្វើនឹងបើនាវានានៅប្រចាំការណ៍ណា អ្នកនឹងឲ្យគេទៅមុខសញ្ញានឹងទៅ ដូចនៅកោះតាងអញ្ចឹងគេមើលមុំកោះតាងអញ្ចឹងមក អ្នកនៅកោះរ៉ុងមើលមុំកោះរ៉ុង កោះកុងម៉ង ។

ដានី ៖ ចុះពូកាលនឹងនៅកោះតាង?

ទូច ៖ ខ្ញុំនៅតែអូរឈើទាល ។ ជាធម្មតានាវារបស់ខ្ញុំដូចយើងថាវានៅប្រចាំការណ៍តែកន្លែងដែលមេៗ គេមានការជឿទុកចិត្តអីសម្រាប់ប្រើអីទៅណាមកណាជាមួយមេអញ្ចឹងទៅណា ។ ដូចថាមិនសូវទៅប្រចាំការណ៍ណាឆ្ងាយទេ ច្រើនតែនៅប្រចាំការណ៍កន្លែងរួម ។

ដានី ៖ ប្រចាំការណ៍កន្លែងរួម?

ទូច ៖ បាទ!អានឹងរួមដូចថាប្រចាំការនៅអូរឈើទាលអញ្ចឹងណា គេអត់សូវឲ្យយើងនៅទៅនៅប្រចាំការណ៍នៅកោះនេះកោះនោះអីយើងបានទៅម្ដងកាលទេ បើភាគច្រើននៅកន្លែងទីបញ្ជាការ ។

ដានី ៖ កាលជំនាន់នឹងកំពង់ផែមានប៉ុន្មានកន្លែងទៅ ផែរបស់គ្រប់គ្រង?

ទូច ៖ ផែដែលគ្រប់គ្រងដោយកងអាម៉ាវីននឹងម៉ង អឺ!មាននៅកោះរ៉ុង ហើយអឺ!រាម អូរឈើទាល ហើយអឺ!ផែស៊ីងហាវកំពង់ធ្វើ ។

ដានី ៖ ផែស៊ីងហាវ កំពង់ធ្វើ?

ទូច ៖ បាទ!កំពង់ធ្វើនឹង ។

ដានី ៖ មាន៤ផែនឹង?

ទូច ៖ បាទ!៤ផែនឹង ។

ដានី ៖ ប៉ុន្តែកាប៉ាល់ច្រើនចត ចេញចូលនៅផែនណាទៅ?

ទូច ៖ ចតចេញចូល នៅអូរឈើទាល ហើយនឹងកោះរ៉ុងសន្លឹម ។

ដានី ៖ កោះរ៉ុងសន្លឹម កន្លែងប្រលោះនឹង?

ទូច ៖ បាទ!ប្រលោះហូរចូល ។ ប្រចាំការណ៍នៅនោះច្រើន រាមមកម្ដងកាល ហើយស៊ីងហាវក៏អញ្ចឹងដែរ មកតាមមិនសូវជាប់លាប់ ។

ដានី ៖ ចុះខ្ញុំឮដូចថាកាលពីជំនាន់៧៥ ដូចវាទាក់ទងនឹងព្រឹត្តិការណ៍ម៉ាយ៉េហ្គេសណា?

ទូច ៖ ព្រឹត្តិការណ៍យ៉ាងម៉េច?

ដានី ៖ ព្រឹត្តិការណ៍យើងចាប់ម៉ាយីហ្គេស ហើយមានទម្លាក់គ្រាប់បែក?

ទូច ៖ អូ!នឹង កាលនឹងខ្ញុំមានបញ្ហា ខ្ញុំមានជម្ងឺ កាលនឹងខ្ញុំអឺ!ដើរយប់វាយើងធ្លាក់អណ្ដូង យើងដូចថាដើរងងឹត ចុះធម្មតាមានដើរងងឹតវាធ្លាក់អណ្ដូងៗដូចថាវាជម្រៅប្រហែលជាម៉ាម៉ែត្រកន្លះអីនឹងណា ដល់យើងធ្លាក់ទៅវាកល់អាទ្រូង ហើយយើងចេះដើរទៅយើងមានដឹងអណ្ដូងណា ដើរៗទៅវាអត់មានប៉ះអាចម៍ដី ប៉ះអី បើប៉ះអាចម៍ដីមានអី ។ ប៉ុន្តែដូចថាគេជីកគេចោលអាចម៍ដីទៅខាងនោះទៅ ហើយយើងដើរពីនេះទៅវាមានប៉ះអាចម៍ដីអី ស្រាប់តែផុតដីធ្លាក់ផ្លុក ។ ធ្លាក់ទៅ

វាកល់ទ្រូងនេះនឹងណាទៅនឹងដីជ្រុងម្ខាងទៀត ធ្លាក់ទៅដួរស្ងាត់មាត់នឹង ដួលចុកដកដង្ហើមអត់រួច អីអត់រួចទាំងអស់ ណែនរហូតដល់បាន៣ ៤ខែ ៥ខែក្រោយមក វាចេះក្អកធ្លាក់ឈាម អញ្ចឹង ខ្ញុំដេកពេទ្យ។ ពេលដែលចាប់បានម៉ាយ៉ាហ្គេសនឹង ខ្ញុំនៅពេទ្យទេ ពេលចាប់បានម៉ាយ៉ាហ្គេស នឹងយកមកចតនៅខាងត្បូងឆ្នេរអូរឈើទាលនឹង ទៅម្តុំកោះបុស្សីកោះតាគៀវអីនឹង ខ្ញុំដឹង ប៉ុន្តែ ខ្ញុំ។

ដានី ៖ ពូមើលឃើញដែរ?

ទូច ៖ បាទ! ខ្ញុំនៅដេកពេទ្យ នៅសម្រាកពេទ្យនៅម្តុំ ពេទ្យយើង គេហៅពេទ្យសព្វថ្ងៃនឹង។

ដានី ៖ ពេទ្យនៅកំពង់សោមសព្វថ្ងៃនឹង?

ទូច ៖ បាទ!គេហៅពេទ្យចំការចេក។

ដានី ៖ ពេទ្យចំការចេក?

ទូច ៖ បាទ!ហើយអឺ! ពេលនឹងមានយន្តហោះទម្លាក់នៅដៃ មានយន្តហោះទម្លាក់នៅរាម យន្តហោះ ទម្លាក់នៅតារាងកាប៉ាល់ហោះនឹង ខ្ញុំក៏ដឹងដែរ។ ប៉ុនគ្រាន់ពេលនឹងយើងកំពង់មានជម្ងឺ ចាក់ថ្នាំ ដេកពេទ្យ។ បាទ!គ្រាន់បានដឹង ប៉ុនយើងអត់បានចូលរួមក្នុងព្រឹត្តិការណ៍នឹងទេ ហើយករណី មួយទៀត ដូចជារឿងវាយគ្នានៅកោះតាង ក៏ខ្ញុំអត់បានឃើញដែរ គ្រាន់បានដឹងថាពាក់ព័ន្ធនឹង អាម៉ាយ៉ាហ្គេស មានអាមេរិចកាំង គេមានកងយន្តហោះ កងអីវាមកទម្លាក់គ្រាប់បែកអី បាញ់ គ្នានៅកោះតាង។ ហើយមានព្រឹត្តិការណ៍មួយទៀត៧៥នឹងដែរ កងជាមួយគ្នាអន្តភាពពិសេស កាលនឹងរៀបពេលដែលវាយសំរុងភ្នំពេញ គេរៀបអន្តភាពពិសេសម៉ាអន្តភាពសម្រាប់ឡើង វាយសំរុក ចល័តហើយអញ្ចឹងអន្តភាពពិសេសនឹងទៅដល់កំពង់សោមនឹងទៅនៅអន្តភាពពិសេស នឹងដដែល លេខ៤៥០នឹង។ ដល់អញ្ចឹងទៅម៉ាចំនួនគេទៅនៅកោះតាង អឺ!គេទៅនៅកោះប៉ូឡូ វៃ។ បាទ!ហើយម៉ាចំនួនទៀត នៅពេលដែលយួនទៅវាយកោះប៉ូឡូវៃនឹង យើងក៏ឡើងកម្លាំង ចល័តទៅជួយគ្នា។នៅកោះប៉ូឡូវៃនឹង។ ប៉ុន្តែ ទី១គឺយើងថ្មី យើងអត់ដែលប្រយុទ្ធ អត់ដែល ការពារអីនៅក្នុងទឹក គឺថាយើងអត់មានជំនាញអីសោះ សូម្បីតែទឹកក៏យើងខ្លាចដែរ។ យើង ណាដែលទៅជួបទឹកសមុទ្រល្អូរល្អាវអញ្ចឹង ហើយដល់អញ្ចឹងទៅបញ្ជូនកម្លាំង ហើយខ្ញុំចេះទទួល គេអូ ស្តាប់និយាយគេអូ ថាឥឡូវចេះហើយថាឥឡូវចោះហើយ យួនវាមកដល់ណា វាទម្លាក់ វាបាញ់អាម៉ារីនយើង។ ហើយត្រូវលិច បងប្អូនយើងហែលទឹកអីអញ្ចឹង បាត់ប៉ុន្មាននាក់ស្លាប់ ប៉ុន្មានអីប៉ុន្មានអញ្ចឹង ហើយនៅលើកោះនឹងទៀតអញ្ចឹង។ វាវាយអត់ វាមានអាម៉ារីន ហើយ យើងអត់ ដល់ពេលវាទៅវាយកោះយើង អាម៉ារីនវាវាយយើង២ ៣ថ្ងៃ អន់ទៅហើយយើង

បន្ទាប់មកវាបុកឡើងគោក ឡើងលើកោះទៅ ហើយកម្ទាំងប៉ុន្មានវាវាយហើយ វាចាប់ប្រុងយកទៅស្រុកវានោះ ។ វាចាប់កម្ទាំងយើងដែលនៅលើកោះនឹងចាប់យកទៅស្រុកវា ហើយយើងអត់មានអាម៉ារីនយកទៅជួយ កាលនឹងវា ដោយសារយើងទើបនឹងចប់ទៅ ។ អានឹងក៏ព្រឹត្តិការណ៍នឹងកើតក្នុងឆ្នាំ៧៥ដូចគ្នានឹងដែរ ។

ដានី ៖ មុនម៉ាយ៉េហ្គេស ឬក្រោយ?

ទូច ៖ អឺ!ដូចជាមិនច្បាស់ត្រង់នឹង ក្នុងខែ៦ ខែ៧ ខែ៨នឹង ដូចជាមុន ឬក្រោយទេ ប្អូនឯងបានដឹងថាយ៉ាងណាដែរ ពត៌មានបងប្អូនយើង ខ្ញុំមិនច្បាស់ដែល អាកន្លែងនឹង ។

ដានី ៖ បាទ!ខ្ញុំបានដូចជាមិនសូវជាច្បាស់ដែល ដូចថាទាក់ទងនឹងម៉ាយ៉េហ្គេស នឹងអឺ! ។

ទូច ៖ ដូចជាម៉ាយ៉េសហ្គេសមុន ។

ដានី ៖ បាទ!ម៉ាយ៉េហ្គេសមុនៗ បើតាមពូចាំប្រហែលនៅខែប៉ុន្មាន?

ទូច ៖ ម៉ាយ៉េហ្គេសនឹងដូចជាខែ៦ ខែអីនឹង ។

ដានី ៖ ខែ៦?

ទូច ៖ អឺ!ភ្លៀងខ្លាំងណាស់ហើយ ខែ៦ ។

ដានី ៖ ភ្លៀងខ្លាំងកាលនឹង?

ទូច ៖ អឺ!ខែ៦ ខែ៧នឹងណា បាទ! ។

ដានី ៖ ដល់ពេលយួនចាប់បានកម្ទាំងនៅខាងយើងខាងកោះប៉ូឡូវៃនឹងក្រោយមកយ៉ាងម៉េចទៀតទៅ?

ទូច ៖ ដល់ពេលម៉ាយ៉េហ្គេសខ្ញុំដេកពេទ្យ ដល់ពេលកម្ទាំងដែលថាវាយកោះប៉ូឡូវៃនឹង ខ្ញុំដូចជាត្រឡប់ពេទ្យមកវិញ ខ្ញុំរៀនដូចនៅចាំ ស្រពេចស្រពិលដែលណា ។ ខ្ញុំត្រឡប់ពីពេទ្យមកវិញ ខ្ញុំមកនៅកន្លែងគេអូ មានអីនឹងទាក់ទងគ្នានឹង ពាក់ព័ន្ធនឹងកម្ទាំងដែលយួនចូលចាប់ចូលអីអស់នឹង ។ កាលពិតទៅដល់ពេលនោះយើងបោះបង់អាកោះនោះចោលយើងអត់មានបានការពារអីយើងអត់ទាន់មានអាម៉ារីនសម្រាប់ប្រយុទ្ធ ហើយយើងអត់ទាន់មានសមាសភាព ។ អញ្ចឹងក្រោយមកទៀតពេលនឹងដែលមានតាមពត៌មានព្រះមហាក្សត្រទៅចរចាជាមួយយួន ពាក់ព័ន្ធនឹងរឿងនឹងសុំដូរឲ្យយួនដកចេញពីកោះ ហើយសុំប្រគល់កម្ទាំងដែលយួនចាប់ទៅប៉ុន្មានមកឲ្យខ្មែរវិញ ។ដល់អាពេលប្រគល់ វាដូចជាចូល៧៧ ម៉ាឆ្នាំ ៗដាងអីដែលនឹងទម្រាំតែវាប្រគល់យូរដែរនឹង ។ ប៉ុនកិច្ចការនឹង ខ្ញុំអត់សូវច្បាស់ទេ ដូចជារឿងម៉ាយ៉េហ្គេស ដូចជារឿងវាយគ្នានៅកោះតាងហើយដូចជារឿងអឺ! យួនចូលទៅយកកោះប៉ូឡូវៃ ក្រោយ ។

ដានី ៖ អញ្ចឹងដល់ពេលក្រោយមកទៀត ដូចកាលក្រោយៗមកទៀត នៅចន្លោះឆ្នាំ៧៧ ៧៨អី ពេលនឹងដូចថា ពេលដែលយើងរៀន យើងចេះ យើងមានកាប៉ាល់ ការពារដែនសមុទ្រ ពេលនឹងដូចថាខាងយួន ខាងថៃអីគេ ដូចថាពួកអ្នកនេសាទអីគេចូលមកអីយ៉ាងម៉េចៗ ពូមានចាំព្រឹត្តិការណ៍នឹងខ្លះៗអត់?

ទូច ៖ បាទ!ព្រឹត្តិការណ៍នឹងខ្ញុំបានដឹងដែរថា រូបជាធម្មតាខ្ញុំនៅដែនឹង អញ្ចឹងពេលនឹងមាន អឺ!យួនគាត់ឆ្លងទៅស្រុកថៃ នឹងខាងនាវាល្បាតនឹងមានPGF មានអឺ!នាវាការពារ មានអាបណ្ដែតអីគេចាប់បានយកមកដែ ។ ដែលក្នុងនោះឃើញអឺ!ពួកអាមេរិចកាំងមានដែរ ។

ដានី ៖ អាមេរិចកាំងមានដែរ?

ទូច ៖ មានអាមេរិចកាំងនឹងមាន៣នាក់ ។

ដានី ៖ អាមេរិចកាំង៣នាក់?

ទូច ៖ វាចូលមកស្រុកយើងនឹង៣នាក់ ដែលតាមខ្ញុំចាំ បើយួនមានកម្លាំងវាខ្លះមកស៊ើបការណ៍ ហើយកម្លាំងខ្លះ ជាអ្នករត់ឆ្លងទៅថៃ នឹងក៏យើងចាប់បានដែរ ។

ដានី ៖ កាលធ្វើយួនដែលរត់ ដែលពួកមានចំរុះមានពួកទៅថៃ ចូលមកស៊ើបការណ៍អីនឹង កាលនឹងយើងពួកច្រើនៗនឹងច្រើនកម្លាំងពួកPGF ពួកការពារ ខាងអីនឹងគេចាប់មក?

ទូច ៖ បាទ!គេចាប់មក យើងមិនមែនអ្នកទៅចាប់ទេ ទាល់ដូចខ្ញុំជម្រាបអញ្ចឹង ម៉ារីនខ្ញុំភាគច្រើននៅប្រចាំការពារក្នុងករណី ដូចថាមេគេចង់ទៅណាមកណាអី មានព្រឹត្តិការណ៍អីគេចុះទៅអញ្ចឹង គេយកយើងទៅហើយ ។ បើមិនអញ្ចឹងទេ កម្លាំងគេខាងក្រៅនឹងគេអ្នកតាមចាប់ យើងមានរៀបចំប្រព័ន្ធដូចខ្ញុំនិយាយមិញអញ្ចឹងថា ទី១រ៉ាដាតាមគោលដៅ មានរ៉ាដាកោះកុង ហើយនឹងរ៉ាដាកោះតាង ។ ដល់ពេលរ៉ាដានឹងរាយការណ៍មកឲ្យរ៉ាដាបូកគោៗបញ្ជាក់គោលដៅនឹងច្បាស់លាស់ហើយ ដឹងបញ្ជាឲ្យអាម៉ារីនដែលនៅតាមគោលដៅនឹងមក តាមមកចាប់មក ជាធម្មតាចាប់អត់ដែលរួចទេ ហើយដល់ពេលចាប់មក ត្រូវបញ្ជូនមកដែអូរឈើ ។

ដានី ៖ ជាទូទៅគេបញ្ជូនមកដែអូរឈើទាល?

ទូច ៖ មកដែអូរឈើទាល ។

ដានី ៖ ទាំងកាណូត ទាំងមនុស្ស ហើយក៏?

ទូច ៖ បាទ!យកមកទាំងអស់ ។

ដានី ៖ ក្នុងនឹងអត់មានបញ្ជូនទៅដែផ្សេង ដូចជាដែរាមដែអីអត់ទេ?

ទូច ៖ មានៗទៅដែរពមដែរ ប៉ុន្តែមិនដឹងជាចំនួនប៉ុន្មានអីប៉ុន្មានទេ ប៉ុនបើខ្ញុំឃើញថាបើកឥអាម៉ារីនភាគច្រើនក៏មកអូរឈើទាលដែរ ។

ដានី ៖ ដល់ពេលគេបញ្ជូនមកអូរឈើទាលយ៉ាងម៉េចទៅ?

ទូច ៖ យកមកអូរឈើទាលនឹង មកដល់មានឡានចាំនៅទទួលនៅដែនឹង ។

ដានី ៖ ឡានពីខាងណា?

ទូច ៖ ឡាន អានឹងឡានរបស់កងពល សម្រាប់ដឹកជញ្ជូនពួកនឹង មកដល់នឹងគឺថាគេយកឡានមកដល់ដែរមនុស្ស ឬក៏អាចយកឡានមកចាំដែរក៏ថាបានដែរ ។ មកដល់ប្រជាជនមកឡានទៅហើយដូចជាថៃក៏ដោយ យួនក៏ដោយ ហើយអាមេរិចកាំង មក៣លើកនឹងមិនដឹងជាអាមេរិចកាំងមិនដឹងជាស្អី យើងកាលនឹងយើងនិយាយថាអាមេរិចកាំងៗ មិនដឹងជាទាហាន ជនជាតិអីខ្លះ ។ ប៉ុនវាមកកាប៉ាល់នឹងខុសគេ វាមិនមែនជាទូកនៅអាស៊ីយើងនេះទេ ជាទូក ។

## កាស្សែតទី២ ផ្នែក«ក»

ទូច ៖ អានឹងវាយើងមើលឲ្យមែនទែនទៅវាដូចជា មិនមែនទូកនៅអាស៊ីយើង ប្រើទូកម៉ាស៊ីនធម្មតាទេ ម៉ាស៊ីនវាក៏ទំនើប ហើយនែក!ទូកវាមានក្តោង ។ វាមក៣វគ្គ វគ្គទី១គ្នា២នាក់ ។

ដានី ៖ ជិះ២នាក់ រៀងម៉េចទៅ?

ទូច ៖ បាទ!រៀងដូចខ្ញុំឃើញអាមេរិចកាំងមកធម្មតាអញ្ចឹង មិនដឹងថាជាអ្នកណា ។

ដានី ៖ ឆ្នាំណានឹង?

ទូច ៖ អានឹងឆ្នាំខ្ញុំដូចជា៧៧ ដល់ម៉ាវគ្គនឹងទៀត ទូកនឹងធំ ។

ដានី ៖ ក្នុងឆ្នាំ៧៧ ដែលវគ្គទី១ ប្រហែលជាខែណា ពូចាំខែ ដូចជាខែ?

ទូច ៖ ខ្ញុំមិនចាំខែ ។

ដានី ៖ ខែវស្សា ហើយក៏ខែប្រាំងមើលទៅ ចុះខែ ក៏ដើម អូ!ដើមឆ្នាំ ឬចុងឆ្នាំ?

ទូច ៖ ខ្ញុំដូចអត់ចាំទេប្អូនកន្លែងនឹង ប៉ុន្តែដឹងថាវាទាំងអស់៣វគ្គ ដល់វគ្គទី២ មានអាទូកស្រដៀងគ្នានឹងដែរ តែធំជាងគ្នារៀងស្អាតជាងគ្នាបន្តិច ស្រដៀងគ្នា ប៉ុន្តែវារៀងធំជាង ហើយស្អាតជាងមនុស្ស២នាក់ដែរ ។

ដានី ៖ ពួកនឹងស្បែកស ហើយក៏ស្បែកខ្មៅ?

ទូច ៖ ស្បែកស ។

ដានី ៖ ស្បែកសៗ?

ទូច ៖ បាទ!សៗអញ្ចឹង ។

ដានី ៖ ពូបានឃើញផ្ទាល់ភ្នែកដែរ?

ទូច ៖ បានឃើញដែរ ។

ដានី ៖ ឃើញជិតអញ្ចឹង ឬពេលណា?

ទូច ៖ បានឃើញជិត ។

ដានី ៖ ឃើញជិត?

ទូច ៖ ព្រោះជាធម្មតា អឺ!ដូចថាត្រូវឡើងពីទូកមកដើរលើដៃៗបានទៅដល់ឡាន ។ ហើយដល់វគ្គទី៣ បាននឹងបានអាចមែនទែនម៉ង វគ្គទី៣របសរបរប្រើប្រាស់ក្នុងទូកនឹង អាទូកនឹងវាវិតតែធំហើយ ដងក្តោងខ្ពស់ ហើយស្អាតណាស់ម៉ាស៊ីនក៏ស្អាត ចង្កូតស្អីៗក៏ស្អាតដែរ ទំនើបណាហើយមនុស្ស ២នាក់ដែរ ។

ដានី ៖ ២នាក់ដែរ អញ្ចឹងទូកមួយមនុស្ស២នាក់ៗអញ្ចឹង?

ទូច ៖ បាទ!

ដានី ៖ ក្នុង២នាក់នឹងសុទ្ធតែប្រុសៗទាំងអស់?

ទូច ៖ ប្រុសដូចគ្នា ។

ដានី ៖ ពូដឹងថាវគ្គទី២ប្រហែលជាឆ្នាំណា?

ទូច ៖ ដូចចន្លោះឆ្នាំ៧៧ មកឆ្នាំណា៧៨នឹង ប៉ុននឹង ៣វគ្គនឹងគឺមានប៉ុននឹង ។

ដានី ៖ យូរៗគ្នាទេ ចន្លោះពីគ្នាមួយ?

ទូច ៖ ទេ!យូរដែរ បើតាមមើល វាដូចថាបាត់៣ ៤ ៥ខែអញ្ចឹងទៅណា ។

ដានី ៖ ហើយវគ្គចុងក្រោយប្រហែលជាជិតបែក៧៩ហើយ?

ទូច ៖ បាទ!ជិតដែរ បានប៉ុន្មានថ្ងៃ បានប្រហែលម៉ាខែ ២ខែអញ្ចឹង បាទ!ទូកនឹងកាលដែលបែក៧៩ នឹង នៅនឹងនៅនឹងអូរឈើទាលនឹងណា ។

ដានី ៖ ខ្ញុំមានរូបថតមួយ ពូមើល អាចស្គាល់ដែរអត់ទូកនឹងរៀងចេះ រូបថតមួយដែលខ្ញុំកូពីចេញពី Internet? អានេះក្តោងដងក្តោងវាដែរ ។

ទូច ៖ បាទ!ទូកនឹងរៀងអញ្ចឹង ។

ដានី ៖ ទូកនឹងរៀងអញ្ចឹង?

ទូច ៖ ប៉ុនអានឹងដូចស ។

ដានី ៖ ដោយសារអានេះយើងកូពីមកវាឃើញរៀង សខ្មៅនឹងហើយ ។

ទូច ៖ ហ្នឹងហើយ ទូកនឹងអញ្ចឹងម៉ងនឹង ។

ដានី ៈ ទូកនឹងអញ្ជើងម៉ង?

ទូច ៈ បាទ!

ដានី ៈ ប៉ុន្តែទាំង៣លើកនឹង អញ្ជើងៗទាំង៣លើក?

ទូច ៈ ទាំង៣លើក អានេះស្អាតជាងគេ អាចុងក្រោយនេះ ។

ដានី ៈ អានឹងៗបើតាមពូឃើញ ទូកចុងក្រោយហើយ?

ទូច ៈ បាទ!ទូកចុងក្រោយ ប៉ុនទូកនេះខ្ញុំនៅចាំបានពេលដែលយើងចេញទៅ៧៩នឹង ក៏ទូកនឹងនៅចត ចោលនឹងដែរ ។

ដានី ៈ ចតចោលនៅណាដែរ?

ទូច ៈ ចតចោលនៅខាងមុខអូរឈើទាលនឹង ។

ដានី ៈ ខាងមុខអូរឈើទាល?

ទូច ៈ បាទ! ហើយដល់ពេលខ្ញុំមកវិញ ឆ្នាំ៩១ ក៏ទូកនឹងនៅរលក ។

ដានី ៈ នៅទំនប់រលក?

ទូច ៈ បាទ!

ដានី ៈ ប៉ុន្តែឥឡូវពូឃើញទូកនឹងទៀតដែរអត់?

ទូច ៈ ដល់ទូកនឹងខ្ញុំតាមទៅរកប្រហែលជាឆ្នាំមុន ខ្ញុំទៅឃើញនៅលើដៃ ។

ដានី ៈ ទូកនឹង?

ទូច ៈ បាទ!

ដានី ៈ ប៉ុន្តែឥឡូវនៅទៀតដែរអត់?

ទូច ៈ មុនដឹងនៅអត់ទេ ប៉ុន្តែប៉ុន្មានឆ្នាំមកនេះ ខ្ញុំធ្លាប់មានគេសួរខ្ញុំ ហើយខ្ញុំតាមរកទៅឃើញនៅខាង លិចឃ្លាំងៗដៃធំ ។

ដានី ៈ ពីណាគេតាមរក?

ទូច ៈ មានជនជាតិគេម្នាក់តាមសួររក ខ្ញុំក៏ទៅមើលអានឹងឃើញ ខ្ញុំក៏ចង់ដឹងដែរការពិតនឹងចង់ដឹងរឿង នឹងដែរ បានខ្ញុំចេះតាមមើល ។

ដានី ៈ ពូទៅតាមមើលឃើញដែរអត់?

ទូច ៈ បាទ!ខ្ញុំឃើញទូកនឹងនៅនឹង ប៉ុន្តែនៅលើគងហើយ លែងនៅដីហើយ វាដូចជាអត់ឃើញមានគេ ប្រើគេប្រាស់អីសោះទូកនឹង ហើយមនុស្សអស់នឹងដឹងម៉េច មិនដឹងដែរ ប៉ុនមានមនុស្ស២នាក់

អញ្ចឹងដូចគ្នា ទូកនឹង ហើយរបស់របរនៅលើទូកនឹងច្រើន ទំនើប ហើយហូបចុកអីក៏ច្រើនដែរ ហើយទូកនឹងម៉ាស៊ីនល្អណាស់ ។

ដានី ៖ ម៉ាស៊ីនល្អ?

ទូច ៖ ហ្នឹងម៉ាស៊ីន ដូចម៉ាស៊ីនឡានអញ្ចឹង វាអត់ព្រុ ម៉ាស៊ីនវាអត់ព្រុតិចៗ ហើយដល់ក្តោងខ្ពស់ណាស់ ខ្ពស់មែនទែនទូកនឹង ។

ដានី ៖ ចុះទូកទី១ រៀងម៉េចទៅទូកទី១?

ទូច ៖ ស្រដៀងគ្នានឹងដែរ ប៉ុន្តែវាតូចខ្ចី ។

ដានី ៖ ក្នុងទូកទី១នឹងប្រហែលជា៧៧ ប្រហែលជាដើមឆ្នាំ ប្រហែលខែវស្សា ឬខែប្រាំងដូចថាពូនៅចាំនៅពេលដែលទូកនឹងមក?

ទូច ៖ ដូចខែប្រាំងតាមមើល ។

ដានី ៖ ខែប្រាំង?

ទូច ៖ ឬក៏ចុង ដើម ចុង ។

ដានី ៖ ដូចថាកាលនឹងទឹកសមុទ្រវារលកអី មានរលក ឬក៏ស្ងប់ ឬក៏?

ទូច ៖ ដូចជាដើម៧៧ទេ ខ្ញុំមិនច្បាស់ដែលកាលនឹង ។

ដានី ៖ កាលនឹងពូមើលទៅឃើញគ្នា២នាក់?

ទូច ៖ ២នាក់ ។

ដានី ៖ ២នាក់នឹងមើលទៅដូចថាចំនាស់ៗណាដែរ?

ទូច ៖ បាទ!រៀងចំណាស់ៗ យប់ដងអានឹងយើង ជាធម្មតាមកដល់នឹងគេមិនសូវឲ្យឃើញច្បាស់គេច្រើនយកមកយប់ ។

ដានី ៖ អូ!ច្រើនយកមកយប់?

ទូច ៖ បាទ!

ដានី ៖ ប្រហែលជម៉ោងប៉ុន្មាន?

ទូច ៖ ដូចថាម៉ោង៧ ម៉ោងអីអញ្ចឹងណា ។

ដានី ៖ ម៉ោង៧?

ទូច ៖ ហើយរៀបភ្លឺតាមអាដែលពន្លឺនាវាយើងបញ្ឆេះម៉ាស៊ីនឆេះអីនឹងបើកភ្លើងបើកអីនឹង ភ្លឺខ្លះអីខ្លះបើមិនអញ្ចឹងទេ ដូនកាលក៏មកអញ្ចឹង ។ យើងអាដៃយើនមានភ្លឺឯណា បើតែអាភ្លើងយាមមួយចោលនឹង ។

ដានី ៖ អញ្ជឹងពេល ទី១មកពេលយប់ កាប៉ាល់ទី១?

ទូច ៖ ខ្ញុំបានឃើញដូចជា២ដងទេ អាទី២នឹងអាទី៣ អាទី១ដូចមិនបានឃើញ ។

ដានី ៖ ចុះអាទី២ ចុះម៉េចបានដឹងថាពូមានដឹងថាទី១ បើពូអត់បានដឹង?

ទូច ៖ បាទ!ចង់និយាយថា ទី១យើងឃើញមនុស្សផ្ទាល់ដែលគេយកចេញមកផ្ទាល់ ។

ដានី ៖ ទី១ឃើញមនុស្សផ្ទាល់?

ទូច ៖ បាទ!ទី១ យើងចង់និយាយថា អាមួយយើងឃើញផ្ទាល់ អាមួយទៀតមកយើងអាឡែងទៅនេះទៅនោះអីអញ្ជឹង យើងអត់បាន អានឹងយើងចង់និយាយថាមិនមែនចង់និយាយទី១មិនដឹងទេ យើងចង់និយាយចេះថាករណីដែលយើងឃើញផ្ទាល់ ហើយករណីដែលយើងអាឡែងធ្វើនេះធ្វើនោះ ប្រមូលនេះប្រមូលនោះអីអញ្ជឹងទៅណា ឬក៏ទៅនេះទៅនោះ នៅនេះនៅនោះអីអញ្ជឹងទៅណា ។ បាទ!ហើយករណីមួយទៀត ពេលដែលយើងនៅកន្លែងនឹងម៉ង អត់មានទៅណាទេ ឈរមើលគេ ថាគេនាំមកដល់ទូកចតដែអញ្ជឹងទៅ ហើយគេកាន់អាដៃដឹកដៃមនុស្សនាំមនុស្សឡើងឡានដើរទៅអញ្ជឹងណា ។

ដានី ៖ បើពូឃើញផ្ទាល់ឃើញ២លើក?

ទូច ៖ បាទ!

ដានី ៖ លើកទី២ ហើយនឹងលើកទី៣?

ទូច ៖ បាទ!លើកទី២ លើកទី៣ ។

ដានី ៖ លើកទី២ បើតាមពូចាំនៅខ្ទង់ឆ្នាំប៉ុន្មានដែរ?

ទូច ៖ ៧៧នឹងដែរ ។

ដានី ៖ ប្រហែលជាខែណា?

ទូច ៖ លើកទីនឹងអី!ខ្ញុំនៅនឹងអាម៉ារីនដែលខ្ញុំរៀនហើយនឹង បែបដូចជាពាក់កណ្ដាល៧៧អីនឹងដែរ ។

ដានី ៖ ពាក់កណ្ដាល៧៧?

ទូច ៖ បាទ!ទី៣ នៅរដូវចុង ដូចពាក់កណ្ដាល៧៨ហើយ ។

ដានី ៖ ពាក់កណ្ដាល៧៨?

ទូច ៖ ប៉ុនអានេះអាចុង៧៧ហើយ អាទី២ ចូល៧៨ហើយអានឹងតាមមើល ។

ដានី ៖ អានេះអាចពាក់កណ្ដាល៧៨?

ទូច ៖ ចុង៧៨ ។

ដានី ៖ ចុង៧៨ ។ ចុះចុង៧៧នេះ កាប៉ាល់នឹងមកស្ពានណា បើតាមពូចាំ?

ទូច ៖ មកយប់ដែរ ។

ដានី ៖ មកយប់ប្រហែលម៉ោងប៉ុន្មាន?

ទូច ៖ ប្រហែលជាគេយកមកដល់ដែនឹង ល្មមតែមើលគ្នាលែងស្គាល់ហើយ យប់ងងឹត ។

ដានី ៖ ចុះពូដូចថាកាលនឹងក្រុមណាដែលគេនាំមកនឹង?

ទូច ៖ ខ្ញុំដូចជាចាំអត់ច្បាស់ ពួកកោះតាងនឹងអ្នកនាំមកនឹង ។ ពួកកោះតាងគេនៅមុខសញ្ញាគេយាមម្តុំសមុទ្រក្រៅ ហើយដល់ហើយគេចាប់នាំមក ។ អឺ!ទូកនឹងគេប្រើនៅនឹងចាំងអស់ ប៉ុន្តែអានេះវាពិបាកប្រើត្រង់ថាវាធំពេក ហើយទូកទី១គេយកមកប្រើសម្រាប់ដឹកបាយ ដឹកនេះដឹកនោះសម្រាប់បំរើកងអាម៉ារីននឹង ។ បាទ!ហើយអាទី២ក៏ដូចជាមិនដឹងទៅណាទេ ទី២ដូចជាមិនច្បាស់ព្រោះវាវៀងធំបន្តិចដែរ ។

ដានី ៖ ធំប្រហែលជាធំប៉ុន្មានទៅ?

ទូច ៖ ធំៗជាងគ្នា អាទី១តូចនឹងវាប្រហែលវាមិនប៉ុន្មាន ប្រហែលធំជាងនឹងបន្តិចអាទី១ ប៉ុនគ្រាន់វាវៀងគ្រលោម ហើយវៀងខ្ពស់វា ដូចមានអាធ្វើឲ្យមានទំងន់ទៅក្រោម ដូចជាមានដែក មានស៊ីម៉ង់អីចាប់ទៅក្រោមនោះ ។

ដានី ៖ ដែលជ្រៅ ជំរៅវាជ្រៅទេ?

ទូច ៖ បាទ!

ដានី ៖ បាត ពីគែមទូកទៅបានជ្រៅ?

ទូច ៖ ជ្រៅ អានឹងវាធ្វើៗដូចមានពូកវានៅក្រោម ដើម្បីទទួលទំងន់ក្រោមកុំឲ្យឃ្លោង ប៉ះសមុទ្រលកអីខ្លាំងណា វាធ្វើការពារ ពេលដែលវាចូលសមុទ្រជ្រៅៗ ។ ហើយអាទី២វាមានអញ្ចឹងក្បាលកន្ទុយអីអញ្ចឹងដូចគ្នា ប៉ុន្តែវៀងតូចជាងនឹង ។ នេះខ្ញុំ អឺ!មើលអានេះ វាពិបាកពណ៌ ប៉ុនទឹកសមុទ្រពណ៌អញ្ចឹង ជាធម្មតាអានេះពណ៌វៀងពងមាន់ ។

ដានី ៖ អានេះពណ៌វៀងពងមាន់?

ទូច ៖ បាទ!ពណ៌វៀងពងមាន់ វៀងសៗ ។

ដានី ៖ អានេះពណ៌វៀងស អានេះពណ៌ផ្នែកខ្នងគែមទូកនេះ ពណ៌ពងមាន់?

ទូច ៖ អឺ!

ដានី ៖ អញ្ចឹងមានលេខ មានអីនៅជ្រុងកាប៉ាល់?

ទូច ៖ ទេ!ដូចខ្ញុំមិនបានចាប់អារម្មណ៍ច្បាស់ទេ ។

ដានី ៖ ប៉ុនពូបានឡើងទៅមើលក្នុងកាប៉ាល់នឹងដែរអត់?

ទូច ៖ បាទ ។

ដានី ៖ កាប៉ាល់នឹង ក្នុងកាប៉ាល់នឹងមានអីខ្លះដែរ?

ទូច ៖ គ្រឿងហូប គ្រឿងអី មានអាមួយណាទេ មានទាំងស្គរ មានទាំងឧបករណ៍ភ្លេងលេង ប៉ុនដឹង អានឹងឬមួយណា ប្រហែលជាអានឹងហើយ ។

ដានី ៖ អានឹងបើតាមពូគិតមើលទៅ អានឹងប្រហែលជាអាចុងក្រោយទេ អាកាប៉ាល់ចុងក្រោយ?

ទូច ៖ ខ្ញុំអានឹងកាប៉ាល់ចុងក្រោយ ប៉ុនអាកាប៉ាល់មុន អាដងនឹងវាអត់សូវវែងទេ វាអត់មានធំហើយ អានឹងក៏អត់មានដងខ្ពស់អញ្ចឹងពេកដែរ ។ បាទ!កាប៉ាល់ទី១ ទី២ អត់ដូចអានេះទី៣ៗនឹងបើ គិតតម្លៃទៅវាថ្លៃ ព្រោះវាល្អណា ។

ដានី ៖ ប៉ុន្តែអ្នកដែលនៅក្នុងកាប៉ាល់នឹងសុទ្ធតែជនជាតិស្បែកស?

ទូច ៖ បាទ!ជនជាតិ ។

ដានី ៖ ប៉ុននៅក្នុងកាប៉ាល់មានតែគ្នា២នាក់?

ទូច ៖ ២ ។

ដានី ៖ កាប៉ាល់ធំអញ្ចឹង ម៉េចបានគេមានតែគ្នា២នាក់?

ទូច ៖ ហ្នឹងខ្ញុំមិនដឹងដែរអានឹងវាថាយ៉ាងម៉េច ប៉ុន្តែកាប៉ាល់នឹងវាមានអី!មិនមែនជាទេសចរណ៍ឬយ៉ាង ណាទេ ខ្ញុំក៏មិនដឹងដែរ គ្រាន់ថាវា ។

ដានី ៖ ចុះក្នុងកាប៉ាល់នឹងមានខោអាវ?

ទូច ៖ មានសម្រាប់តែ២នាក់ប្រើ មានតាំងតែពីម៉ាស៊ីនថតមានអី សម្រាប់តែ២នាក់នឹងប្រើមានទាំង អស់ ស្អីក៏មានដែរគ្រឿងហូប បើយើងនិយាយទៅវាមានតាំងពីភ្លេងទៀតនោះ ។

ដានី ៖ ចុះខោអាវដូចថា ឧបករណ៍ភ្លេងស្អីក្នុងកាប៉ាល់នឹង គេយកទុកក្នុងកាប៉ាល់ដដែល ឬយកគេ ប្រមូល?

ទូច ៖ បាទ!អានឹងគេប្រមូលចេញអស់ហើយ ។

ដានី ៖ គេប្រមូលអ្នកៗម្ចាស់ទូក ថានាវីកក្រុមនាវីកនឹងគេប្រមូលទៅខ្លួនឯង ឬក៏ខាង?

ទូច ៖ អានឹងជាធម្មតាមិនមែនយើងអ្នកទៅឡើងបានទេ ទាល់តែចប់កិច្ចការគេប្រមូលចេញ គេធ្វើអី ហើយនោះ បានយើងអាចអ្នកផ្សេងទៅមើលបាន ។ ជាធម្មតាតែក្រុមការងារខ្ញុំមកមើលម៉ង ផែកនេរនឹងណា ។

ដានី ៖ ពួកកាប៉ាល់នឹងមក ឡានគេមកចាំទទួលដឹកពីអូរឈើទាលទៅដែរ?

ទូច ៖ បាទ!ដឹកពីអូរឈើទាលទៅ ។

ដានី ៖ អញ្ចឹងកាប៉ាល់ទាំង៣នឹង នៅ មកចតនៅអូរឈើទាលទាំង៣ដែរ?

ទូច ៖ បាទ!អានឹង មកចតអូរឈើទាលនឹង ។

ដានី ៖ ដឹងថាកាប៉ាល់ទាំង៣នឹង គេចាប់មកពីកន្លែងណាមក?

ទូច ៖ យកមកពីសមុទ្រក្រៅ ប៉ុនដឹងសមុទ្រម្តុំណា ប៉ុនកាល តាមខ្ញុំគិតប្រហែលៗខាងត្បូងកោះតាង អីនឹង ។

ដានី ៖ ខាងត្បូងកោះតាង?

ទូច ៖ បាទ!

ដានី ៖ ក្រុមអ្នកជូនមកនឹង ពួកអី!ក្រុមអ្នកនៅកោះតាង ឬក៏ក្រុមពួក ក្រុមល្បាតរបស់ពូ?

ទូច ៖ ក្រុមល្បាត ក្រុមពួកនាវាដែល មានតួនាទីដេញចាប់ដេញអីនឹង ។

ដានី ៖ ប៉ុន្តែពូ ក្នុងចំណោម៣នឹង ពូមានចាំអាមួយដែលក្រុម ដែលនាំមក?

ទូច ៖ អ្នកនាំមកខ្ញុំមិនដឹងច្បាស់ទេ រឿងអ្នកនាំមក ព្រោះអីយើងដឹងថាតួនាទីជាអ្នកចាប់ ជាអ្នកនៅខាងក្រៅ ហើយអ្នកបញ្ជាឲ្យនាំមកនឹង ប្រហែលបញ្ជាពីកងពលឲ្យនាំមក អ្នកនាំមកវាមិនៗដុតអាអ្នកនៅកន្លែងណាជាអ្នកនាំមកយើងអត់ដឹង ។

ដានី ៖ ហើយខ្ញុំចង់ដឹងមួយទៀត ចុះកាលដែលដូចថាពេលដែលនាំមកអញ្ចឹង យើងនាំមកជាមួយទូកយួន ទូកថៃ នាំមកច្រើនអីអញ្ចឹង ឬក៏ពេលចាប់បានចាប់មួយនាំមកមួយ?

ទូច ៖ បាទ!ៗនាំ ចាប់បានអញ្ចឹង មកមួយចាប់បានមួយមកមួយ ។

ដានី ៖ បាទ!ចាប់មកដូចរបៀបការនាំ ការដឹកអីគឺដូចៗគ្នា គេមានលក្ខណៈខុសៗគ្នា ដូចថាខាងយួនគេប្រព្រឹត្តជាមួយយួន ការដឹកការអីខុសផ្សេងជាមួយថៃ ផ្សេងជាមួយពួកបរទេសណាEurope ខាងពួកអាមេរិចកាំងផ្សេង?

ទូច ៖ អានឹងដូចជាមិនខុសគ្នាអីទេ គ្រាន់ថាតាមពត៌មានថាពួកថៃ ពួកយួនយើងដូចជាមិនទៅយកទៅណាឆ្ងាយទេ ប៉ុនមិនដឹងជាយកទៅទុកណា ឧបមាកន្លែងទុក កន្លែងនៅអីនឹង ដូចជាថៃអីពូមុនតាមពត៌មានមិនដូវការនឹងថាមានយកទៅសម្លាប់ចោលដែរ ដល់ក្រោយមកថាគេឲ្យដូចថាទៅផ្ទះទៅអី យួនអីអញ្ចឹងណា ។ កាលពីយើងនៅថៃទាក់ទងតាមការទូតបានល្អ គេបញ្ជូនទៅផ្ទះនឹងអញ្ចឹងទៅ ។ ហើយអឺ!ពួកបរទេសនេះ គឺតាមពត៌មានយកមកភ្នំពេញ ។

ដានី ៖ គេយកមកភ្នំពេញ ម៉េចបានពូដឹង?

ទូច ៖ អានឹងដូចជាធម្មតា អ្នកដែលនៅក្នុងអង្គភាពនឹងយើងស្គាល់គ្នា ម៉ាកងពលវាដូចថាបានដឹងរឿងអ្នកនៅក្នុងមន្ទីរ អ្នកនៅក្នុងអីនឹង ភាគច្រើនអ្នកស្គាល់អង្គភាពមួយគ្នានឹងណា ។ អញ្ចឹងពូពត៌

មានថាយកមកភ្នំពេញៗ  អញ្ចឹងខ្ញុំក៏មិនដឹងច្បាស់ដែរ ។  ប៉ុនពាក់ព័ន្ធនឹងពួកបរទេស  មិនមានណាយអ្នកណាមានសិទ្ធិសម្រេចក្នុងការធ្វើអីមួយទេ  រកវាត្រូវតែមកដល់ថ្នាក់ជាតិនេះ ។  មិនមែនដូចយួនដូចថៃទេ  យួនដូចថៃអាណាក៏ចេះទទួលសិទ្ធិ  ឬក៏អាចរំលោភបំពានអីបានអញ្ចឹង ។  ប៉ុនពួកនេះ  មិនមែនអ្នកណាហ៊ានវាយ  ហ៊ានទៅធ្វើអីមួយទេ ។

ដានី  :  អញ្ចឹងអត់ហ៊ានទេ?

ទូច  :  បាទ!យកមក  ដូចជាការពីដើមមកក៏មកធម្មតា  ឡើងលើឡានក៏ឡើងធម្មតាអញ្ចឹងទៅ  បានថាសម័យនឹងមិនមែនសម្រាប់ឡានតូច  ឡានអីជិះណា  មានឡានៗធំឡានអីអញ្ចឹងមកណា ។

ដានី  :  ប៉ុន្តែមកភ្នំពេញ  ខាងកងពលគេដូនមកភ្នំពេញ  ហើយក៏យ៉ាងម៉េច?

ទូច  :  បាទ!មកភ្នំពេញ  អានឹងគេមានអគ្គភាពមួយគេសម្រាប់ជូនអ្នកនាំ  អឺ!មកអញ្ចឹងអានឹងយើងមិនដឹងដែរ ។

ដានី  :  ប៉ុនពូគ្រាន់ដឹងថាគេបញ្ជូនមកភ្នំពេញ?

ទូច  :  ហ្នឹងហើយ គេបញ្ជូនមកភ្នំពេញ ។  បើពួកនឹង  បើតាមដែលខ្ញុំដឹង  ដូចអត់មានសិទ្ធិទុកនៅនឹងទេ ។

ដានី  :  ទុកនៅកន្លែងកងពល?

ទូច  :  បាទ!ទុកនៅកន្លែងកងពល ។

ដានី  :  ប្រហែលជាដូចថាកាល  ឧបមាថាពេលចាប់មកអញ្ចឹង  គេទុកក្នុងរយៈពេលមួយ  ក្នុងរយៈពេលប៉ុន្មាន  បានត្រូវគេបញ្ជូនមក  ពីកន្លែងមួយទៅកន្លែងមួយ  ឧបមាថាចាប់ពីសមុទ្រមក  គេត្រូវចាប់មកសួរនាំសិន  ឬក៏ចាប់មកភ្លាម  គេបញ្ជូនមកកងភ្លាម  ហើយកងពលបញ្ជូនមកភ្នំពេញភ្លាមអីអញ្ចឹង  ហើយក៏ម៉េច  ទុកសួរអីសិនដែរ?

ទូច  :  ហើយខ្ញុំដូចជាមិនច្បាស់  តាមមើលទៅ  ខ្ញុំស្មានដែរតាមការសន្និដ្ឋានរបស់ខ្ញុំថា  ពួកនឹងមិនទី១បើថានៅនោះមិនសូវអ្នកជំនាញ  ខាងសាកសួរខាងដេញដោលអីចេះភាសាអីអញ្ចឹង  ដូច្នេះគេប្រហែលមិនទុកយូរទេ  គេបញ្ជូនមកភ្នំពេញភ្លាមៗហើយ ។

ដានី  :  ចុះនៅកងពលអត់មានអ្នកនិយាយអង់គ្លេសទេអញ្ចឹង?

ទូច  :  មានដែរ  ប៉ុនគ្រាន់ថានេះតាមការដែលយើងគិតទៅ  គ្រាន់តែអាចវាយការណ៍សាក់សួរខ្លះៗទៅណាមកណាទេ  ទៅការទុកនឹងក៏យើងមានមើលទៅប្រហែលជាមានបទពិសោធន៍ពាក់ព័ន្ធនឹងម៉ាយ៉េហ្គេសដែរ ។

ដានី  :  យើងមានបទពិសោធន៍ពី៧៥ហើយ?

ទូច ៖ បាទ!ម៉ាយ៉ាងហ្ហេសនឹងមានបញ្ហាមួន ដូច្នេះកម្លាំងនេះ ដូចកម្លាំងក្រៅប្រទេសដែរ អញ្ចឹងគេអាច បញ្ជូនមកនេះភ្លាមៗមកយ៉ាងណាខ្ញុំមិនដឹងទេ។ ប៉ុនតាមការសន្និដ្ឋានខ្ញុំថាមកភ្នំពេញច្រើនជាង មិនដូចថៃ មិនដូចយួនអីអានឹង។

ដានី ៖ យើងមានសិទ្ធិ?

ទូច ៖ បាទ!យើងមានសិទ្ធិសម្រេចក្នុងកងពល កងអីគេយកទៅណាទៅណែមិនដឹងទេ ប៉ុនបើថាពួកនេះ តាមដែលខ្ញុំដឹងទៅ ដូចជាគេបញ្ជូនមកភ្នំពេញណា។

ដានី ៖ កាលក្រុមទី២ ហើយទី៣នឹង កាលនឹងពូនៅជិតនឹងឃើញ ពេលដែលឡានមកទទួលជនបរទេស នឹងកាលនឹងពេលដែលឡានមកទទួល អឺ!បើលើកទី៣នឹងខ្វង់ប្រហែលម៉ោងប៉ុន្មាន ដែលកាណូត មករាម មកដល់ដែអូរឈើទាល?

ទូច ៖ ខ្ញុំថាដូចជាម៉ោង៧កន្លះ ៨អីនឹង។

ដានី ៖ ៧ ៨យប់?

ទូច ៖ បាទ!

ដានី ៖ កាលនឹងពូមើលឃើញបរទេសនឹងច្បាស់ដែរអត់?

ទូច ៖ បាទ!មើលឃើញ ដូចថាខ្ញុំនៅផែសមុទ្រវាវាល ទី១នៅសមុទ្រវាវាល ហើយដូចជាមានខែភ្លឺ ឬក៏ខែងងឹតមិនដឹងទេ ប៉ុន្តែមើលបានដើរបានធម្មតា។

ដានី ៖ មើលដូចថាពូមើលឃើញមុខ?

ទូច ៖ បាទ!ព្រោះវាមាន វាមានតភ្លើង តអីពីគោកមកអញ្ចឹង យើងប្រើភ្លើង ប្រើអីអញ្ចឹងដែរ នៅ នឹងផ្ទះនឹងក៏មានភ្លើងដែរ។

ដានី ៖ ចុះពេលដែល ពេលនឹង ពេលដែលមកដល់អញ្ចឹងគេមានអ្នកខាងនេះគេមកដឹកដៃទៅ?

ទូច ៖ បាទ!គេមកនាំទៅ អូ!កាលណាទូកគេមកដល់ ភាគច្រើនដូចជាមានឡានមកចាំមុននឹងអញ្ចឹង។

ដានី ៖ អូ!ឡានមកចាំ?

ទូច ៖ គេបានរាយការណ៍មកដល់ណាៗអញ្ចឹង មានឡានគេមកចាំមុន។

ដានី ៖ មានគ្នាច្រើនអត់ អ្នកនៅក្នុងឡាន?

ទូច ៖ ឡានមិនច្រើនទេ អ្នកឡាននឹងនោះ ដូចថាមានទាហានសម្រាប់អ្នកយកចេញ ចូលអីនឹងណាមាន ទាហាននឹងមកជាមួយឡាន មានអ្នកបើកឡាន មានមេបញ្ជាការមួយអញ្ចឹងទៅ។

ដានី ៖ ចុះពួកបរទេសនឹងអត់ប្រកែក មើលទៅសភាពគេដូចក្នុង?

ទូច ៖ អត់ទេធម្មតា។

ដានី ៖ អត់ភ័យឬកគេឡូឡា?

ទូច ៖ បាទ!អត់មានឡូឡាមានអីទេ គ្រាន់មុខស្លូត គ្រាន់ថាមុខស្លូតអីមានអារម្មណ៍ថាមុខស្លូត មិននិយាយ មិនថាអី ។

ដានី ៖ ពេលមកដល់អូរឈើទាលនឹងអត់និយាយទេ?

ទូច ៖ បាទ!ដូចអត់មាននិយាយមានអី ។

ដានី ៖ ពួអត់មានពុសម្ញេនិយាយភាសា?

ទូច ៖ បាទ!អត់មានអ្នកណាទៅសួរ និយាយនៅកន្លែងនឹងទេ ព្រោះវាកន្លែងនឹងជាកន្លែងកងអាម៉ាវីន ដែលមិនត្រូវការចតអីយូរ អ្នកណាទៅធ្វើអីនឹងយូរទេ ។ ព្រោះធម្មតាទៅមានតែពួកអាម៉ាវីន ហើយនឹងអាម៉ាវីននឹងទេ ។

ដានី ៖ ចុះក្នុងចំណោមនឹង ពូមានឃើញត្រូវមួយរបួសដៃ កាលពីថ្ងៃមុនខ្ញុំជួបពូកាន គាត់និយាយថា គាត់ធ្លាប់បានឃើញបរទេសដែលត្រូវរបួសដៃ ហើយមានចងជាយដៃអាវចេះ?

ទូច ៖ នឹងខ្ញុំមិនច្បាស់ទេ ព្រោះរឿងត្រូវរបួសដូចជាយើងគិតថាយើងជួនកាលយើងមិនចាប់អារម្មណ៍ ក៏ថាបានដែរ ។ ព្រោះការពិតទៅរបួសមិនរបួសធ្ងន់ដែរ ដើរបានធម្មតាទេ ។

ដានី ៖ បាទៗដើរបានធម្មតា គ្រាន់តែរបួសសារស្បែកអីបន្តិច?

ទូច ៖ បាទ!គ្រាន់របួសអញ្ចឹង ប៉ុន្តែដើរបាន ខ្ញុំឃើញដើរដង្ហក់ ។

ដានី ៖ ចុះពួកនឹងស្លៀកពាក់ខោអាវយ៉ាងម៉េចដែរ?

ទូច ៖ ដល់ពេលនឹងស្លៀកខោត្រឹមៗនឹងហើយ ។

ដានី ៖ ស្លៀកខោខ្លី?

ទូច ៖ បាទ!

ដានី ៖ ចុះមានពាក់អាវដែរអត់?

ទូច ៖ ដូចអត់ពាក់អាវទេ មកដល់នឹង ។

ដានី ៖ អត់ពាក់អាវទេ?

ទូច ៖ ឬក៏ពាក់អាវដៃខ្លីមិនដឹងទេ ប៉ុនអត់មានពាក់អាវវែងអាវអីទេ ព្រោះខ្ញុំមិនចាំអាកន្លែងនឹង ប៉ុន មិនមែនខោវែងទេ ខោខ្លីទៀត ហើយអាវ បើមិនអាវយឺតខ្លួនទទេរប៉ុននឹង ប៉ុនដូចជាខ្លួនទទេរ ។

ដានី ៖ អញ្ចឹងខ្លួនទទេរទាំង២នាក់?

ទូច ៖ បាទ!

ដានី ៖ ចុះមុខមាត់អី មានដុះពុកមាត់អី បើតាមពូមើលឃើញពេលនឹង?

ទូច ៖ អឺ!វាកាលពិតដូចវាអត់ចាំ មានម្នាក់យប់អញ្ជើញវាពិបាកមើលដែលនឹងណា បើម្នាក់រៀនស បន្តិច ម្នាក់រៀនសម្បុរមិនសទេ ។

ដានី ៖ អានឹងអាលើកទី៣ចុងក្រោយ?

ទូច ៖ បាទ! ប៉ុនដូចរៀនមាំៗដែរ ។

ដានី ៖ ដូចរៀនមាំ ដើរអត់មានពុសម្លេងពួកនឹងរអ៊ូ ឬក៏អីយ៉ាងម៉េច?

ទូច ៖ អត់ៗ ។

ដានី ៖ ហើយដើរទៅខ្លួនទទេរ អត់មានស្ពាយអីទៅណា?

ទូច ៖ អត់ទេ គេឲ្យដើរទៅខ្លួនទទេរ ។

ដានី ៖ ចុះអ្នកដែលដឹកដៃទៅនឹង ដូចថាពីឡានមកគេមកតែម្នាក់ មកដឹកដៃទាំង២នាក់នឹងទៅ ឬក៏មាន គ្នាអីមកច្រើន?

ទូច ៖ មានគ្នាដើរ ដូចថាមិនមានការប្រុងប្រយ័ត្នអីណា មិនមានការអីគឹងរីងអីទេ ដូចហៅឡើងឡាន ទៅធម្មតាអញ្ជើញទៅណា ។ ប៉ុន្តែដូចជាមិនចង់មិនអី មិនដាក់ខ្នោះអីណាទេ ដូចអត់មានអញ្ជើញ ។

ដានី ៖ អត់ទេនោះ?

ទូច ៖ បាទ!

ដានី ៖ អត់មានបិទមុខ បិទអីទេ?

ទូច ៖ គេបិទមុខ ដូចបិទមុខដែរ បិទមុខមកដល់ដៃនឹងជាធម្មតាគេមិនឲ្យឃើញទេ បិទមុខៗ ។

ដានី ៖ បិទមុខ?

ទូច ៖ បាទ!គេបិទមុខហើយ ។

ដានី ៖ ពូដឹងថាលក្ខណៈហេតុអីបានគេបិទមុខ គេមិនឲ្យឃើញដៃ?

ទូច ៖ ព្រោះដៃៗយោធា ហើយអាម៉ារីននឹងនៅចតនឹងទាំងអស់ អញ្ជើញជាធម្មតាគេអត់ឲ្យឃើញអា ម៉ារីននឹងទេ សូម្បីតែទាហាន ពលរដ្ឋធម្មតាក៏គេមិនឲ្យទៅជិត មិនឲ្យទៅអីដែរ គេការពារអាម៉ា រីននឹងនោះ ។

ដានី ៖ ចុះពួកយួន ពួកថៃ ក៏គេបិទមុខដែរ?

ទូច ៖ បាទ!ពួកយួន ពួកថៃ ក៏គេមកយប់អញ្ជើញដែរ ហើយគេបិទមុខទុកតែក្មេងៗតូចៗអីវ៉ាន់ទេ មនុស្សចាស់ក៏គេបិទអត់ឲ្យឃើញដែរ ។

ដានី ៖ ប៉ុន្តែគេអត់មានចងទេ បរទេស២នាក់ដែលមកចុងក្រោយនឹង ក៏វាអត់?

ទូច ៖ បាទ!ខ្ញុំចាំបានថាដូចអត់មានចងផង កាលដែលដឹកដៃនឹងមកពីបិទមុខ ។

ដានី ៖ ដោយសារបិទមុខ បានគេធ្វើដឹកដៃ?

ទូច ៖ បាទ!

ដានី ៖ ម្នាក់ដឹកដៃមួយ ឬក៏២នាក់?

ទូច ៖ ដូចថាអ្នកដឹកដៃមួយអញ្ជឹងទៅណា ។

ដានី ៖ ម្នាក់ដឹកដៃមួយ ម្នាក់មួយទៀតទៅៗដឹកដៃមួយទៀត?

ទូច ៖ មួយទៀតទៅ ហើយមានអ្នកដើរទៅជាមួយគ្នាអញ្ជឹងទៅ ។ មានសភាពធម្មតា ប៉ុនយើងមិនដឹងថាមកដល់នេះវាយ៉ាងម៉េច យ៉ាងម៉ាយើងអត់ដឹង ។ប៉ុននៅទីនោះដូចធម្មតាហៅឡើងមកក៏ឡើងរថយន្តមិនមែនចងអីប្រង៉េងប្រង៉ាំអីដូចអត់មានឃើញចងឃើញអីទេ តាមដែលខ្ញុំមើលទៅប៉ុនបិទមុខដូចមានបិទ ប៉ុនជាធម្មតា ។

ដានី ៖ អានឹងពូច្បាស់ហើយណា៎ តែបិទមុខនឹងមួយទេ?

ទូច ៖ បាទ!យើងៗគិតថាម៉េចបានជាបិទមុខ ជាធម្មតាមកដល់កន្លែងនឹងគេអត់ឲ្យឃើញដៃ អត់ឲ្យឃើញទិដ្ឋភាពអាម៉ារីននឹងទេ ទី១ ។ ហើយទី២ទៀត ទាក់ទិននឹងការដឹកដៃនេះ បើធម្មតាមិនចាំបាច់ដឹកដៃទេមនុស្សយើង មិនអញ្ជឹង ដូច្នេះខ្ញុំសន្និដ្ឋានថាបិទមុខហើយ ។ ព្រោះទី១អត់ឲ្យមើលឃើញអីទេ ទិដ្ឋភាពមកដល់នឹង ទី២ទៀតព្រោះដៃនឹងដៃយោធា ហើយទី២ទៀតដឹកដៃ ខ្ញុំនៅចាំបានកន្លែងនឹង អញ្ជឹងបានន័យថាបិទមុខហើយ ។

ដានី ៖ គេឲ្យគេដឹកដៃពួកនឹងទៅដាក់ក្នុងកាប៊ីនឡានមុខ ហើយក៏ដាក់លើអាទ្រង់?

ទូច ៖ ដាក់ទ្រង់ឡានក្រោយ ព្រោះធម្មតាវាមានអាឡានទ្រង់នឹងទេ ហើយមានកម្លាំងអង្គុយជាមួយគ្នាអញ្ជឹងទៅ ។

ដានី ៖ ជាទូទៅអ្នកដែលចាប់បានមកនឹង គេយកទៅដាក់កន្លែងឃុំឃាំងអីនៅនេះ ឬក៏គេយកទៅកន្លែងមន្ទីរកងពល?

ទូច ៖ អានឹងខ្ញុំក៏អត់ច្បាស់ដែរ ការពិតទៅយើងដូចអត់បានសួរដឹងរឿងនឹងខ្លះដែរ កិច្ចការក្រៅពីអាបានយើងដឹង ។

ដានី ៖ ចុះអ្នកមកដឹក ពូមានស្គាល់ដែលអត់ ដូចថាអ្នកមកដឹកដៃ អ្នកដែលបើកឡានមកទទួលអី ពូមានចាំ អឺ!មានស្គាល់ ឬក៏មានស្គាល់ឈ្មោះ?

ទូច ៖ កាលនោះដូចជាមានស្គាល់ខ្លះ ប៉ុនដល់ឥឡូវវាយូរពេកទៅភ្លេចទៅ ដូចជាមានម្នាក់ធ្លាប់នៅជាមួយគ្នា ជាមេបញ្ជាការ ប៉ុន្តែទាល់ឥឡូវមិនដឹងជាគាត់ស្លាប់ ឬក៏ស្លាប់តាំងពីកាលណាទៀត ក៏មិនដឹងដែរ ។

ដានី ៖ គាត់ឈ្មោះអីទៅ?

ទូច ៖ ឈ្មោះណាន ។

ដានី ៖ ឈ្មោះណាន?

ទូច ៖ អឺ!

ដានី ៖ ណាននឹងមេបញ្ជាការអីគេ?

ទូច ៖ អានឹងអឺ!ជាអគ្គភាពមួយសម្រាប់ការពារកងពលនឹងផង ហើយសម្រាប់ខាងចាប់ ខាងចងអីនឹងដែរនឹង ។

ដានី ៖ ឈ្មោះណាន?

ទូច ៖ បាទ!

ដានី ៖ ប៉ុន្តែ ។

ទូច ៖ បានមេបញ្ជាការសម្រាប់ការពារ ។

ដានី ៖ ការពារខាងសន្តិសុខ?

ទូច ៖ បាទ!ខាងការពារផង ខាងចាប់ចងអីនឹងដែរនឹង ។

ដានី ៖ ណាន ប៉ុន្តែមិនដឹងថាគាត់នៅរស់ ឬក៏?

ទូច ៖ ណាននឹងក្រោយមកថាមានបញ្ហាទៀត ។

ដានី ៖ បញ្ហាយ៉ាងម៉េចទៅ?

ទូច ៖ បញ្ហានឹងរឿងមិនច្បាស់ ប៉ុន្តែរឿងជាមួយអ្នកទោស ដូចថានៅក្នុងអគ្គភាពនឹងការពិតម្នាក់នឹងនៅរស់រហូតដល់ឥឡូវ មានការចោទប្រកាន់ចេះចោះទៅក៏ចាប់គ្នាដ៏ចាប់ទៅម្នាក់នឹងស្រី ហើយដល់ទៅដេកក្នុងបន្ទប់ក្នុងអីមិនសូវមានការតឹងតែងប៉ុន្មានទេ ។ ដល់អញ្ចឹងទៅដូចជាដេកទៅដេកស្រាត ដេកអីអញ្ចឹងទៅ ហើយដល់អាអ្នកទៅពិនិត្យអ្នកយាមនឹងដូចជាមិនហ៊ានចូលទៅរួមរក្សជាមួយអ្នកនឹង ឬក៏យ៉ាងម៉េចក៏មិនដឹងយើងរហូតដល់ម្នាក់នឹងរួច ម្នាក់ស្រីនឹងរួចចេញពីគុកនឹងចេះ ។

ដានី ៖ ប្រហែលទៅមានការស្រឡាញ់អ្នកទោស ឬក៏?

ទូច ៖ បាទ!ការពិតទៅប្រហែលជាអ្នកទោសនឹងដេក ដូចថាដេកស្រាតដេកអីលែងគិត លែងគូរអីអញ្ចឹង ។ អ្នកទោសម្នាក់នឹងជាកងវរៈ ដល់ពេលក្រោយមកគាត់មិនដឹងជាមានទោសកំហុសអីពាក់ព័ន្ធជាមួយសង្សារគាត់ ដែលត្រូវជាប្តីត្រូវគេចាប់ ដល់គេចាប់អញ្ចឹងទៅគេអាចឆ្លើយដាក់ថាគាត់នឹងមានពាក់ព័ន្ធគាត់ ក៏គេចាប់គាត់ទៀតទៅស្រីនឹង ។ ដល់ចាប់ទៅដាក់គុកនឹងទៅ វាដូច

ជាមានដេកក្នុងគុកនឹងដេកស្រោតដេកអីអញ្ចឹងទៅ ហើយអាអ្នកនេះនឹងបែបមិនទ្រាំមិនបាន អី ម៉េចមានរឿងអញ្ចឹង។ ហើយវាអាចទៅរំលោភអ្នកទោស ហើយមានប្រព្រឹត្តិគ្នា ហើយលែង អ្នកទោសនឹងទៅ បានឈ្មោះណននឹងមានបញ្ហាទៀត។ អានឹងពត៌មានមិនច្បាស់ទេ ពុតគ្នាទេ ប៉ុនវាប្រហែលជាអញ្ចឹងដែរ ព្រោះរីននឹងបានរួចចេញដែរ។

ដានី ៖ នៅរស់ដែរអត់សព្វថ្ងៃ?

ទូច ៖ នៅរស់។

ដានី ៖ នៅណាទៅ?

ទូច ៖ នៅរស់កាលនេះនៅលិចនឹងដែរ។

ដានី ៖ នៅខាងសំឡូត?

ទូច ៖ អត់ទេកាលនឹងនៅកោះកុងនេះ ដល់ហើយមិនដឹងទៅណា មិនដឹងជាទៅនៅបាត់ដំបង ឬនៅ សំឡូត ឬនៅណាគឺខ្ញុំមិនដឹងទេ ប៉ុនខ្ញុំដឹងថានៅរស់។

ដានី ៖ នារីនឹងឈ្មោះអីទៅ?

ទូច ៖ ឈ្មោះរីម។

ដានី ៖ ឈ្មោះរីមហ៎?

ទូច ៖ បាទ!

ដានី ៖ ពូអត់ដឹងថានៅ គាត់នៅណាៗច្បាស់ទេ?

ទូច ៖ អត់ដឹងច្បាស់ទេឥឡូវ កាលពីយើងនៅជាមួយគ្នា ដឹងថានៅ អត់ស្លាប់ទេ។

ដានី ៖ ចុះពូកាលពីពូឃើញទាំងអ្នកដែលគេចាប់មក ដូចជាយួន ថៃ បរទេសអី ទាំង៣លើកនឹង កាល នឹងពូមានភារកិច្ចអី កាលនឹងបានជាពូ?

ទូច ៖ កាលនឹងយើងគ្រាន់តែអាម៉ារីនយើងចតនៅនឹង។

ដានី ៖ ចតនៅនឹង?

ទូច ៖ បាទ!

ដានី ៖ ចតនៅក្បែរនឹង?

ទូច ៖ បាទ!អាម៉ារីនយើងនៅដែនឹង ហើយដែៗឈើធម្មតានឹង វាមានទំហំត្រឹម៉ាយើងអាចដើរ យើងអាចអូសរទេះអីបាន មិនមែនជាដែមាំទាំដែបណ្តោះអាសន្ន។ អញ្ចឹងយើងចតនឹងទៅ ហើយគេយកអានឹងមកចតនៅក្បាលដៃ យក ព្រោះអាម៉ារីនយើងចតអមសងខាង ហើយគេ យកមកចតក្បាលដែអញ្ចឹងគេនាំមនុស្សដើរលើដែអញ្ចឹងទៅ។

ដានី ៖ យើងគ្រាន់តែឃើញគេអញ្ចឹងទៅ?

ទូច ៖ បាទ!

ដានី ៖ ចុះពេលនឹងពូមានសួរទេ ចាប់អីមកពីណា មូលហេតុអីៗយើងអាចសួរគេដែរ?

ទូច ៖ មិនអាចទេ កាលនឹងគ្រាន់ថាពូសួរនិយាយៗគ្នា យើងអាចនិយាយគ្នា សួរគ្នាយើងបាន ប៉ុន្តែយើងមិនអាចទៅសួរគេវែងឆ្ងាយរឿងអញ្ចឹងៗ ។ យើងចង់សួរក៏បានដែរ ប៉ុនគ្រាន់ថាមិនដឹងជាសួរមានប្រយោជន៍អី យើងចេះតែអានឹងជនជាតិបរទេស ហើយមកតាមទូកៗនឹងចាប់មកមានគ្នា២នាក់ អញ្ចឹងដល់ពេលហើយយើងទៅមើលទូក មើលមនុស្សមើលអីគេនឹងឯង ។

ដានី ៖ ប៉ុន្តែចែជន្យដូចទូក អឺ!មាន បើទូកមួយមានមនុស្សតែ២នាក់ៗអញ្ចឹង?

ទូច ៖ ខ្ញុំមិនដឹងដែរ ។

ដានី ៖ បើតាមមើល បើតាមពូគិតមើលទៅពូ ទូកដូចថាអ្នកទូកមនុស្ស២ៗនាក់អញ្ចឹង ជាជនស៊ីវិលជាអ្នកទេសចរណ៍ ឬក៏ពួកស្ទីដែរ បើតាមមើល?

ទូច ៖ នេះតាមការគិតរបស់ខ្ញុំទេ ខ្ញុំគិតថាអានឹងវាមានប្រព័ន្ធចាប់ផ្តើម ។

## កាសែ្សតទី២ ផ្នែក«ខ»

ទូច ៖ ថាម៉េចទេ វាជាតួនាទីរបស់ប្រទេសគេ រដ្ឋគេព្រោះថាគេចង់ធ្វើអីគេដាក់កម្លាំងស៊ើបការណ៍ គេត្រូវតាមទៅមើល គេត្រូវអីអញ្ចឹងអានឹងជារឿងរបស់គេ ហើយអ្នកដែលចាប់អានឹងវាជារឿងរបស់អ្នកចាប់ មកដល់នឹងដែនសមុទ្រគេហើយ គេត្រូវចាប់ អានឹងយើងក៏អត់ដឹងដែរ ប៉ុន្តែជាធម្មតា ។

ដានី ៖ ប៉ុន្តែពេលនឹងពូដែលពូដូចថាកាលគេចាប់បរទេសមកដូចថាអញ្ចឹង ភាគច្រើនគេនិយាយថាពួកបរទេសអីដូចជា កាលជំនាន់នឹង បើតាមខ្ញុំពូដូចជាពាក្យ?

ទូច ៖ សេ.អ៊ី.អា ។

ដានី ៖ សេ.អ៊ី.អា កា.សេ.បេអីអញ្ចឹង កាលនឹងដូចពាក្យបរទេសមកអញ្ចឹង គេច្រើនថាពួកនឹងជាពួកអីគេ?

ទូច ៖ ជាសេ.អ៊ី.អា បើពួកនេះវាបើថាជាទេសចរណ៍ក៏មិនជាប្រព័ន្ធអញ្ចឹងដែរ ខ្ញុំមើលទៅឃើញថាទូកទី១អញ្ចឹងដែរតូចបន្តិច ទី២អញ្ចឹង មកទី៣ដល់ពេលចុងក្រោយយើងយកអានឹង យកមកវិភាគម្តង បូកបញ្ចូលគ្នាទៅ ហើយឃើញប្រហាក់ប្រហែលគ្នា ។ ហើយអ្នកទាំងអស់នឹងសុទ្ធតែមានម៉ាស៊ីនរូបថត ម៉ាស៊ីនអីដែលមានចំងាយឆ្ងាយៗ អីថតអីនឹងណា ។

ដានី ៖ បាទ!បើតាមពូចាំចំណាំមើល ពូឃើញថាក្នុងទូកទី១ ទី២ ទី៣សុទ្ធតែមានម៉ាស៊ីនថត?

ទូច ៖ បាទ!អានឹងដូចជា បើនិយាយទៅយើងថាវាដូចជាក្នាក់ងារអីចូលមកស៊ើបការណ៍នៅក្នុងសមុទ្រ យើងក៏ថាបាន អានឹងវាមិនអីទេ ឬក៏គេថាទេសចរណ៍ក៏ថាបានព្រោះយើងវាមិនដឹងយ៉ាងម៉េចដែរ ។ ប៉ុនស្ទីដែលយើងចាប់អារម្មណ៍គឺថា ជាធម្មតាប្រទេសកុម្មុយនីស ហើយមានអ្នកទេសចរណ៍ចូលមកអញ្ជឹងអី អានឹងវាជាធម្មតាចង់ទៅទេសចរណ៍ប្រទេសណា ត្រូវមានការទំនាក់ទំនងគ្នាមិនអញ្ចឹង ។ ហើយដល់ចូលមកក្នុងប្រទេសមួយទើបនឹងចប់ពីសង្គ្រាម ហើយប្រទេសកុម្មុយនីសអញ្ចឹងផង អានឹងយើងចាប់អារម្មណ៍ថាមិនបានទំនាក់ទំនងគ្នា ហើយចូលមកអញ្ចឹង យើងខ្លាចថាវាអាចគេប៉ាន់ស្មានថាជាសេ.អ៊ី.អា ស៊ើបការណ៍ស៊ើបអីអញ្ចឹងណា ។ ប៉ុន្តែ ការពិតមិនដឹងអី យើងមិនយល់ដែរ ប៉ុនគ្រាន់ថាចាប់អារម្មណ៍អញ្ចឹង ។

ដានី ៖ អឺ!ដូចថាកាលនឹង អាទូកៗចុងក្រោយបើតាមពូប៉ាន់ស្មានមើល ដូចថាទំហំវាទទឹងចេះប្រហែលជាប៉ុន្មានម៉ែត្រ ជម្រៅចេះប្រហែលជាប៉ុន្មាន ហើយបណ្តោយប៉ុន្មាន តាមពូប៉ាន់ស្មានអាទូកចុងក្រោយ?

ទូច ៖ ទូកចុងក្រោយនឹងដូចយើងមើលទូក៣ម៉ែត្រជាងនឹងណា ។

ដានី ៖ ទទឹងប្រហែលជា៣ម៉ែត្រ?

ទូច ៖ បាទ!ប្រហាក់ប្រហែលប៉ុននឹងហើយ ។

ដានី ៖ ៣ម៉ែត្រ ចុះជម្រៅពីក្បាលមកគែម?

ទូច ៖ អូ!អាទូកនឹងពីជម្រៅវាខ្ពស់ ធំៗណាស់ទូកនឹង ឃើញថាធំម៉ង បាទ!មានជិះកាត់សមុទ្រនឹងអត់ខ្លាចម៉ង ។

ដានី ៖ បានន័យថាជ្រៅម៉ងបាតវា?

ទូច ៖ អឺ!ទូកវាធ្វើៗរៀងទំរង់អញ្ចឹង មើលទៅឃើញអញ្ចឹងហើយ ប៉ុន្តែអាជម្រៅវិញនោះស៊ីទឹកជ្រៅមិនដូចទូកធម្មតាយើង ដែៗលើទឹកអញ្ចឹងទេ ។ ទូកវាធ្វើរបៀបអាចជិះរលកបាន ហើយអាចឆ្លងកាត់សមុទ្រជ្រៅៗបាន ព្រោះវាធ្វើបើករៀងទៅ....អញ្ចឹងមកហើយមានពោះវាទម្លាក់ទៅក្រោម ហើយខាងក្រោមភាគច្រើនគេចាក់ស៊ីម៉ង់ឲ្យមានទំងន់ ។

ដានី ៖ ចាក់នៅក្នុងបាតនឹង?

ទូច ៖ បាទ!ចាក់ក្នុងបាតឲ្យវាមានទំងន់ណា ឬក៏វាអាចចាប់ដែកខាងក្រោមអីអញ្ចឹង ដូច្នេះវារៀងមានទ្រង់ទ្រាយអញ្ចឹង ខ្ញុំចេះតែសង្ស័យទូកនឹងដែរនឹង ដងក្តោងអី ។ ការពិតនៅខ្ញុំនៅឃើញនៅនឹងប៉ុន្មានឆ្នាំមុនខ្ញុំទៅមើលនៅដែនឹង ហើយឥឡូវមិនដឹងយកទៅណាមិនដឹង ។ ហើយទូកនឹងមាន

អាកន្លែងអាបន្តិចនឹងទេ នេះប្រវែងនឹងមកវែងនឹងទេ កន្លែងដែលចូលទៅក្នុងនឹងហើយមានម៉ាស៊ីននៅពីក្នុង ។

ដានី ៖ បណ្តោយប្រហែលប៉ុន្មានម៉ែត្រ បណ្តោយ?

ទូច ៖ ហ៊ឺ!បណ្តោយប៉ុន្មានទេ ទូកនឹងវែងដែរនឹង អាចពីនឹងទៅសសរនឹងដែរ ។

ដានី ៖ ប្រហែល១០ម៉ែត្រៗជាង?

ទូច ៖ បាទ!នឹង ។

ដានី ៖ ចុះឥវ៉ែឥវ៉ាន់របស់ទូកនឹង ពេលដែលគេដឹកដៃមនុស្សទៅ ឥវ៉ែឥវ៉ាន់ក្នុងទូកនឹងពូទៅមើលនៅឃើញដដែល ឬក៏គេប្រមូលយកទៅ?

ទូច ៖ មានឥវ៉ាន់ខ្លះ គេប្រមូលយកទៅ ឥវ៉ាន់ខ្លះគេយកប្រមូលយកទៅ តែឥវ៉ាន់ខ្លះវានៅនឹងដែរ វាដូចថាវាមិនចាំបាច់អីយកទៅនឹង ។

ដានី ៖ បាទ!មានស្អីខ្លះដែរគេអត់ប្រមូលទៅ?

ទូច ៖ បាទ!មានចាន មានឆ្នាំង ខ្លះមានរបស់ប្រើប្រាស់អីកំប៉េកកំប៉ុក ។

ដានី ៖ ភាគច្រើនដែលគេប្រមូលទៅ ច្រើនប្រមូលយកទៅធ្វើអីដែរ?

ទូច ៖ អានឹងមិនច្បាស់ដែរ យកទៅកន្លែងកងពលទៅ គេយកទៅដើម្បីជាភស្តុតាង ឬក៏ជាអីមិនដឹងយើងមិនបានដឹងដែរ ។

ដានី ៖ ចុះដាក់ដូចជារូបថតអី ពូមានឃើញអីដែរអត់?

ទូច ៖ បាទ!ឃើញប្រមូលទាំងអស់ ។

ដានី ៖ ប៉ុន្តែពូឃើញក្នុងកាប៉ាល់ទី៣នឹងមានឃើញរូបថតដែរអត់ ដូចជារូបថតរបស់មនុស្ស រូបថតទេសភាព ឬរូបថតដែលគេថតអី ពីព្រោះតែមានកាំម៉ារ៉ាអញ្ចឹងប្រហែលជាមានរូបថតអីហើយ ប៉ុន្តែពេលនឹងពូមានឃើញរូបថតអីដែរអត់?

ទូច ៖ កាលពិតទៅយើង ដូចថ្ងៃនឹងអីយើងចុះទៅ ដូចថាគេចេញដុតអីអញ្ចឹង យើងទៅមើលទៅអីយប់អញ្ចឹង ដូចថាអត់មានពេលវេលាណានឹងទៅគេឲ្យយើងមើលច្រើន មើលយូរអី ខ្ញុំគ្រាន់បានចុះទៅមើលទ្រង់ទ្រាយកាប៉ាល់ម៉េច រៀងម៉េចអីហើយ គេយកកាប៉ាល់នឹងចេញទៅចតកន្លែងផ្សេងទៅ គេមិនឲ្យយើងមើលអញ្ចឹង ។ ហើយការពិតទៅយើងជាមនុស្សដែលចូលចិត្តមើល ចង់ដឹងដងទេ បើអ្នកខ្លះគេមិនបានមើលផង ។

ដានី ៖ បាទៗ គេបណ្តើរទៅសន្តិភាព អត់មានពូខាងបរទេសនឹងឡូឡាឬក៏ខាងកងការពារទៅឡូឡាគំរាមកំហែង ឬក៏វាយ?

ទូច ៖ អត់ទេ ។

ដានី ៖ អត់ទេ ទៅធម្មតា?

ទូច ៖ បាទ!ទៅធម្មតា ។

ដានី ៖ អាទី៣នឹងប្រហែលជាម៉ោង៨ អ៊ឺ!កន្លះម៉ោង៨ដដែល?

ទូច ៖ បាទ!ប្រហែលក្នុងចន្លោះម៉ោងប៉ុននឹងក៏វា គេអាចយប់បន្តិចដែរ ។

ដានី ៖ អាចយប់ជ្រៅជាងនឹងបន្តិចទៀត?

ទូច ៖ បាទ!វាមិនអាចមិនៗ យប់ជ្រៅទេ វាអាចប៉ុននឹង ព្រោះថាវាអាចម៉ោយប់ម៉ង់ៗ ប្រហែលជាម៉ោង៧ជាងអី ម៉ោង៧ ម៉ោង៨នឹង ។

ដានី ៖ អាទី២ក៏អញ្ជឹងដែរ?

ទូច ៖ បាទ!ទី២ដូចជាម៉េចទេ ខ្ញុំចាំមិនច្បាស់ទេណា ប៉ុន្តែដែលបានដឹងពត៏មានខ្លះអីខ្លះហើយឃើញខ្លះនឹងថា២នាក់ៗអញ្ជឹងដូចគ្នា ។

ដានី ៖ ដឹងថា២នាក់ៗអញ្ជឹងហើយ?

ទូច ៖ ហើយជាធម្មតាយប់អញ្ជឹង ។

ដានី ៖ បាទ!ហើយមាន៣វគ្គអញ្ជឹងម៉ង?

ទូច ៖ បាទ!មាន៣វគ្គអញ្ជឹង ។

ដានី ៖ ២នាក់ៗសុទ្ធតែមនុស្សប្រុ ២ៗនាក់?

ទូច ៖ បាទ!ប្រុស២នាក់ៗ ។

វណ្ណៈ ចុះពូខ្ញុំចង់សន្នេបឡើងវិញបន្តិច អ៊ឺ!ទី១នឹងចាប់នៅឆ្នាំណា ហើយខែណា ហើយទី២នឹងចាប់នៅឆ្នាំណាខែណា ហើយចុងក្រោយនឹងចាប់នៅខែណា ឆ្នាំណាដែរ?

ទូច ៖ នឹងសុទ្ធតែក្នុងចន្លោះ៧៧ ៧៨នឹង ប៉ុន្តែយើងមិនអាចចាំថ្ងៃខែទេ ប៉ុន្តែដូចជា៧៧នឹង ទី១ក្នុង ៧៧ ដល់ទី២ ទី៣នឹង វាចន្លោះពី៧៧ និង ៧៨នឹងប៉ុននឹងឯង ។ ក្នុងឆ្នាំ ២ឆ្នាំនឹងដូចជាអានេះនៅក្នុង៧៨ម៉ងអានេះ ៧៨ហើយចុងឆ្នាំ៧៨ទៀត ។

ដានី ៖ អាពូឃើញក្នុងរបបថតនេះនឹង?

ទូច ៖ បាទ! អាក្រោយគេនឹងចុង៧៨ម៉ង ។

ដានី ៖ ចុង៧៨ម៉ង?

ទូច ៖ បាទ!

ដានី ៖ កាលនឹងពូចាំ ដូចថាកាលនោះខ្យល់ៗសមុទ្រគេបកមកពីទិសណា?

ទូច ៖ អានឹងខ្យល់ អេ!កាលណាចុង៧៨នឹងវាបានន័យថាខែ១១ ខែអីនឹងណា ។

ដានី ៖ បាទ!ខ្ទង់ប្រហែលខែ១១អីនឹង?

ទូច ៖ ហ្នឹងខ្ទង់ខែ១១អីនឹងណ៎ា ។ អូ!ទូកនឹងយកមកអត់ទាន់ទៅណាទេ នៅចតទុកចោលនៅមុខខាងត្បូងអូរឈើទាលនឹង ។

ដានី ៖ បាទ!ទុកចោលនៅនឹង?

ទូច ៖ បាទ!ដល់ពេលខ្ញុំមិនចេញទៅក្រៅ គ្រាន់ទូកនឹងនៅនឹង ។

វណ្ណៈ ៖ ចុះពូបានអើតឃើញទូកនឹងរហូតដល់ឆ្នាំណា ពូទៅមើលម្តងទៀត?

ទូច ៖ អឺ!ឆ្នាំ មកដល់ឆ្នាំអឺ ៩១ខ្ញុំមកខ្ញុំទៅដែរអឺ!ទំនប់រលក ខ្ញុំឃើញនៅចតចោលនឹង បាទ! ហើយស្រាប់តែទៅដល់២០០០ប៉ុន្មានទេ ២០០២អញ្ចឹងហ៎ ២០០២នេះមានអ្នកមកសួរខ្ញុំរឿងនឹង ខ្ញុំតាមទៅរកមើលទៅឃើញនៅដៃៗធំ អាជិតដៃធំនឹងអាកន្ទែងដីគោក ។

ដានី ៖ ចុះឆ្នាំ២០០២មានគេសួររឿងទូកនឹងដែរ?

ទូច ៖ មានដែរ ។

ដានី ៖ ពួកណាទៅមកសួរ?

ទូច ៖ មិនស្គាល់ច្បាស់ ពួកបរទេសអញ្ចឹងដែរ ។

ដានី ៖ ពួកបរទេស គេមកសួរថាម៉េច?

ទូច ៖ សួរអារឿងធ្លាប់ឃើញអីអញ្ចឹង ។

ដានី ៖ គេឈ្មោះអីទៅអ្នកមកសួរនឹង?

ទូច ៖ ខ្ញុំមិនចាំទេ ភ្លេចបាត់ហើយ ។

ដានី ៖ ប៉ុនគេមកជួបពូ គេមកសួររឿងដំនើរទំនងទូកដូចខ្ញុំសួរមិញនឹងដែរ?

ទូច ៖ បាទ!

ដានី ៖ ប៉ុនតាំងពីឆ្នាំ២០០២មក?

ទូច ៖ បាទ! ហើយខ្ញុំក៏តាមទៅរកមើលទូកនឹង ក៏ឃើញអាទូកនឹងគេលើកដាក់គោកហើយ ។

ដានី ៖ ដល់ពេលនឹង មាននាំគេមកមើលទូកនឹង?

ទូច ៖ អត់ៗ គេអត់ទៅ គេថាគេដឹងដែរ តាមខ្ញុំ ។

ដានី ៖ អូ!អញ្ចឹង កាលគេចាប់ទូកនឹង ពូដឹងថាមូលហេតុដែលគេចាប់ មូលហេតុពិតប្រាកដម៉្ង គេចាប់នឹងមូលហេតុអីទៅ?

ទូច ៖ ហ្នឹង មិនដឹងទេ ប៉ុនគ្រាន់ថាទូកដែលចូលមកក្នុងដែនដី ។

ដានី : ចូលដែនដីយើង?

ទូច : បាទ! ដែនដីយើង ។

ដានី : ពីម្តុំខាងកោះ?

ទូច : អឺ! មិនដឹងជាម្តុំណាទេ ប៉ុន្តែចូលដល់ដីយើងហើយ អូ! បើសិនណាជានៅខាងក្រៅដូចជាអត់មានអីទៅចាប់ទេ វានៅឆ្ងាយពីកោះ ឆ្ងាយពីវាដាយើង ។ ហើយវាដាយើងវានៅក្នុង មានព្រំដែនកំណត់ដែលអាចមើលឃើញចំងាយម៉ា ៗ ក្នុងទឹកដីយើងអញ្ចឹងណា ។

ដានី : ប៉ុន្តែអ្នកដែលនាំមកនឹង ច្រើនអ្នកដែលច្រើនល្បាតនៅកោះតាង ឬក៏កោះផ្សេងទៀត? នាំទូកទីពានិយាយតែទូកទីពាមួយដែលចាប់?

ទូច : ដូចជាពួកកោះតាង ។

ដានី : កោះតាង?

ទូច : បាទ!

ដានី : អញ្ចឹងបានទូកនឹងគេចាប់មកពីម្តុំកោះតាង?

ទូច : ប្រចាំការនៅកោះតាងហ្នឹងហើយ ។

ដានី : ពូចាំទូកណាមួយណា ដែលប្រចាំក្រៅកោះតាង?

ទូច : កោះតាង ទាល់តែសួរពួកនាវិក សួរពួកកាងនឹងបានច្បាស់ ព្រោះខ្ញុំអត់បាននៅកោះតាងទេ កាលនោះ ខ្ញុំនៅដែដូចខ្ញុំបានជម្រាបអញ្ចឹង បើកោះតាង វិន ហើយ កាន គេនៅជាមួយគ្នា ។

ដានី : កោះតាង បាទ!

ទូច : ២នាក់នឹងគេនៅប្រចាំអឺ! កាលមុននៅនាវាមួយគ្នា ហើយក្រោយមកគេដកខ្ញុំចេញមកខាងអាបណ្តែត ហើយអឺ! ធាងនៅមូលគ្នា ហើយប្រចាំការកោះតាង ។

ដានី : ពូស្គាល់ឈ្មោះ ពែល ឈ្មោះអី?

ទូច : ពែលនឹងមានឈ្មោះមែន ឈ្មោះអញ្ចឹងមែនពីដើម ប៉ុនមិនដឹង ។

ដានី : ពូកាន ប្រាប់ខ្ញុំអញ្ចឹងថាឈ្មោះពែល អីគាត់អ្នកដែលបើកទូកឈើ BE គាត់ថាច្រើនពួក BE អ្នកជូន ដូចថាពេលចាប់?

ទូច : បាទ! ហ្នឹងហើយច្រើនពួកនឹង មិនគេមិនយកនាវាជូនទេ បើសិនណាទៅចាប់ប្រហែលជាពួកនឹងជាអ្នកចាប់ ។ ប៉ុនដល់ពេលជូនពួកនឹងអ្នកជូន អូ! ពួកនាវានឹងគេមិនមែនជាអ្នកជូនទេ ព្រោះករណីនឹងទៅណាមកណា គេមិនចោលអាក្រុមជំនាញគេទេ គេខ្លាចបាត់សមាជិកគេណាស់ ។

ដានី : អញ្ចឹងអត់ឲ្យចេញពីកាប៉ាល់?

ទូច ៖ បាទ!អត់ឲ្យចេញពីនាវាគេទេ ព្រោះគេម្នាក់ត្រូវប្រចាំការឲ្យមានតួនាទីជាម្នាក់ៗអញ្ចឹង ហើយ អ្នកជូននឹងបានន័យថាអ្នកផ្សេងទេ ជូននោះ ។

ដានី ៖ អញ្ចឹងកាប៉ាល់នឹងវៀង ផ្ទៃវាពណ៌ពងមាន់?

ទូច ៖ បាទ!បើយើងមើលពីឆ្ងាយ វាសទាំងអស់ម៉ង ។

ដានី ៖ វៀងសម៉ង?

ទូច ៖ អឺ!

ដានី ៖ បាទ!ក្តោងពណ៌អីទៅ អាជងក្តោង?

ទូច ៖ ជងសដែរនឹង ។

ដានី ៖ ជងស?

ទូច ៖ នេះអាជងនេះ សស្កុះម៉ង ។

ដានី ៖ បើតាមពូប៉ាន់ស្មាន អាជងក្តោងវាទៅនឹង កំពស់ប្រហែលប៉ុន្មានទៅ?

ទូច ៖ ខ្ពស់ៗមែនទែន ។

ដានី ៖ ខ្ពស់មែនទែន?

ទូច ៖ បាទ!ចំឡែក នៅស្រុកយើងៗមិនដែលឃើញទូកណាអញ្ចឹងទេ យកមកមានតែមួយនឹង ហើយ មកដល់សព្វថ្ងៃនឹងទៀត ទូកនឹងហេតុអីបានខ្ញុំចូលចិត្តសង្កេតទូកនឹង ព្រោះទី១ខ្ញុំចាប់អារម្មណ៍ថា ទូកនឹងជាទូករបស់ពួកអឺរ៉ុប ។ បាទ!មិនមែនទូកនៅអាស៊ីយើងទេ ហើយទី២ទៀត អ្នកដែលមក នឹង គឺជាជនជាតិបរទេស ។ បាទ!ហើយពេលដែលយកមកដល់ ពេលដែលចេញ ពេលដែលខ្ញុំ ចេញពីកន្លែងអូរឈើទាលនឹង នៅឆ្នាំ៧៩ ពេលយួនចូលនឹង ទូកនឹងត្រូវបោះយុថ្កាទុកចោល នៅនឹង អត់មានអ្នកណាយកទៅណាទេ ។ ដល់អាពេលឆ្នាំ៩១ ខ្ញុំមកវិញ ខ្ញុំដើរចុះដើរឡើង ទូកនឹងបើវានៅឆ្ងាយពីគេក៏ខ្ញុំ គង់យើងមើលស្គាល់ហើយ មានតែមួយនឹងទេ មិនដែលមានទូក ណា អាចប្រដូចនឹងវា ឬក៏អាចថាច្រឡំពិបាកមើលទេ មានតែមួយនឹងទេ បាទ! ។

ដានី ៖ កាលនឹងដូចថា បើតាមពូនេះ ដូចថាទូកអ្នកដែលជាជនបរទេសនឹង បានពេលដែលគេបញ្ជូនមក នឹងមាន មើលទៅមានបានហូបចុកអីហើយនៅ គេមានឲ្យហូបអាហារ?

ទូច ៖ ហ្នឹងខ្ញុំអត់បានដឹងទេ ដូចខ្ញុំអឺ!ៗជម្រាបខាងដើមនឹងថាខ្ញុំជាអគ្គភាពអាម៉ារីនមួយដែលនៅកំពង់ ផែកន្លែងនឹង ដូច្នេះកាលដែលគេនាំមនុស្សមកឆ្លងកាត់នឹង គឺមកដល់ពេលយប់ហើយ ។ ដូច្នេះ មិនដឹងជាសកម្មភាពនឹង វាពីណាមកណាអីយ៉ាងម៉េចទេ កាលដែលយើងបានទទួលនឹងគ្រាន់

ដំណឹង ហើយស្អីៗដែលយើងមើលឃើញទិដ្ឋភាពជាក់ស្ដែងនឹង នៅពេលដែលគេយកមកដល់ដៃ គេនាំមនុស្សឡើងលើដៃ ដើរលើដៃទៅឡើងឡាន ប៉ុននឹងទេ មិនបានឃើញ ។

ដានី ៖ ពូដូចថា ពូង៉ាកមើលទៅប្រហែលៗស្រដៀងមនុស្ស២នាក់ ប្រុសៗនៅក្នុងរូបថតនឹងដែរ?

ទូច ៖ បាទ!ខ្ញុំមើល មានឃើញ អឺ!ពេលដែលគេចេញទៅម្នាក់នេះ ដើរក្រោយ ម្នាក់នេះដើរមុខណា

ដានី ៖ ម្នាក់នេះដើរមុខ ម្នាក់នេះដើរក្រោយ?

ទូច ៖ ២នាក់នឹង ។

ដានី ៖ អ្នកខ្ពស់ៗនេះដើរមុខ ហើយម្នាក់ដែលឈរជិតនារីនឹងដើរខាងក្រោយ?

ទូច ៖ បាទ!ហើយអឺ!ម្នាក់នេះដូចជារៀងសខ្លាំងជាង ។

ដានី ៖ ម្នាក់ខ្ពស់នឹងសជាងម្នាក់ដែលនៅជិតស្ដ្រីនឹង?

ទូច ៖ បាទ!

ដានី ៖ ស្រដៀងៗនឹង បើតាមពូមើល?

ទូច ៖ បាទ!ស្រដៀងនឹង អូ!មាននៅរូបភាព ម្នាក់វាដើររៀងអញ្ចឹង ខ្ញុំនៅចាំបានថាម្នាក់នេះអឺ!ដើរក្រោយ ម្នាក់នេះដើរមុខ ដូចជាសង្ស័យនឹងដែរ ប៉ុនដឹងជាដូចម៉េចទេ ប៉ុនគ្រាន់អានឹងជាធម្មតាចម្លើយរបស់យើងៗមិនច្បាស់ទេ ព្រោះស្អីដែលយើងឃើញគឺយើងអត់បានចាប់អារម្មណ៍ ។ ប៉ុនយើងតាមមើលថា ម្នាក់នេះដើរមុខរៀងសជាង ហើយម្នាក់នេះដើរក្រោយរៀងល្មមអញ្ចឹងមែន រៀងសម្បុររៀងមិនសូវសដូចម្នាក់នេះទេ ។

ដានី ៖ ប៉ុន្តែពេលៗដែលដូចថាខាងកងការពារគេមកយកនោះអត់មានឃើញគេមកយកដឹកដៃ អត់មានដូចថាសួរនាំទៅវិញទៅមក ហើយបរទេសនឹងសួរមកនេះ សួរទៅវិញសួរទៅមកអត់មានទេ?

ទូច ៖ អត់ទេៗ ដូចអត់មានអញ្ចឹង ។

ដានី ៖ ស្ងាត់ស្ងៀម?

ទូច ៖ កាលណាទូកនឹងមកដល់ដៃនឹង គេតំរង់បត់ឡើងម៉ង ឲ្យឡើងម៉ង អ្នកនាំគេត្រូវនាំឡើងមកដើម្បីឲ្យអ្នកនាំនៅនេះបន្តនាំទៅឡើងឡាន ។

ដានី ៖ គេមកដឹកដៃទៅបណ្ដោយ?

ទូច ៖ បាទ!

ដានី ៖ ប៉ុនពូកាលនឹង ពូមិនបាន អឺ!បានចាប់អារម្មណ៍ឃើញថានៅលើ ព្រោះដោយសារគាត់ដោះអាវស្បៀកខោខ្លីអី បើតាមពូស្មាន?

ទូច ៖ បាទ!

ដានី ៈ អឺ!ពូនេះនឹង កាលនឹងមានឃើញរបួសស្នាមអីនៅលើខ្លួនគាត់អី អត់ទេ មានឃើញដែរ?

ទូច ៈ កាលពិតទៅ ទាហានយើងមែនទែន មិនជាអ្នកធ្វើទារុណកម្មអញ្ជឹងៗទេ បើនិយាយឲ្យមែនទែនទៅ ពួកទាហានយើងម៉ង ដូចជាអត់មានអញ្ជឹង ។ បើករណីឡើងមកដល់លើអានឹងយើងមិនដឹងទេ ប៉ុនបើខ្ញុំខ្លួនឯងខ្ញុំៗមើលឃើញមានទំលាប់មួយអញ្ជឹង បើថាចាប់បានមកក៏ ទៅចាប់ក៏មិនដូចមានការវាយតប់អី ហើយនាំមកទៀតក៏ដូចជាមិនសូវជាមានការ ព្រោះទាហាននិយាយរួមអត់សូវមានរឿងអញ្ជឹងៗ ដូចគេមូលដ្ឋាន ដូចឈ្លប ដូចស្អីៗ ទាហាននឹងដូច និយាយរួមទៅខ្លួនខ្ញុំផ្ទាល់ក៏ដូចអត់ដែលមានពាក់ព័ន្ធអីរឿងអញ្ជឹងៗ បាទ!និយាយទៅ ។

ដានី ៈ ចុះតាមមើលទៅ អ្នកដែល អឺ!អ្នកនឹងគេយកទៅដាក់កន្លែងសន្តិសុខ កន្លែងមានកន្លែងគេឃុំឃាំង ហើយក៏អត់ទេមើលទៅ?

ទូច ៈ អានឹងអឺ! វាមិនច្បាស់កន្លែង ។

ដានី ៈ បាទ!មន្ទីរកងពល មានកន្លែងគេឃុំឃាំងគេដែរ?

ទូច ៈ គេមានរោងកុងចាស់មួយកាលនឹង ។

ដានី ៈ រោងកុងចាស់ ។

ទូច ៈ គេមានបន្ទប់ៗអញ្ជឹង ។

ដានី ៈ បាទ!មានកន្លែងរោងកុនចាស់?

ទូច ៈ បាទ! ហើយមួយទៀត វានៅវត្ត ប៉ុនដូចនៅវត្ត មិនមែនទេ ដូចនៅរោងកុនចាស់ ។

ដានី ៈ វត្តពោធិញាណ ។

ទូច ៈ ប៉ុនពួកនេះ ខ្ញុំជឿថាមិនយកទៅដាក់ច្របូកច្របល់ជាមួយពួកខ្មែរយើងយ៉ាងណា យ៉ាងណែអីដូចជាមិនទាន់ច្បាស់ នេះបើអ្នកនៅកន្លែងកងពលគេអាចដឹងពួកនឹង ។

ដានី ៈ កន្លែងកងពលពីណាទៅ បើពូអឺ!អាចខ្ញុំទៅសួរនាំគេ ដែលគាត់នឹង ពូនៅស្គាល់ឈ្មោះ?

ទូច ៈ អឺ!នៅកន្លែងកងពលពីគេ រកនឹកដូចជាមិនឃើញនៅអឺ! មាននោរសេនាធំមួយនៅលិច អាចដឹងខ្លះ ក៏មិនដឹងដូចជាគាហាក់ អាចទៅខាងលិចនឹងមានជួបគាហាក់ ។

ដានី ៈ ឡាយ ហាក់នឹង?

ទូច ៈ បាទ!មានជួបគាហាក់ទេ?

ដានី ៈ ជួបដែរ ។

ទូច ៈ បាទ!មានសួរមានអាចដឹងយន់នឹង ។

ដានី ៖ គាត់អត់បានឃើញ គាត់គ្រាន់ថាគ្រាន់ថាៗ ប៉ុន្តែគាត់អត់បានឃើញ គេបញ្ជូន គាត់ថាភាគច្រើនគេបញ្ជូនមកមន្ទីរកងពល គាត់នៅកន្លែងវរសេនាធំ ។

ទូច ៖ ខ្ញុំចង់ចេះ ការពិតទៅគេអត់ថាអត់បានដឹងនឹងវាត្រូវហើយ ព្រោះគាត់ផ្ទះនៅខាងនេះហើយផ្លូវវានៅខាងនេះ កាលណាឡើងឡានទៅៗម៉ង់ហើយ ។ ហើយអឺ!តាហុច ។

ដានី ៖ ហុចហេ៎?

ទូច ៖ ហុច ដូចជានៅកងពល ។

ដានី ៖ ហុចនឹងគាត់នៅណា?

ទូច ៖ កាលនឹងនៅលិចជាមួយគ្នានឹងដែរ ប៉ុនរកនឹកមិនដឹងជានៅណា បើគាត់ស្លាប់បាត់ឬក៏មិនដឹងៗយ៉ាងម៉េច ប៉ុនតាហុចដឹងថានៅកងពលម៉ង់ ។

ដានី ៖ បើតាមពូចាំអ្នកដែលចាប់មក ភាគច្រើនគេចាប់មកខាងដៃអូរឈើទាល ហើយខ្លះទៀតនៅខាងដែពមមើលទៅ?

ទូច ៖ បាទ!ខាងអឺ!កាលណាមាន អឺ!៣វគ្គនឹងដូចជាឡើងអូរឈើទាលទាំង៣នឹង ខ្ញុំ ។

ដានី ៖ ៣វគ្គឡើងអូរឈើទាលទាំង៣?

ទូច ៖ ដូចមិនច្បាស់ទេ ប៉ុនថាដូចជាឡើងអូរឈើទាលទាំង៣ហើយតាមមើល ប៉ុនគ្រាន់ពេលខ្លះខ្ញុំនៅពេលខ្លះខ្ញុំមិននៅអីអញ្ចឹង ប៉ុន្តែវគ្គទី២ និងវគ្គទី៣នឹងដូចជា ប៉ុនចាំម៉ាវគ្គច្បាស់ ។

ដានី ៖ វគ្គដែលចុងក្រោយនឹង?

ទូច ៖ បាទ!វគ្គចុងក្រោយនឹង ។

ដានី ៖ អឺ!កាលនឹងដូច អាកប្បកិរិយាដូចថាបរទេស ដែលគេដឹកដៃដើរនឹង ដើរទៅមើលដូចឃើញយើង មនុស្សយើងធម្មតាដូចអត់នេះ ឬក៏មានលក្ខណៈជាភ័យខ្លាចឬក៏មានលក្ខណៈខឹងឆេវឆាវមើលទៅ បើតាមពូមើលឃើញពី?

ទូច ៖ តាមខ្ញុំមើលដូចអត់មានភ័យខ្លាចផងតាមមើល ដូចធម្មតាៗយើងមើលមុខមិនច្បាស់ដែរយប់យើងមិនមុខមិនច្បាស់ ប៉ុនដូចវាអត់មានអីច្រងើងច្រងំា ទៅក៏ទៅធម្មតាអញ្ចឹងទៅ ។

ដានី ៖ ចុះមានឮដំណឹងថា មានបរទេសនឹងមានស្លាប់អីនៅលើកោះតាងអី ឬក៏កោះណាផ្សេង ដូចថាមានឮដំណឹងថាមានបរទេសអីគេបាញ់ស្លាប់ ឬក៏យ៉ាងម៉េចនៅកោះ?

ទូច ៖ អានឹងមានតែកាលជិនាន់វាយគ្នា ។

ដានី ៖ មានជំនាន់វាយ?

ទូច ៖ បាទ! ហើយដល់ជំនាន់យកទូកនឹងមក អានឹងខ្ញុំវគ្គមួយវគ្គ២នឹងមិនសូវបានច្បាស់ ដូចវាប៉ុនម៉ាវគ្គដែលខ្ញុំមិនបានឃើញ២នាក់ ដូចជារឿងច្បាស់ថាយកមកអូរឈើទាល ។ ប៉ុនថាវាសង្ស័យម៉ាវគ្គមិនដឹងជាវគ្គមួយមិនដឹងជាវគ្គ២មិនដឹង ឬក៏អត់មិនដឹងថាមាននៅកោះតាងនឹងវាមិនច្បាស់កន្លែងនឹងដែរ ។ មានបរទេសដូចមិនមានត្រូវវាយចោលឬក៏មានបញ្ហាអីទេពាក់ព័ន្ធនឹងការស្លាប់នៅនោះទេ ព្រោះថាជាធម្មតាត្រូវយកមនុស្សនឹងមកដល់ជូនកងពល កងអីវាយការណ៍អញ្ចឹងវាគេមិនអាចទៅធ្វើអីគេឬក៏អត់មានទេ ។

ដានី ៖ ប៉ុនបើតាមពូនឹង ពូមានឮដំណឹងថាជនជាតិនឹង អឺ! ពួកបរទេសនឹងជាជនជាតិអីពិតប្រាដកហើយក៏ពូដឹថាជាអាមេរិចកាំង១ ឬក៏?

ទូច ៖ បាទ! ខ្ញុំសង្ស័យថាអាមេរិចកាំងច្រើនជាង ហើយមិនអញ្ចឹងទេ អឺ! ។

ដានី ៖ ពូគ្រាន់តែសង់សង្ស័យខ្លួនឯងទេ?

ទូច ៖ បាទ! សង្ស័យខ្លួនឯង ព្រោះវាមានការពាក់ព័ន្ធគ្នា តាំងពីម៉ាយ៉ហ្គេស វាមានការពាក់ព័ន្ធគ្នាតាំងពីវាយអឺ! ប្រើខម្មាទូកចក្រវាយគ្នានៅកោះតាង មានការពាក់ព័ន្ធគ្នាអញ្ចឹង ។

ដានី ៖ អញ្ចឹងឲ្យតែឃើញស១ស្រមូ៉ង១ថាអាមេរិចកាំងទាំងអស់?

វណ្ណៈ ៖ ទេ! អានឹងវាមិនដឹងទេ ប៉ុន្តែតាមស្មីដែលយើងពាក់ព័ន្ធគ្នាយើងបានដឹងនឹងផ្ទាល់គឺថាអាមេរិចកាំងវាយក អឺ! វាបើកអាម៉ាយ៉ហ្គេសនឹងមិនដឹងរបស់ប្រទេសណាទេប៉ុនថាមានអាមេរិចកាំងហើយអានឹង ។ ហើយដល់ពេលយន្តហោះដែលមកវាយនៅកោះតាងនឹងទៀតអានឹងអាមេរិចកាំងដែរបាទ! ហើយម្ល៉េះហើយ គេចាប់អារម្មណ៍ទៅលើអាមេរិចកាំងនឹងហើយ ។

ដានី ៖ ចុះពូខាងថៃខាងយួនអីវិញ អឺ! បញ្ជូនមកច្រើនដងដែរអត់ មកខាងកោះ ខាងដៃ?

ទូច ៖ មិនសូវច្រើនទេ ។

ដានី ៖ មិនសូវច្រើន?

ទូច ៖ បាទ! បែកខាងនួននឹង ពេលខ្លះមកនឹង ពេលខ្លះក៏ទៅដៃផ្សេង ។

ដានី ៖ ដៃណា?

ទូច ៖ មិនដឹងដៃណាខ្លះទេ ប៉ុនវាអាចជាទៅរាម ឬក៏អាចជាទៅកន្លែងផ្សេង មកនឹងទាំងអស់ពេកទេ ។

ដានី ៖ បាទ! ចុះពូកាលពេលដែល កាលអញ្ចឹងខាងយើងអីមានដែលចូលទៅខាងគេ ហើយគេចាប់បានបាត់អីមានពត៏មានអីដែរអត់?

ទូច ៖ យើងដូចអត់ទេ ។

ដានី ៖ អត់ទេនោះ?

ទូច ៖ កាលនឹងទូកនេសាទយើងវាតិច មិនមានចូលទៅ ដូចថាទឹកដីយើងនេសាទមិនអស់ផងនឹង ទូកវាតិច ហើយដល់ក្រោយមកយើងមាននាវាមានអីគ្រប់គ្រងការពារមើលខុសត្រូវមានវ៉ាដាអីទៅ ដូចជាមិនមានទូកណាថាបាត់ថាអីអញ្ចឹង មានអ្នកចាប់ ។

ដានី ៖ ចុះកាលសម័យនឹងពូមានដែលធ្លាប់មកលេងផ្ទះដែរអត់ ដូចថាកាលពីសម័យ?

ទូច ៖ អត់ល្អើង ។

ដានី ៖ អត់ម៉េង?

ទូច ៖ អត់ៗមកលេងផ្ទះទេ ។

ដានី ៖ ម៉េចដូចថាកាលនឹងពូអាឡែងវល់ ដូចថាភ្លេច?

ទូច ៖ មិនរវល់ទេ យើងមិនភ្លេចទេ យើងចង់ណាស់ ប៉ុន្តែអត់បានមកកាលពីឆ្នាំ៧៥នឹងវាដូចនៅទំនេរច្រើន ដល់ពេលដែលយើងទៅរៀនទៅថាវាជាប់ដៃ ដល់ជាប់ដៃរៀន៧៥ ៧៦ ៧៧ធូរហើយ អ្នកខ្លះគេមានពេលដើររកប្រពន្ធអ្នកណាគេអីអញ្ចឹង ប៉ុន្តែនៅមិនទាន់បានមកលេងផ្ទះ ។

ដានី ៖ កាលនោះពូអត់ទាន់មានប្រពន្ធទេ?

ទូច ៖ អត់មាន កាលនឹងយើងនៅក្មេងជាងគេ ដូចវាគេមានវ័យរៀង២៥អីអញ្ចឹង ហើយគេដើររកប្រពន្ធរកអី ពេល៧៧ ៧៨នឹងគេ ចុង៧៧ ដើម៧៨នឹងគេដើររកប្រពន្ធឡើងស្វាត់ នៅតែខ្ញុំ ២ ៣នាក់ដែលក្មេងចេះនៅ ហើយគេហៅឲ្យទៅ ថាមិនដឹងរកម៉េចអីម៉េចទេ ។

ដានី ៖ កាលនឹងពូអត់ទាន់គ្រប់អាយុ?

ទូច ៖ បាទ!អានឹងយើងអាយុ២០ជាងហើយ ប៉ុនដូចថាវាអត់ទាន់មានការគិតអញ្ចឹង បាទ!គេឲ្យទៅអញ្ចឹងគេទៅតែគ្នាគេនឹង គេបបួលគ្នាទៅអញ្ចឹង យើងក៏អត់ដូចថាមិនចង់ទៅអីអញ្ចឹងណា ។

ដានី ៖ ចុះពូកាលជំនាន់នឹងដូចថាការហូបចុក ដូចជាម្ហូបចំណីបាយទឹកអីដូចបានហូបបានគ្រប់គ្រាន់ដែរឬយ៉ាងម៉េច?

ទូច ៖ បាទ!យើងមានបញ្ហានៅឆ្នាំ៧៦ ហើយដល់ចូល៧៧ ៧៨ហើយលែងមានបញ្ហាអីហើយ ៧៦ នឹងដូចជានៅខែប៉ុន្មាន ខែ៩ខែអីនឹងណា ៧៦ខែ៩ខែអីនឹងមានបញ្ហា អត់ខ្វះខាតដែរ៧៦ ។

ដានី ៖ ខ្វះខាតដែរ?

ទូច ៖ បាទ!ដល់ក្រោយមកអត់មានអីទេហូបបាន ដល់ពេលយើងទៅនៅចូល៧៧ ៧៨នេះវ៉ាន់ហូបណាដើបយាមនឹងហូបទៀតទៅ ហាវស្នានម៉ាហូបស្នាននឹងទៅ ។

ដានី ៖ ចុះពូនៅកំពង់សោមម៉ង អ្នកដូចថាអ្នកគ្រប់គ្រងកំពង់សោមម៉ងពីណាគេ?

ទូច ៖ អ្នកទាហានៗខាងតាមាស មុត ។

ដានី ៖ តាមាស មុត?

ទូច ៖ បាទ! ហើយដល់ស៊ីវិលទៅដែទៅដូចជាខាងអ្នកណាគេអ៊ំគ្រិនៗ ដឹងណាទៀត ។

ដានី ៖ កាលនឹងគ្រប់គ្រងដាច់ដោយគ្នា ឬក៏ដូចថាតាមុត គាត់គ្រប់គ្រង?

ទូច ៖ ដាច់ដោយឡែក ។

ដានី ៖ ដាច់ដោយឡែក?

ទូច ៖ កម្មករទៅ ខាងកម្មករទៅគេគ្រប់គ្រងខាងដៃខាងអីអញ្ចឹង ខស្សេហាកម្មគេពាក់ព័ន្ធនឹងកំពង់ដែអញ្ចឹងទៅ ហើយយើងខាងទាហាននឹងដោយឡែកនឹង ។

ដានី ៖ ចុះតាមុត គាត់នៅកំពង់សោមរហូត ពីតាំងពី៧៥រហូតដល់៧៩ ឬក៏គាត់មានផ្លាស់អីទៅណាទៀតដែរអត់?

ទូច ៖ អត់ផង តាំងពី៧៥រហូតដល់៧៩នឹង គាត់គ្រាន់មានតួនាទីខ្វះ គាត់បានឡើងជាជំនួយការ ឬក៏អីទេ ខាងក្រសួងការពារជាតិដែរ ឬអគ្គបញ្ជាការមិនដឹងទេ មកភ្នំពេញនឹងណា ប៉ុន្តែការពិតគាត់នៅនឹងជាប់ ។

ដានី ៖ គាត់នៅនឹងជាប់?

ទូច ៖ អឺ!

ដានី ៖ គ្រាន់ថាតួនាទីគាត់មានមែន ប៉ុន្តែតាមគាត់ភាគច្រើនគាត់នៅនឹង?

ទូច ៖ ឈរជើងនោះ បាទ! អានឹងចង់និយាយថាមុខសញ្ញាដែលគាត់ប្រចាំការគឺនៅនឹង ។ ការពិតទៅនិយាយអញ្ចឹងទៅ ខ្ញុំដូចជាឆ្ងល់បន្តិច មានអីៗមានដែលទៅសួរគាត់ទេ?

ដានី ៖ ពួកខ្ញុំដូចថាគាត់អឺ! មានតួនាទីធំអីអញ្ចឹងយើងដូចថាអត់ចង់ទៅសួរគាត់ អឺ! ខ្លាចគាត់ទើសទាល់អីពិបាកឆ្លើយអីណា ។

ទូច ៖ រឿងនឹងដូចជារឿងនឹងគាត់ដឹង គេបញ្ជូនៗអីត្រង់ណា ប៉ុនគ្រាន់ថាជាគាត់របៀបជាយោធាជាន់ខ្ពស់ ហើយម្យ៉ាងគាត់ទៅជាអី បើយើងនិយាយទៅវាដូចថាវាចង់ទៅជាអ្នកនយោបាយមួយក៏បាន ពិបាកនឹងសួរត្រង់ថាគាត់មានអឺ! ឱកាស ។

ដានី ៖ បាទ! វាអាចអញ្ចឹង?

ទូច ៖ វាអាចអញ្ចឹងដែរ ព្រោះវាធ្វើម៉េចឲ្យវាទៅតាមស្អីដែរវាអាច និយាយទៅបានស្អីដែលនិយាយទៅមិនបាន អាចអញ្ចឹងដែរ ។

ដានី ៖ ចុះពូកាលនឹង កាលនៅកំពង់សោមនឹង មានដូចថាខាងគណៈប្រតិភូ ឬក៏ថ្នាក់ដឹកនាំប្រទេសអីគេគាត់ធ្លាប់ចូលទៅទស្សនកិច្ច ទៅសួរសុខទុក្ខកងទ័ពជើងទឹកអីដែរអត់?

ឌូច ៖  មានៗ ។

ដានី ៖ មានដែរ?

ឌូច ៖  បាទ!មានអ៊ឹប៊ុល ពត ។

ដានី ៖ អ៊ឹប៊ុល ពត ។

ឌូច ៖  អៀង សារី ។

ដានី ៖ អៀង សារី?

ឌូច ៖  បាទ!

ដានី ៖ គាត់ចុះទៅ គាត់សួរសុខទុក្ខអីថាម៉េច ពូនៅចាំដែរអត់?

ឌូច ៖  បាទ!គាត់ចុះទៅទស្សនះកិច្ចមើលអានាវ៉ានឹង ហើយអឺ!ថ្ងៃមួយគាត់ទៅទទួលអឺអានាវ៉ាប្រឆាំង អឺ!អាខ្មាតធំដែលយើងមានបុគ្គលិក៧០នាក់នឹង ហើយទៅអញ្ជឹងទៅធ្វើការហ៊ឹកហ៊ឺនហើយអឺ បាញ់កាំជ្រួច បាញ់អីអញ្ជឹងទៅណា ដើម្បីឲ្យបានឃើញពីសមត្ថភាពរបស់នាវ៉ានឹងវ៉ាយ៉ាងម៉េច អីយ៉ាងម៉េចអញ្ជឹងណា ។

ដានី ៖ បាទ!អានឹងប៉ុល ពតគាត់ទៅ?

ឌូច ៖  បាទ!

ដានី ៖ ឆ្នាំណា?

ឌូច ៖  អានឹងដូចជា៧៧ ។

ដានី ៖ ៧៧ ចុះអៀង សារីគាត់ទៅឆ្នាំណាដែរ?

ឌូច ៖  អៀង សារី ធ្លាប់ទៅឆ្នាំ តាំងពី៧៧ ប៉ុនគ្រាន់គាត់ដើមឆ្នាំ ។

ដានី ៖ ចុះពូមានប្រសាសន៍មិញថានាវ៉ា ពួកអានាវ៉ាប្រឆាំងនឹង សមាជិកក្នុងកាប៉ាល់មាន៧០នាក់?

ឌូច ៖  បាទ!

ដានី ៖ ចុះការពារ?

ឌូច ៖  ការពារ៣៦ ។

ដានី ៖ ៣៦ ។ បាទ!ចុះអាបណ្តែត?

ឌូច ៖  ១២ ។

ដានី ៖ ១២ហ៎ ។ មានតែ៣ប្រភេទនឹងទេ នាវ៉ា?

ឌូច ៖  ៣ប្រភេទ ។

ដានី ៖ ចុះអា PGFអីនឹងយើងប្រើ?

ទូច ៖ បាទ! PGF អឺ!អានឹងធម្មតានាវាល្បាតដែលយើងសេសសល់នឹង ដូចជាមិនច្បាស់ទេនៅប៉ុន្មាននាក់ទេអានឹង មិនសូវជាមានមនុស្សប៉ុន្មានទេ ។

ដានី ៖ ចុះនាវាបោសមីន?

ទូច ៖ នាវាបោះមីននឹងនៅ៤ ៥នាក់នឹង មិនសូវមានជំនាញប៉ុន្មានដែរ កាលនឹងនោះ ហើយក៏យើងយកមកគ្រាន់ប្រើប្រាស់សំអាតនៅក្នុងទន្លេនឹង ប៉ុននឹង ហើយក៏អត់អាចយកទៅប្រយុទ្ធយកទៅអីវិញបានទេ ។

ដានី ៖ ចុះពូមកដល់សព្វថ្ងៃ ពូនៅមានដូចថាសេសសល់ឯកសារ ឬក៏រូបថតអីកាលពីសម័យ៣ឆ្នាំនឹងដែរអត់ កាលពីសម័យពូធ្វើកងទ័ពជើងទឹកនឹង?

ទូច ៖ អត់ ។

ដានី ៖ អត់មាន?

ទូច ៖ សោកស្តាយដែរ ថតៗនៅលើនឹង ថតអឺ!មូលគ្នានៅខាងក្រោមនៅដៃ ។

## ការស្សេតទី៣ ផ្នែក«ក»

ដានី ៖ រូបថតអីនេះនឹង បាត់បង់ពេលដែលយើងទៅព្រៃពេល?

ទូច ៖ បាទ!យើងទៅរកព្រៃ ។

ដានី ៖ ក្នុងព្រៃនឹង?

ទូច ៖ ពេលដែលយើងជួបបញ្ហារត់ច្រើនលើកច្រើនសារ ហើយជួបខបទុវហេតុអីផ្សេងៗនៅពេលប្រយុទ្ធអី ពេលដូចជាបន្ទាន់អីយើងចោល យើងអត់បានយកវាអីអញ្ចឹង ។ រឿងនឹងបើសិនណាកុំកើតមានអញ្ចឹង ប្រហែលមានសល់ច្រើនមានទាំងមេរៀន ដូចជាមេរៀនដែលយើងបានរៀននឹងក៏មានច្រើន ហើយអឺ!រូបថតក៏មានច្រើន ។ ប៉ុន្តែដល់ពេលយើងទៅ៧៩នឹងយើងនៅក្នុងព្រៃទី១ អត់ហូប អត់អីអញ្ចឹងទៅ ហើយទី២ទៀតអាការប្រយុទ្ធគ្នានឹងដូចជាមានចាញ់មានឈ្នះ ហើយភាគច្រើនយើងចាញ់៧៩នោះ ។ ដល់ចាញ់អញ្ចឹងទៅចេះ ជួនកាលដូចចោលអីវ៉ាន់ ជួនកាលចោលស្បៀងអញ្ចឹងទៅ ដូច្នេះបាត់ម្តងបន្តិចៗទៅវាប៉ុន្មានឆ្នាំក្រោយមកបាត់បង់អស់ហើយ ។

ដានី ៖ ចុះពូបើតាមពូដឹង បើថាពូអាចស្គាល់ថាមិត្តភ័ក្ត ឬក៏អ្នកដែលអាចខ្ញុំទៅទំនាក់ទំនង់ទៅសួរនាំដូចពូទាក់ទងនឹងកងពល១៦៤តាមផ្នែកមួយៗអី ពូអាចនៅ?

ទូច ៖ មនុស្សសំខាន់ខ្ញុំកំពុងរកនឹកមើលដែលដឹងរឿងនឹងនៅនឹងកងពលនឹង ។

ដានី ៖ ក្រៅពីតាមុត? ចុះពូដូចឈ្មោះមឿន ម៉េចដែរ?

ទូច ៖ មឿននឹងបាត់តាំងពីឆ្នាំ៩៨នោះណា៎ ។

ដានី ៖ ៩០ប៉ុន្មាន?

ទូច ៖ បាត់៩៨ ។

ដានី ៖ ៩៨ ម៉េចអញ្ចឹង?

ទូច ៖ គាត់មកនឹងហើយ មិនដឹងមានរឿងអីទំនាស់អីជាមួយនឹង ទំនាស់គានឹងកាច ។

ដានី ៖ កាចហ៎?

ទូច ៖ បាទ!មនុស្សចិត្តល្អ ស្លូតតែកាច ស្លូតនឹងបានន័យថាចិត្តល្អ មិនចេះសោកមិនចេះស្តាយទេធ្វើអីក៏ដោយ ហ៊ានធ្វើហ៊ានទទួលខុសត្រូវ ប៉ុន្តែដល់ទៅកាចគឺកាចត្រឹមមនុស្សណាមិនល្អ មិនបានទេគាត់ចិត្តអាក្រក់ ។ ដល់ហើយមិនដឹងជាមូលហេតុអី ប្រហែលជាមានឈ្លោះគ្នា មានវាយគ្នារហូតដល់ស្លាប់ តាមដំណើរ ព្រោះតានឹងទម្លាប់ខ្ញុំនៅជាមួយគាត់ កាចណាស់ ប៉ុន្តែកាចអ្នកអាក្រក់ ។

ដានី ៖ ប៉ុន្តែពួកខ្ញុំអាចរកគាត់ឃើញដែរអត់ មើលទៅ?

ទូច ៖ រកមិនឃើញ ព្រោះខ្ញុំហើយអ្នករកៗមិនឃើញផង ការពិតយើងស្រឡាញ់គាត់ ហើយរាប់អានគាត់ ព្រោះស្អីដែលយើងធ្វើ ស្អីដែលយើងចេះគឺគាត់ជាអ្នកជួយបង្រៀនយើង ព្រោះគាត់ជាមនុស្សថ្នាក់ទី៣ ។

ដានី ៖ បាទៗ គាត់កម្រិតវប្បធម៌គាត់ខ្ពស់?

ទូច ៖ បាទ!កម្រិតវប្បធម៌គាត់ខ្ពស់គាត់ណាស់ ហើយគាត់ចេះដឹងច្រើន គាត់មានសេចក្តីក្លាហាន គាត់មានការលះបង់ច្រើន ប៉ុន្តែគាត់មានអី!ដូចថាបើករណីអីដែលវាកើតអត់សមហេតុសមផលគាត់មិនលើកលែងទេ គាត់ច្រើនតែតបតវិញបន្ទាន់ៗ គាត់មិនសូវចេះអត់ធន់ទេ ។ ហើយឥឡូវគាត់ស្លាប់បាត់ក៏មិនដឹង ឬក៏គាត់អាចគេចខ្លួនទៅនៅណាដឹង ព្រោះគាត់ជាធម្មតាខ្ញុំនៅជាមួយគាត់ ខ្ញុំនៅតែនឹកគុណគាត់ត្រង់ថាគាត់ចេះប្រដៅមនុស្ស ហើយគាត់ចេះប្រដៅ ចេះណែនាំ ។ ហើយរបៀបរស់នៅអី គឺមើលទៅគាត់ជាអ្នករស់នៅមានរបៀបជាអ្នកដឹកនាំ ប៉ុន្តែសោកស្តាយត្រង់ថាមិនដឹងទៅមានបញ្ហាអីប៉ះទង្គិចជាមួយអ្នកណា ដូចឮថាសម្លាប់គេ ហើយរត់បាត់ ។

ដានី ៖ ខ្ញុំឮពត៌មានអញ្ចឹងដែរ?

ទូច ៖ បាទ!ហើយតាមរករហូតថ្ងៃហ្នឹងមកដល់មកដល់ថ្ងៃនឹង នៅតែបាត់ពត៌មាន ។

ដានី ៖ អត់ដឹងពត៌មាន?

ទូច ៖ បាទ!

ដានី ៖ ចុះក្រៅពីគាត់មានពីណាទៀតដែលអាច?

ទូច ៖ ហើយចុះមានបងអួចមួយ យើងទៅដល់នឹង មិនហៅបងអួចសួរ ។

ដានី ៖ ដោយសារគាត់នៅកន្លែងគេហៅថាបាក់អន្រ្ទុតនឹងឡានទៅអត់រួច ហើយបើថាត្រូវធ្វើដំនើរទាល់តែយើងចំនាយពេលប្រហែល២ម៉ោងទៅ ហើយ២ម៉ោងមក ។

ទូច ៖ បាទ!អានឹងជិះអី! ។

ដានី ៖ ជិះម៉ូតូ?

ទូច ៖ អូប័រ ជិះម៉ូតូហេ៎ ។

ដានី ៖ បើយើងទៅតាមស្រែអំបិល ត្រូវជិះម៉ូតូ ទៅដល់កន្លែង ។

អ្នកជិតខាងៈ ជិះម៉ូតូ ប៉ុន្តែខែវស្សាប្រហែលជិះអូប័រ ជិះទូកអញ្ចឹង ឥឡូវក៏មានទូកអញ្ចឹងដែរ ។

ទូច ៖ យើងអាចចេញសោហ៊ុយឲ្យគាត់ធ្វើដំនើរមក មនុស្សនឹងវាសំខាន់ ។

ដានី ៖ បាទ!គាត់ខាង១អីគេ?

ទូច ៖ អួចដឹងរឿងច្រើនជាងគេបង្អស់ ព្រោះគាត់អី!ពីមុននឹងអំមឿនគាត់ប្រធាន បងអួចគាត់អនុប្រធាន ។

ដានី ៖ គាត់ខាងកាប៉ាល់អី?

ទូច ៖ បាទ!កាប៉ាល់នាវាប្រដេញ ។

ដានី ៖ នាវាប្រដេញហេ៎?

ទូច ៖ បាទ!គាត់ជាអង្គភាពវរសេនាធំបណ្តេញនឹងដែរ ដូចថាមានតាហ៊ន មានតាមឿន មានគាត់ហើយដល់ទៅ ។

ដានី ៖ ចុះពូប៊ូ?

ទូច ៖ បាទ!មានប៊ូដែរ ប៉ុន្តប៊ូគាត់បានទៅស្រុកចិនគាត់ទៅស្រុកចិនបាត់ទៅ ហើយដល់មកវិញវាយូរដែលហើយ បាទ!មិនសូវមានការដឹងរឿងរ៉ាវនឹងច្រើន ដូចបងអួចទេ បងអួចគាត់ដឹងច្រើនតើ ។

វណ្ណៈ បងអួចនឹងប្រពន្ធគាត់ឈ្មោះអីទៅ?

ដានី ៖ អួច យើងទៅសួរពូនួនដឹងទេ គាត់នៅជិតគ្នា?

ទូច ៖ បាទ!ប្រពន្ធឈ្មោះបងរ៉ួច ឬក៏ ។

ដានី ៖ ផ្ទះគាត់ខ្ញុំដឹងដែរតើ ប៉ុន្តែដោយសារនេះខ្ញុំអត់បានទៅជួបគាត់ ។

ទូច ៖ បាទ!មនុស្សសំខាន់ណាស់ ។

ដានី ៖ បាទ!អឺ!គាត់ថ្នាក់កងពលដែរ ដូចថ្នាក់ អឺ!ថ្នាក់វរសេនាធំដែរអញ្ចឹង?

ទូច ៖ បាទ! អានឹងវរសេនាតូច ហើយក្រោយមកទៅជាគណៈកម្មការរបស់វរសេនាធំនឹងដែរ វានៅក្នុងអង្គភាពធំណាស់ ។

ដានី ៖ វរសេនាធំនឹងគ្រប់គ្រងទាំងកាប៉ាល់ការពារ ទាំងកាប៉ាល់បណ្តែត?

ទូច ៖ បាទ!គ្រប់គ្រងនឹងទាំងអស់ម៉ង ។

ដានី ៖ បាទៗ មានពីណាទៀរដែលក្រៅពីនឹង?

ទូច ៖ ខ្ញុំមើលទៅរកមើលទៅ វាមានសេងស្លាប់ហើយ បងសារឿនស្លាប់ហើយ តាហ៊ិនស្លាប់ហើយ ហើយមឿនបាត់ទៀត ហើយបងអ្នួចនឹងនៅរហូតទាល់ដល់តែៗយើងនៅ៧៩នឹងបានបែកគ្នានឹង ដល់ហើយមកជួបគ្នាវិញនៅពេលដែលយើងក្រោយសមាហរណកម្មអីមកនឹង ។ ហើយខ្ញុំក៏ហៅគាត់មកធ្វើសមាគមន៍ធ្វើអីនឹងដែរ ព្រោះពេលដែលខ្ញុំបង្កើតសមាគមន៍នឹងខ្ញុំនឹងយកគាត់ធ្វើជាៗអ្នកជួយពិនិត្យឯកសារ ជួយណែនាំអីៗអញ្ចឹងណា ។ ព្រោះមានតែគាត់នឹងទេដែលនៅកន្លែងនឹងដឹងរឿងច្រើនជាងគេនោះ ហើយនួនក៏គាត់នៅលើកាប៉ាល់ដែរ នួនបើនិយាយទៅតួនាទីគាត់អនុសេនាធំហ៊ើ បងអ្នួចបានគាត់មានតួនាទីវរៈ ។ អញ្ចឹងក្នុងចំណោមកងវរៈទាំងអស់ ដូចជាគិតទៅបងសារ៉ាត់ គាត់អនុសេនាធំ អឺ!ប្រធាននាវាមួយដែរ ប៉ុនការពារ ហើយអ្នកផ្សេងទៀតដូចអត់ដែរ តារ៉េតក៏អនុសេនាធំ តារ៉េតអនុសេនាធំ ។ ទៅនឹងដូចអត់មានៗតែមួយទៀតនៅអឺ!មានតួនាទីខ្ពស់ជាងគេដែលនៅក្នុងកងអាម៉ារីននឹង ។

ដានី ៖ ចុះខាងកោះតាង?

ទូច ៖ កោះតាងដូចជា ។

ដានី ៖ អ្នកដែលគាត់នៅរស់?

ទូច ៖ ដឹងណាណែ កោះតាង ដូចបាត់អស់ច្រើនណាស់កោះតាង ស្លាប់អស់ច្រើនណាស់ បាទ!មកស្លាប់អឺ!៧៩ ។ ខ្ញុំថាយល់ល្អជួបបងអ្នួច ដូចជាមានពត៌មានច្រើនជាងគេបង្អស់ ។

ដានី ៖ បាទៗ ចាំមើលខ្ញុំព្យាយាមទៅជួបគាត់ម៉ាសារទៀត ។

ទូច ៖ បើសិនណាជាតាមរយៈបងនួន ឲ្យគាត់បញ្ជូនមកមិនបដិសេធទេ ។

ដានី ៖ បាទ!ចាំមើលខ្ញុំទាក់ទងមានទូរស័ព្ទគាត់ដែរ ។

ទូច ៖ អូ!បេះការពិតរឿងនឹងយើងចង់និយាយឲ្យវាដឹងសដឹងខ្មៅ ដឹងល្អដឹងអាក្រក់ដែរ យើងអត់ទៅចង់លាក់អីទេ ព្រោះថាសម័យនោះមានកន្លែងខ្លះខុសកន្លែងត្រូវ ។ បាទ!កន្លែងខ្លះល្អ កន្លែងខ្លះមិនល្អ ហើយបើនិយាយសរុបមកវាធ្វើទៅ វាក្នុងរបត់នយោបាយមួយដែលយើងអត់បាន

ដឹង វាមិនដឹងយ៉ាងម៉េចទេ ប៉ុនយើងគិតថាកិច្ចការដែលយើងធ្វើទាំងអស់នឹង គឺដើម្បីប្រទេសជាតិទេ ។ បើរឿងរបត់នយោបាយវាទៅជាការកាប់សម្លាប់អី មនុស្សយ៉ាងម៉េចយ៉ាងម៉ារឿងពាក់ព័ន្ធនឹងការចាប់ទូកនេសាទយួន ថៃអី ការរត់ឆ្លងដែនអី ហើយពាក់ព័ន្ធនឹងការចាប់ទូកនឹងអានឹងជារឿងនយោបាយយើងអត់ដឹងដែរ ។

ដានី ៖ អញ្ចឹងពួកខ្ញុំដូចជាអស់សំនួរអីត្រូវសួរនាំពូទៀតហើយ ពូមានអីចង់បញ្ជាក់បន្ថែមសម្រាប់ ចង់បញ្ជាក់បន្ថែមអី?

ទូច ៖ បាទ!ខ្ញុំគ្រាន់តែចេះ ថាអឺ!ផ្ទាល់ខ្លួនខ្ញុំទេអានេះខ្ញុំមានអឺ!សំណូមពរមួយថាធ្វើម៉េចឲ្យមជ្ឈមណ្ឌលសិទ្ធិមនុស្ស ។

ដានី ៖ មជ្ឈមណ្ឌលឯកសារកម្ពុជា ។

ទូច ៖ អឺ!មែន!អាឯកសារនឹង ឯកសារកម្ពុជានឹងលោកព្យាយាមតាមដានក្នុងរឿង អឺ!ពាក់ព័ន្ធនឹងរបបខ្មែរក្រហមនេះឲ្យបានច្រើនថែមទៀត ដើម្បីយកមក អឺ!បង្ហាញកូនខ្មែរយើងហើយនឹងអឺ!យកមកបង្ហាត់បង្រៀន ជាមេរៀនមួយថានេះជាប្រវត្តិសាស្រ្តមួយដែលល្វីងជូរចត់ ។ បាទហើយអឺ!មួយទៀតសុំឲ្យអឺ!មជ្ឈមណ្ឌលឯកសារនឹងធ្វើម៉េចអាចមានឱកាសឲ្យជួយជំរុញអឺ!ការកាត់ទោសនឹងដើម្បីឲ្យសមទៅនឹងពាក្យដែលយើងសរសេរថាស្វែងរកការពិត តើការពិតវាយ៉ាងម៉េច? បាទ!បើយើងដែលជាអតីតខ្មែរក្រហម តាមការពិតយើងដូចជាអត់មានធ្វើអីខុសដែលយើងនេះ ក្នុងនាមយើងជាប្រដាប់អាវុធដែលឧបករណ៍សំខាន់របស់ខ្មែរក្រហមនឹងណា យើងហាក់ដូចជាអត់មានបានធ្វើអីជាៗបញ្ហាខុសឆ្គងដូចជារឿងពាក់ព័ន្ធនឹងការសម្លាប់មនុស្ស ។បាទ!ការពិតទៅតួនាទីរបស់យើងទាំងយប់ទាំងថ្ងៃនឹង វាដូចជាសំលឹងមើលទៅខាងក្រៅនឹង អឺ!ច្រើនហើយមានតួនាទីមួយរវល់ក្នុងការហាត់ហ្វឹកហ៊ឺន ដើម្បីទប់ទល់នឹងបញ្ហា អឺ!នៅតាមព្រំដែនអញ្ចឹងវាដូចជាអត់មាន ។

ដានី ៖ ភ័យដែរ?

ទូច ៖ បាទ! ហើយអឺ!សំណូមពរនេះ គឺចង់ឲ្យជំរុញអឺ បញ្ហាកាត់ទោសនេះជាឈានទៅរកភាពយុត្តិធម៌ពិតប្រាកដ ដើម្បីឲ្យយើងទាំងអស់គ្នានឹងបានដឹងថាការពិត ព្រោះកិច្ចការខ្លះយើងធ្វើគ្រាន់បានធ្វើ តែយើងអត់ដឹងគោលបំណងពិតរបស់អ្នកនយោបាយនឹងវាយ៉ាងម៉េច ហើយមានអ្នកណាខ្លះហើយបង្កឲ្យមានបញ្ហា ដែលអាចបន្សល់ទុកមកដល់បច្ចុប្បន្ននេះ ។ បាទ! ជាក់ដែលមានរឿងរ៉ាវនៅក្នុងឥឡូវៗថ្មីៗនេះទៀត វាចេះតែមានហូរហែអញ្ចឹង យើងមើលទៅដូចជាសោកស្តាយដែរ មកដល់ថ្ងៃនេះរកខុសរកត្រូវឲ្យអឺ! ថាអ្នកខុសត្រូវទទួលបានអី ហើយអ្នកត្រូវទទួល

បានអី ព្រោះការកើតសង្គ្រាមប្រយុទ្ធគ្នានេះ សង្គ្រាមវាអ្នកខ្លះមើលខ្លួនឯង គ្រាន់ពូថាសង្គ្រាមនេះ ប៉ុនថាអ៊ីទោសកម្មភាពរបស់សង្គ្រាមនោះ ពេលដែលវាកើតនៅកន្លែងណាមួយ តើវាទទួលរងអឺ!ផលប៉ះពាល់យ៉ាងម៉េច ទាំងការបែកបាក់ ការខូចខាត ទាំងការបាត់បង់ អឺ!គ្រោះថ្នាក់ដល់ជីវិតមនុស្សអីៗនៅពេលដែលកើតសង្គ្រាមម្តងៗនៅកន្លែងណា ។ ហើយសម្លេងវាមានពូរបៀបម៉េចខ្លះ ដូចជាគ្រាប់បាញ់ គ្រាប់បែក គ្រាប់ទម្លាក់ គ្រាប់ផ្លោងអីអញ្ចឹងវាមានទិដ្ឋភាពពេលនោះគួរឲ្យរន្ធត់តស្លុតណាស់ ។ អញ្ចឹងអានឹងហើយដែលត្រូវតែយកមកវែកញែកនៅពេលខាងមុខនឹង ដើម្បីឲ្យកូនខ្មែរយើងទាំងអស់គ្នាដឹង ហើយឲ្យតម្លៃវាថាអ្នកធ្វើត្រូវទទួលបានអី ហើយអាអ្នកធ្វើខុសត្រូវទទួលបានអី ខ្ញុំចង់បែកឲ្យដាច់ពីគ្នាអញ្ចឹងកុំឲ្យវាចេះតែនៅប្របូកប្របល់ នាំពិបាក ។

ដានី : ចុះពូយល់ឃើញយ៉ាងម៉េចដែរ ចំពោះតុលាការដើម្បីជំនុំជំរះមេដឹកនាំជាន់ខ្ពស់ខ្មែរក្រហមយើងសព្វថ្ងៃនឹង? ចិត្តពូផ្ទាល់ពូយល់ឃើញយ៉ាងម៉េចដែរ?

ទូច : បាទ!ខ្ញុំទី១ ខ្ញុំមានជំនឿថាអឺ!អ្នកស្នេហាជាតិ អ្នកស្នេហាប្រជាធិបតេយ្យលោកពិតជាមានឆន្ទះក្នុងការជម្រុញអ៊ីៗដែលវាកំពុងកើតមាន អឺ!សព្វថ្ងៃនឹងឲ្យវាដំណើរការទៅបាន ។ ហើយទី២ទៀតក៏សង្ឃឹមទៅ អឺ!អន្តរជាតិ ដែលក្នុងនោះមានប៉ុន្មានប្រទេសគេចូលរួមនោះ អឺ!គេព្រោះថារឿងយើងនេះ បើសិនណាជាមិនមានអន្តរជាតិចូលរួម ខ្ញុំហាក់ដូចជាមិនមានជំនឿទេ ។ ប៉ុនបើមានអង្គការសហប្រជាជាតិចូលរួម ដែលក្នុងនោះមានអាមេរិចកាំងអី អឺ!ខ្ញុំមានជំនឿថាវគ្គទី១ ទី២ ទី៣ ឬក៏ប៉ុន្មានវគ្គនឹងខ្ញុំសង្ឃឹមថាគេនឹងអាចធ្វើឲ្យដោះស្រាយបញ្ហានឹងឲ្យបាន ។ឥឡូវនេះជីវិតខ្ញុំ រហូតដល់ខ្ញុំអឺ!មិត្តភ័ក្តិខ្ញុំស្លាប់អស់ច្រើន ហើយអឺ!ប្រជាពលរដ្ឋយើងស្លាប់អស់ច្រើន ហើយខ្លួនខ្ញុំធ្លាក់ខ្លួនពិការ ហើយអញ្ចឹងនៅមានតែមានសង្ឃឹមតែមួយនឹងទៀតទេ ដែលថាមិនអាចវែកៗអឺ!ញែករកខុសរកត្រូវ បាទ!ជូនយើងទាំងអស់គ្នា មុនពេលយើងស្លាប់ទៅ ហើយកូនយើងអឺ!នៅសល់កូនយើងៗនឹងបានដឹងពីបញ្ហាដែលកើតមាន ។ សង្ឃឹមតែមួយនឹងទៀតទេ បើថាបើកាលណាអ៊ីដែលកំពុងធ្វើនេះ វាមិនត្រឹមត្រូវដូចយើងថាអស់ៗសង្ឃឹម ហើយអឺ!ម្យ៉ាងទៀតក៏យើងគិតថាអ៊ីៗចំពោះមុខយើងៗ ហើយនឹងបញ្ហាទាំងរបស់ខ្មែរយើងកាន់តែមានបញ្ហាធ្ងន់ធ្ងរថែមតិចទៀត ។

ដានី : បាទ! ហើយខ្ញុំមានសំនួរមួយទៀត អឺ!ពួកខ្ញុំជាអ្នកសរសេរ ជាអ្នកស្រាវជ្រាវអីអញ្ចឹងពេលដែលផ្សព្វផ្សាយអ៊ីដែល អឺ!ពួកខ្ញុំបានជួបសំណេះសំណាលជាមួយពូនេះ ឧបមាថាថ្ងៃក្រោយទៅមានអ្នកស្រាវជ្រាវអីបរទេសអីគេស្រាវជ្រាវ ហើយខ្ញុំបានអឺ!សរសេររឿងរ៉ាវដូចពូបាន

ជម្រាបខ្ញុំមិញនឹង ស្រាប់តែមានបរទេសគេចាប់អារម្មណ៍ ហើយគេមកជួបខ្ញុំ ហើយគេចង់ទៅជួបពូអី ពូគិតយ៉ាងម៉េចដែរ?

ទូច ៖ បាទ!អានេះខ្ញុំនៅតែមាន១ អឺ!មួយមានគំនិតមួយថាវាជាបញ្ហាមួយដែលយើងត្រូវតែរួមគ្នាជួយស្រាយបញ្ហាដែលវាមានកន្លងមក បើកាលណាយើងអត់ចូលរួមបំភ្លឺក្នុងករណីនេះ អឺ! យើងហាក់ដូចជាមិនទទួលស្គាល់ការពិត ។ បើកាលណាយើងមិនទទួលស្គាល់ការពិត បញ្ហាវានៅតែជាបញ្ហា អត់ត្រូវបានដោះស្រាយ ។ បាទ!អញ្ចឹងខ្ញុំនៅតែមានអឺ!បំណងមួយចង់ស្រាយបំភ្លឺរឿងនេះដើម្បីឲ្យដឹងរឿងពិតថា វាយ៉ាងម៉េច ។ ហើយខ្ញុំក៏នៅសង្ឃឹមថាខ្ញុំនឹងចូលរួមរាល់សកម្មភាពណាដែលខ្ញុំអាចអឺ!ចូលរួមបាន ព្រោះខ្ញុំមានគំនិតចង់ឲ្យអ៊ីៗដែលវាកើតមកនឹង បានស្រឡះគេទទួលស្គាល់ថា អឺ!ដឹងថាខ្ញុំនេះធ្វើ ។ ពិតមែនតែខ្ញុំជាអតីតខ្មែរក្រហម ប៉ុន្តែអឺ!សកម្មភាពរបស់ខ្ញុំៗបានធ្វើអីខ្លះ ហើយអឺ!ខ្ញុំជាមនុស្សអាក្រក់ដូចគេថា ឬក៏ខ្ញុំជាមនុស្សល្អ ។ នឹងខ្ញុំក៏ចង់លាងសំអាតខ្លួនរបស់ខ្ញុំដែរ ព្រោះស្អីដែលខ្ញុំធ្វើមកដល់សព្វថ្ងៃ គឺជាសកម្មភាពមួយបម្រើប្រទេសពិតប្រាកដ ។ ហើយអឺ!មានការលំបាកណាស់ ពេលដែលយើងធ្វើមិនជារឿងស្រួលទេ ទី១គឺថាការធ្វើពលិកម្មដោយអត់ឃ្លានបំផុត ដោយលំបាកបំផុត ដែលមកដល់សព្វថ្ងៃនេះ មិនទាន់មានខ្មែរណាពិបាកជាងខ្មែរក្រហមទេ បើនិយាយឲ្យមែនទែនទៅ ព្រោះមានអ្នកខ្លះអត់បាយមានអ្នកខ្លះស្លាប់ដូចគ្នា ប៉ុន្តែចំពោះទាហានក៏មានអត់បាយ មានពិបាកវេទនាមានស្លាប់អញ្ចឹងដូចគ្នា ។ អញ្ចឹងអឺ!សរុបឲ្យខ្លីមកៗនៅតែបញ្ហាមួយគឺអឺ! តុលាការនេះតែម្តង បាទ! ។

ដានី ៖ បាទ!អញ្ចឹងពួកខ្ញុំអរគុណពូច្រើន ដែលចំណាយសំនេះសំណាលជាមួយពួកខ្ញុំ មានរឿងដ៏សំខាន់ច្រើនពូ ខ្ញុំអរគុណពូច្រើន ។

ទូច ៖ បាទ!អរគុណច្រើន ។

«ចប់»